សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តរបបសន្តិសុខសង្គមដោយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

ស្រាវជ្រាវចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ម៉ុម ហ៊ាមេឃ**

សាស្ត្រាចារ្យណែនាំ
លោក **ស៊ិន សន្ធា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១១

ឆ្នាំចូលសិក្សា ២០១៤
ឆ្នាំសរសេរសារណា ២០១៨

និស្សិតៈ អាហារូបករណ៍

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ម៉ុម ហ៊ាមេយ** ជានិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ ជំនាន់ទី១១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមបង្ហាញនូវការដឹងគុណ និងរម្លឹកគុណយ៉ាងជ្រាវជ្រៅបំផុតជូនចំពោះ៖

- **លោកឪពុក និងអ្នកម្តាយ** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅកូនឱ្យធ្វើជាមនុស្សល្អ ព្រមទាំងបានផ្តល់ឱកាសឱ្យកូនទទួលបានការសិក្សាតាំងពីតូចរហូតដល់ពេលនេះ ទោះបីជាជួនកាលសេដ្ឋកិច្ចគ្រួសារមានបញ្ហាខ្លាំងយ៉ាងណាក៏ដោយ។ លោកទាំងពីរជាម្លប់ដ៏ត្រជាក់សម្រាប់ឱ្យកូនយកជីវិតទៅជ្រក និងលើកទឹកចិត្តគ្រប់វេលាមិនថាក្នុងការសិក្សា ឬការងារអ្វីក៏ដោយ។
- **វីរៈបុរស វីរៈនារីខ្មែរ** ទាំងឡាយដែលបានបូជាកម្លាំងកាយ កម្លាំងចិត្ត អាយុជីវិត ក្នុងការការពារ ថែរក្សាប្រទេសជាតិ និងបានស្វែងរកសន្តិភាពជូនជាតិ ប្រជាជន ដើម្បីឱ្យប្រទេសជាតិមាន ឱកាសទទួលបាននូវសន្តិភាព និងរីកចម្រើន ថែមទាំងអាចឱ្យប្រជាជនមានឱកាសទទួលបាននូវក្តីសុខនេះបន្ថែមទៀតនៅថ្ងៃមុខ។
- **ឯកឧត្តមសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការរៀបចំដំណើរការគ្រប់គ្រង និងបណ្តុះបណ្តាលដល់រូបខ្ញុំ និងនិស្សិតទាំងអស់។
- លោក **ស៊ិន សង្ហា** (សាស្ត្រាចារ្យណែនាំ) ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការពន្យល់ណែនាំ ផ្តល់ជាគំនិត និងជួយកែតម្រូវទាំងបែបបទនៃការសរសេរ ពាក្យពេចន៍ក្នុងការសរសេរសារណានេះ តាំងពីដើមរហូតដល់ចប់។
- **ឯកឧត្តមនាយកបេឡាជាតិរបបសន្តិសុខសង្គម** គណៈគ្រប់គ្រង និងមន្ត្រី/បុគ្គលិកដែលបម្រើការងារនៅ **បេឡាជាតិរបបសន្តិសុខសង្គម** ទាំងអស់ ដែលបានបង្កភាពងាយស្រួលក្នុងការរកឯកសារដែលពាក់ព័ន្ធ។

ជាចុងក្រោយ ខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធទាំងអស់ឱ្យជួយតាមថែរក្សាអស់សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក/លោកស្រី ជួបតែសេចក្តីសុខគ្រប់ពេលវេលា៕

# អារម្ភកថា

ក្រោយពីសិក្សាអស់រយៈពេល៤ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រូបខ្ញុំ និងមិត្តនិស្សិតជាច្រើននាក់ទៀតបានក្រេបជញ្ជក់ចំណេះដឹងជាច្រើនពីសាស្ត្រាចារ្យលើមុខវិជ្ជាផ្សេងៗរួមមាន៖ នីតិរដ្ឋធម្មនុញ្ញ នីតិរដ្ឋប្បវេណី នីតិព្រហ្មទណ្ឌ នីតិការងារ នីតិរដ្ឋបាល និងនីតិវិធីរដ្ឋបាលជាអាទ៍។ ដូច្នេះដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌនៃការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ និងដើម្បីពង្រីកចំណេះដឹងបន្ថែមទៀត រូបខ្ញុំក៏សម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្ដីពី “**ការអនុវត្តរបបសន្តិសុខសង្គមដោយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)**” មកធ្វើការបកស្រាយ និងចងក្រងជាសារណា។

សារណានេះបង្ហាញពីដំណើរការ និងការប្រព្រឹត្តិទៅនៃស្ថាប័ន **បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)** ដែលរួមមានការអនុវត្តភារកិច្ច បែបបទក្នុងការផ្ដល់តាវកាលិក សមិទ្ធផល អត្ថប្រយោជន៍ជាច្រើនទៀតរបស់សមាជិក**ប.ស.ស** បញ្ហាប្រឈម ដំណោះស្រាយផ្សេងៗនាពេលកន្លងមក។ លើសពីនេះទៀត សារណានេះក៏ជាការរួមចំណែកមួយក្នុងការជួយផ្សព្វផ្សាយនូវគោលនយោបាយនីតិវិធីដើម្បីទទួលបានតាវកាលិក និងសមិទ្ធផលផ្សេងៗរបស់រាជរដ្ឋាភិបាលតាមរយៈបេឡាជាតិរបបសន្តិសុខសង្គមសម្រេចបាន។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាស្នាដៃនេះនឹងក្លាយជាធនធានស្រាវជ្រាវសម្រាប់បងប្អូន និងមិត្តនិស្សិតគ្រប់ជំនាន់ ព្រមទាំងសម្រាប់សមាជិកនៃបេឡាជាតិរបបសន្តិសុខសង្គមផងដែរ។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធពរជ័យសិរីបវរដល់អ្នកអានទាំងអស់ឱ្យជួបតែសេចក្ដីសុខគ្រប់ប្រការ។ ហើយរូបខ្ញុំក៏សប្បាយរីករាយជានិច្ចក្នុងការទទួលយក នូវរាល់ការរិះគន់ក្នុងន័យស្ថាបនាលើស្នាដៃរបស់រូបខ្ញុំមួយនេះ ដើម្បីឱ្យរូបខ្ញុំបាទអាចកែប្រែជាវិជ្ជមានទៅថ្ងៃអនាគត។

សូមអរព្រះគុណ និងសូមអរគុណ៕

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**


ក. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

ខ. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ៣

គ. គោលបំណងនៃការស្រាវជ្រាវ ........ ៣

ឃ. ដែនកំណត់នៃការស្រាវជ្រាវ ........ ៣

ង. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

ច. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

ឆ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


**ជំពូកទី ១**

**របបសន្តិសុខសង្គម**


**ផ្នែកទី ១ ប្រវត្តិរបបសន្តិសុខសង្គម** ........ ៦

**កថាខណ្ឌទី ១ ប្រវត្តិនៃការអនុវត្តរបបសន្តិសុខសង្គមនៅលើសកលលោក** ........ ៦

ក. ការអនុវត្តនៅប្រទេសអាល្លឺម៉ង់ ........ ៦

ខ. ការអនុវត្តនៅសហរដ្ឋអាមេរិក ........ ៦

គ. ការអនុវត្តនៅប្រទេសបារាំង ........ ៦

**កថាខណ្ឌទី ២ ប្រវត្តិនៃការអនុវត្តរបបសន្តិសុខសង្គមនៅព្រះរាជាណាចក្រកម្ពុជា** ........ ៧

**ផ្នែកទី ២ ស្ថាប័នបេឡាជាតិរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា** ........ ៩

**កថាខណ្ឌទី ១ ស្ថានភាពទូទៅ** ........ ៩

ក. ភារកិច្ច ........ ៩

ខ. ប្រភពធនធាន ........ ១០

គ. ការចំណាយ ........ ១០

**កថាខណ្ឌទី ២ រដ្ឋបាល និងរចនាសម្ព័ន្ធគ្រប់គ្រង** ........ ១១

ក. ក្រុមប្រឹក្សានៃបេឡាជាតិរបបសន្តិសុខសង្គម ........ ១១

ក.១. សមាសភាព............................................................................................................ ១១

ក.២. ការតែងតាំង និងការបាត់បង់សមាជិកភាព ........................................................... ១១

ក.៣. ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល............................................................................. ១២

ខ. អង្គការប្រតិបត្តិនៃបេឡាជាតិរបបសន្តិសុខសង្គម........................................................ ១៣

ខ.១. នាយកនៃប.ស.ស...................................................................................................... ១៣

ខ.២. គណនេយ្យករនៃប.ស.ស ........................................................................................ ១៥

ខ.៣. អធិការ ឬ អភិបាលរបបសន្តិសុខសង្គម .................................................................. ១៥

ខ.៣.១. ការតែងតាំង......................................................................................................... ១៦

ខ.៣.២. បេសកកម្ម និងភារកិច្ច.......................................................................................... ១៦

ខ.៤ បុគ្គលិកនៃប.ស.ស .................................................................................................. ១៨

គ. រចនាសម្ព័ន្ធគ្រប់គ្រង..................................................................................................... ១៨

## ជំពូកទី ២

## ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

**ផ្នែកទី ១ តិដ្ឋភាពទូទៅ និងការរៀបចំដំណើរការ** ........................................................... ២០

**កថាខណ្ឌទី ១ ដំណាក់កាលនៃការដាក់ឱ្យអនុវត្ត**............................................................ ២២

**កថាខណ្ឌទី ២ ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងការចុះបញ្ជិកាសមាជិក ប.ស.ស** ... ២២

ក. ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន.............................................................................. ២២

ក.១. រយៈពេលនៃការចុះបញ្ជិកាសហគ្រាស ..................................................................... ២៣

ក.២. នីតិវិធីនៃការចុះបញ្ជិកា............................................................................................ ២៤

ខ. ការចុះបញ្ជិកាសមាជិក ប.ស.ស .................................................................................. ២៥

ខ.១. ការចុះបញ្ជិកាកម្មករនិយោជិតចូលក្នុងបេឡាជាតិរបបសន្តិសុខសង្គម ...................... ២៥

ខ.២. នីតិវិធី ..................................................................................................................... ២៦

ខ.៣. ការរៀបចំឯកសារ...................................................................................................... ២៧

ខ.៤. ភាពមិនប្រក្រតីចំពោះការចុះបញ្ជិកា ........................................................................ ២៨

**កថាខណ្ឌទី ៣ នាគនានសម្រាប់របបធានារ៉ាប់រងហានិភ័យការងារ**.................................. ២៩

ក. អត្រាភាគទាន ...................................................................................................... ២៩
ខ. នីតិវិធីនៃការបង់ភាគទាន ...................................................................................... ៣០
គ. កាលបរិច្ឆេទបង់ភាគទាន ....................................................................................... ៣១
**ផ្នែកទី ២ តាវកាលិកហានិភ័យការងារ** ................................................................... ៣២
**កថាខណ្ឌទី ១ លក្ខខណ្ឌទទួលបានតាវកាលិក** .......................................................... ៣២
ក. ការជូនដំណឹងពីហានិភ័យការងារ ............................................................................ ៣២
ខ. ការអង្កេតគ្រោះថ្នាក់ការងារ ..................................................................................... ៣៣
**កថាខណ្ឌទី ២ តាវកាលិកចំពោះការបាត់បង់សមត្ថភាពការងារជាបណ្ដោះអាសន្ន** ....... ៣៤
ក. ការផ្ដល់សេវាថែទាំ និងព្យាបាល ............................................................................... ៣៥
ខ. ការឧបត្ថម្ភប្រាក់បំណាច់ប្រចាំថ្ងៃ .............................................................................. ៣៥
គ. បែបបទនៃការទាមទារ ............................................................................................ ៣៦
**កថាខណ្ឌទី ៣ ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ និងបាត់បង់ជីវិត** ............... ៣៦
ក. តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ......................................... ៣៦
ក.១. ប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ ................................................. ៣៦
ក.២. ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ ........................................................ ៣៧
ក.៣. សេវាបុននីតិសម្បទា .......................................................................................... ៣៨
ខ. តាវកាលិកសម្រាប់ការបាត់បង់ជីវិតដោយហានិភ័យការងារ ............................................ ៣៨
ខ.១. សោហ៊ុយបូជាសព ............................................................................................. ៣៨
ខ.២. តាវកាលិកឧត្តរជីវី ............................................................................................. ៣៩
**ជំពូកទី ៣**
**ការអនុវត្តរបបថែទាំសុខភាព**
**ផ្នែកទី ១ របបថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ** ........ ៤២
**កថាខណ្ឌទី ១ សាវតា** ............................................................................................. ៤២
**កថាខណ្ឌទី ២ ការចុះបញ្ជិកាកម្មករនិយោជិត និងការបង់ភាគទាន** ............................... ៤៣

ក. ការចុះបញ្ជិកាសមាជិក ប.ស.ស ........................................................................ ៤៣
ខ. ការបង់ភាគទានសម្រាប់របបធានារ៉ាប់រងសុខភាព ................................................. ៤៤
**កថាខណ្ឌទី ៣  តាវកាលិកសម្រាប់របបថែទាំសុខភាព** ............................................ ៤៥
ក. ប្រភេទតាវកាលិក ............................................................................................ ៤៥
ក.១. កញ្ចប់តាវកាលិកសុខភាព ............................................................................ ៤៥
ក.២. សេវាបង្ការសុខភាព ..................................................................................... ៤៧
ខ. លក្ខខណ្ឌ និងនីតិវិធីក្នុងការទទួលបានតាវកាលិក ............................................... ៤៧
ខ.១.  ចំពោះសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ....................................................... ៤៧
ខ.២. ប្រាក់បំណាច់ប្រចាំថ្ងៃ .................................................................................... ៤៩
ខ.៣. សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះ និងបញ្ជូនសព ................................................ ៥០
ខ.៤.សេវាបង្ការសុខភាព ......................................................................................... ៥០
**ផ្នែកទី ២ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន** ........................................................ ៥១
**កថាខណ្ឌទី ១ ការចុះបញ្ជីមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនចូលទៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម** ................................................ ៥២
**កថាខណ្ឌទី ២ ការបង់ភាគទាន** ........................................................................ ៥៣
ក. អត្រាបង់ភាគទាន ............................................................................................ ៥៣
ខ. នីតិវីធីនៃការបង់ភាគទាន ................................................................................... ៥៣
ខ.១. ចំពោះប្រាក់ភាគទានដែលជាបន្ទុករបស់រដ្ឋ ........................................................ ៥៣
ខ.២. ចំពោះប្រាក់ភាគទានដែលជាបន្ទុករបស់សាមីជន ................................................ ៥៤
**កថាខណ្ឌទី ៣ តាវកាលិក** ............................................................................... ៥៤
ក. ការព្យាបាល និងថែទាំវេជ្ជសាស្ត្រ ......................................................................... ៥៤
ខ. សេវាសង្គ្រោះបន្ទាន់ ........................................................................................ ៥៥
**ផ្នែកទី ៣ មូលដ្ឋានសុខាភិបាល និងយន្តការនៃការទូទាត់ថ្លៃសេវាសុខាភិបាល** .......... ៥៦
**កថាខណ្ឌទី ១ មូលដ្ឋានសុខាភិបាលដៃគូ** ........................................................... ៥៧

ក. លក្ខណៈសម្បត្តិមូលដ្ឋានសុខាភិបាលដែលអាចចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ........... ៥៧
ខ. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មូលដ្ឋានសុខាភិបាល ........ ៥៧
គ. ការត្រួតពិនិត្យ និងវាយតម្លៃគុណភាពនៃសេវាសុខាភិបាល ........ ៥៨
គ.១. ការត្រួតពិនិត្យសេវាសុខាភិបាល ........ ៥៨
គ.២. ការវាយតម្លៃគុណភាព ........ ៥៩
**កថាខណ្ឌទី ២ យន្តការនៃការទូទាត់ថ្លៃសេវាសុខាភិបាល** ........ ៦១
ក. លក្ខណៈរួមនៃការទូទាត់ថ្លៃសេវា ........ ៦១
ខ. ការទូទាត់តាមប្រភេទករណី ........ ៦១
គ. ការទូទាត់តាមប្រភេទសេវា ........ ៦២
គ.១. ប្រភេទករណីដែលមាន នៅក្នុងឧបសម្ព័ន្ធ ៦ ហើយដែលត្រូវការសេវា
ពិសេសបន្ថែម ឬ សេវាព្យាបាល និងថែទាំបន្តមានៈ ........ ៦៣
គ.២. ករណីពិសេសផ្សេងទៀតដែលគ្មាននៅក្នុងឧបសម្ព័ន្ធ ៦ ........ ៦៣

## ជំពូកទី ៤

## បញ្ហាប្រឈម ដំណោះស្រាយ និងទិសដៅអនុវត្តបន្ត

**ផ្នែកទី ១ បញ្ហាប្រឈម** ........ ៦៥
**កថាខណ្ឌទី ១ ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងសមាជិក ប.ស.ស** ........ ៦៥
ក. ការចុះបញ្ជិកាសហគ្រាស ........ ៦៥
ខ. ការចុះបញ្ជិកាសមាជិក ប.ស.ស ........ ៦៥
**កថាខណ្ឌទី ២ ការបង់ភាគទាន** ........ ៦៥
**កថាខណ្ឌទី ៣ ការផ្តល់តាវកាលិក** ........ ៦៥
**ផ្នែកទី ២ ដំណោះស្រាយ** ........ ៦៦
**កថាខណ្ឌទី ១ ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងសមាជិកប.ស.ស** ........ ៦៦
**កថាខណ្ឌទី ២ ការបង់ភាគទាន** ........ ៦៦
**កថាខណ្ឌទី ៣ ការផ្តល់តាវកាលិក** ........ ៦៦
**ផ្នែកទី ៣ ទិសដៅអនុវត្តបន្ត** ........ ៦៦

កថាខណ្ឌទី ១ របបធានារ៉ាប់រងហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ ........................ ៦៧
កថាខណ្ឌទី ២ របបសោធន ........................................................................................ ៦៧
**សេចក្តីសន្និដ្ឋាន** ........................................................................................ ៦៨
**អនុសាសន៍** ........................................................................................ ៧០
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# តារាងសម្គាល់អក្សរកាត់

| | |
|---|---|
| ប.ស.ស | : បេឡាជាតិរបបសន្តិសុខសង្គម (NATIONAL SOCIAL SECURITY FUND) |
| AFD | : ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (THE AGENCE FRANÇAISE DE DÉVELOPMENT) |
| ASSA | : សមាគមសន្តិសុខសង្គមអាស៊ាន (ASEAN SOCIAL SECURITY ASSOCIATION) |
| ILO | : អង្គការពលកម្មអន្តរជាតិ (INTERNATIONAL LABOUR ORGANIZATION) |
| GMAC | : សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GARMENT MANUFACTURERS ASSOCIATION IN CAMBODIA) |

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ក. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្នុងបរិបទនៃសកលភាវូបនីយកម្ម និងការរីកសាយភាយនៃលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស វាបានជម្រុញឱ្យមានការយកចិត្តទុកដាក់កាន់តែខ្លាំងថែមទៀតទៅលើសុខុមាលភាពរបស់ប្រជាពលរដ្ឋទូទៅ។ ក្នុងនោះផងដែរ ប្រទេសកម្ពុជាក្រោយពីទទួលបាននូវពន្លឺសន្តិភាពសារជាថ្មី បានខិតខំធ្វើយ៉ាងណាឱ្យមានការអភិវឌ្ឍលើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចប្រកបដោយគុណភាព និងគណនេយ្យភាព។ ក្នុងដំណើរការនេះ រដ្ឋដើរតួយ៉ាងសំខាន់ក្នុងការរៀបចំគោលនយោបាយយុទ្ធសាស្ត្រ ឬលិខិតបទដ្ឋានគតិយុត្ត ធ្វើយ៉ាងណាដើម្បីធានានូវសោមគ្គីធម៌ក្នុងសង្គម ការធានាសន្តិសុខប្រាក់ចំណូលប្រកបដោយប្រសិទ្ធភាព និងអាចទុកចិត្តបាន ពីសំណាក់ប្រជាពលរដ្ឋ។

តាវកាលិកត្រូវបានផ្តល់តាមរយៈការអនុវត្តរបបសន្តិសុខសង្គម ដែលជាយន្តការដ៏មានប្រសិទ្ធភាពមួយក្នុងការចូលរួមចំណែកការជួយសម្រាលនូវបន្ទុករបស់បុគ្គល ឬគ្រួសារណាមួយនៅក្នុងសង្គមដែលទទួលរងនូវការបាត់បង់ និងធ្លាក់ចុះនូវប្រាក់ចំណូល ឬសុខភាព។

**វិស័យសន្តិសុខសង្គមកម្ពុជាបច្ចុប្បន្ន រួមមានៈ**

- របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ
- របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងជនពិការ ដែលគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- សំណាញ់សុវត្ថិភាពសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះក្រោមការផ្តល់សេវាដោយដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធនានា
- ការធានារ៉ាប់រងសង្គមតាមច្បាប់ធានារ៉ាប់រង ដែលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

របបសន្តិសុខសង្គម មានលក្ខណៈផ្សេងៗពីគ្នារវាងបណ្តាប្រទេសនីមួយៗនៅជុំវិញពិភពលោក។ លក្ខណៈខុសគ្នានេះស្តែងឡើងដោយការឱ្យនិយមន័យនៃពាក្យរបបសន្តិសុខសង្គមដោយអាស្រ័យទៅតាមបរិបទនៃប្រទេសនោះ។ ទោះបីជាមានលក្ខណៈខុសគ្នាមួយចំនួនក៏ដោយ វានៅតែមានលក្ខណៈរួមមួយចំនួនដែលអាចឱ្យយើងធ្វើការកត់សម្គាល់បានថាវាជារបបសន្តិសុខសង្គម ដោយការកំណត់នូវគោលបំណងបីធំៗរបស់វារួមមានៈ

១.ការធានាបាននូវតម្រូវការចាំបាច់ផ្នែកសុខភាព

២.ការធានាចំពោះតម្រូវការចាំបាច់នៅពេល ដែលមានសមាជិកសង្គមណាម្នាក់បាត់បង់ប្រាក់

ចំណូលក្នុងលក្ខខណ្ឌនិកម្មវេលាឬ ខកខានមិនបានធ្វើការរកចំណូលដោយសារគ្រោះថ្នាក់ផ្សេងៗ ឬជរាភាព

៣.ការធានាចំពោះតម្រូវការចាំបាច់នៅពេលដែលបន្ទុកគ្រួសារកើនឡើង។

ម្យ៉ាងទៀត លិខិតបទដ្ឋានរបស់នីតិបុគ្គលអន្តរជាតិធំៗ ដូចជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាលេខ ១០២ ស្តីអំពីតាវកាលិកសន្តិសុខសង្គមរបស់អង្គការពលកម្មអន្តរជាតិ (ILO) ដែលសុទ្ធតែជាក្របខ័ណ្ឌផ្នែកសន្តិសុខសង្គមអន្តរជាតិ។ លើសពីនេះទៀតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) និងសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) ក៏បានលើកឡើងពីគោលការណ៍ផ្នែកសន្តិសុខសង្គមផងដែរ រួមមានលើកកម្ពស់ និងធ្វើកិច្ចសហការវិស័យសន្តិសុខសង្គមនៅក្នុងតំបន់តាមគោលបំណង ច្បាប់ និងបទបញ្ញត្តិនៃបណ្តាប្រទេសជាសមាជិក។ យ៉ាងណាមិញកម្ពុជា គឺជាសមាជិកនៃអង្គការអន្តរជាតិធំៗខាងលើ និងអាស៊ាន ដែលស្ថិតក្នុងបរិបទនៃសកលភាវូបនីយកម្ម និងការរីកសាយភាយនូវវប្បធម៌ប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ដែលប្រទេសកម្ពុជាបាន និងកំពុងខិតខំពង្រឹង និងពង្រីកផងនោះ។ ការរៀបចំដាក់ឱ្យអនុវត្តនូវរបបសន្តិសុខសង្គម គឺជាកិច្ចការដែលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំង។

ទាំងនេះសបញ្ជាក់ថា របបសន្តិសុខសង្គម គឺជារដ្ឋាបាលកិច្ចដែលរដ្ឋ /រាជរដ្ឋាភិបាលត្រូវរៀបចំនូវគោលនយោបាយ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងដើម្បីធ្វើយ៉ាងណាស្វែងរកសុខុមាលភាពជូនប្រជាពលរដ្ឋនៅពេលដែលពួកគេជួបនូវហានិភ័យផ្នែកហិរញ្ញវត្ថុ និងសុខភាព ទោះបីជាក្នុងរយៈពេលណាមួយក៏ដោយធ្វើយ៉ាងណាឱ្យពួកគេមានលទ្ធភាពរស់នៅក្នុងសង្គមបន្តទៀតតាមរយៈការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុ សេវាសុខាភិបាល និងវត្ថុប្រើប្រាស់ប្រចាំថ្ងៃជាដើម ដើម្បីឱ្យពួកគេមានអារម្មណ៍កក់ក្តៅ ពោល គឺមិនមានសមាជិកសង្គមណាមួយត្រូវបានសង្គមមិនយកចិត្តទុកដាក់នោះឡើយ។

ចំណុចដែលគួរឱ្យចាប់អារម្មណ៍ជាងនេះទៅទៀតនោះ គឺរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារបាន និងកំពុងដំណើរការយ៉ាងសស្រាក់សស្រាំក្រោមការដឹកនាំ និងជួយជ្រោមជ្រែងពីរាជរដ្ឋាភិបាលកម្ពុជាផ្ទាល់តែម្តង។ បេឡាជាតិរបបសន្តិសុខសង្គម គឺជាប្រតិបត្តិការតែមួយគត់របស់រាជរដ្ឋាភិបាលក្នុងការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

ដោយមើលឃើញពីចំណុចដ៏គួរឱ្យចាប់អារម្មណ៍នេះ ទើបខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ "**ការអនុវត្តរបបសន្តិសុខសង្គមដោយបេឡាជាតិរបបសន្តិសុខសង្គម**" សរសេរជាសារណាបញ្ចប់ឆ្នាំសិក្សារបស់ខ្ញុំតែម្តង។

## ខ. ចំណោទបញ្ហានៃការស្រាវជ្រាវ

- តើបេឡាជាតិរបបសន្តិសុខសង្គមមានបុគ្គលិកលក្ខណ:គតិយុត្តយ៉ាងដូចម្តេច?
- តើបេឡាជាតិរបបសន្តិសុខសង្គមបានអនុវត្តរបបសន្តិសុខសង្គមលើផ្នែកណាខ្លះហើយរហូតមកដល់បច្ចុប្បន្ន?
- តើជនណាខ្លះ ដែលត្រូវបានទទួលនូវតាវកាលិកអ្វីខ្លះ ក្នុងការអនុវត្តរបបសន្តិសុខសង្គមដោយបេឡាជាតិរបបសន្តិសុខសង្គមនេះ?
- ក្នុងការអនុវត្តសកម្មភាពរបស់ខ្លួន តើបេឡាជាតិរបបសន្តិសុខសង្គមទទួលបានលទ្ធផលអ្វីខ្លះ និងបញ្ហាប្រឈមអ្វីខ្លះ?

## គ. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះមានគោលបំណងបង្ហាញអំពីបុគ្គលិកលក្ខណ:គតិយុត្តរបស់បេឡាជាតិរបបសន្តិសុខសង្គម វិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គម តាវកាលិកសមិទ្ធផល និងបញ្ហាប្រឈម ដែលកើតចេញពីការអនុវត្តរបបសន្តិសុខសង្គមដោយស្ថាប័នបេឡាជាតិរបបសន្តិសុខសង្គមនេះ។ លើសពីនេះទៀត ការបំពេញភារកិច្ចទាំងនេះនឹងត្រូវធ្វើការលាតត្រដាងផងដែរ។

## ឃ. ដែនកំណត់នៃការស្រាវជ្រាវ

សារណានេះ មានវិសាលភាពទៅលើការអនុវត្តរបបសន្តិសុខសង្គមដោយបេឡាជាតិរបបសន្តិសុខសង្គមផ្នែកធានារ៉ាប់រងហានិភ័យការងារ និងផ្នែកថែទាំសុខភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានកំណត់ក្នុងបទដ្ឋានគតិយុត្តក្នុងវិស័យការងារ ការសិក្សាលើប្រធានបទនេះ រូបខ្ញុំបានចាប់យកចំណុចដែលពាក់ព័ន្ធនឹង ស្ថាប័នបេឡាជាតិរបបសន្តិសុខសង្គម និងលក្ខណ:ទូទៅនៃរបបសន្តិសុខសង្គមលើផ្នែកធានារ៉ាប់រងហានិភ័យការងារសម្រាប់កម្មករនិយោជិត និងថែទាំសុខភាព សម្រាប់កម្មករនិយោជិត មន្ត្រីសាធារណ: អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនតែប៉ុណ្ណោះ។

របបធានារ៉ាប់រង និងអត្ថប្រយោជន៍ផ្សេងទៀតដែលមានចែងក្នុងច្បាប់ ឬបទដ្ឋានគតិយុត្តដោយឡែកផ្សេងទៀត គឺមិនស្ថិតនៅក្នុងដែនកំណត់នៃការស្រាវជ្រាវនេះទេ

## ង. សារ:សំខាន់នៃការស្រាវជ្រាវ

សារ:សំខាន់វាអាចជាឯកសារពិគ្រោះសម្រាប់ជនទាំងឡាយដែលទទួលតាវកាលិកនៃរបបនេះ ឬក៏សម្រាប់ជាឯកសារដល់បងប្អូនដែលជាអ្នកសិក្សាជំនាន់មុន និងក្រោយអាចយកមកសិក្សាបាន។

## ច. វិធីសាស្ត្រនៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ខ្ញុំទទួលបានទិន្នន័យចំនួនគឺ៖

- បានស្រាវជ្រាវឯកសារដែលពាក់ព័ន្ធទៅនឹងប្រវត្តិនៃការអនុវត្តរបបសន្តិសុខសង្គម នៅលើពិភពលោកពីអ៊ីនធើណែត។
- សិក្សា និងវិភាគលើច្បាប់ និងលិខិតបទដ្ឋានផ្សេងៗដែលពាក់ព័ន្ធនឹងការបង្កើត និងការរៀបចំ**ប.ស.ស** និងច្បាប់ និងលិខិតបទដ្ឋានដែលពាក់ព័ន្ធនឹងការអនុវត្តរបបសន្តិសុខសង្គមដែលជាភារកិច្ចរបស់**ប.ស.ស។**
- ការប្រមូលទិន្នន័យត្រូវបានប្រមូលពីប្រភពពីរសំខាន់ៗគឺៈ
  - o ទិន្នន័យចម្បង ៖ បានមកពីការសាកសួរទៅមន្ត្រី បុគ្គលិកដែលបម្រើការនៅ**ប.ស.ស**។
  - o ទិន្នន័យបន្ទាប់បន្សំ ៖ បានមកពីច្បាប់ និងលិខិតបទដ្ឋានដែលពាក់ព័ន្ធនឹង **ប.ស.ស** និងការអនុវត្តរបបសន្តិសុខសង្គមដោយ**ប.ស.ស**។
- ទិន្នន័យបានមកពីការអង្កេតជាទូទៅតាមរយៈការបម្រើការងារនៅ**ប.ស.ស** អស់រយៈពេល២ឆ្នាំ។

## ឆ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ឯកសារស្រាវជ្រាវនេះ ខ្ញុំបានបែងចែកជា០៤ (បួន) ជំពូករួមមានៈ

**សេចក្តីផ្តើមៈ**

ចំណុចនេះបង្ហាញពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី ១ របបសន្តិសុខសង្គម** ដែលបង្ហាញបន្តិចបន្តួចអំពីប្រវត្តិនៃរបបសន្តិសុខសង្គមលើសកលលោក និងកម្ពុជា រួមទាំងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័នបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)។

**ជំពូកទី ២ ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ** ដែលបង្ហាញអំពីរបបធានារ៉ាប់រងហានិភ័យការងារសម្រាប់ជនទាំឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ការចុះបញ្ជិកាកម្មករនិយោជិតចូលក្នុងបេឡាជាតិរបបសន្តិសុខសង្គម ភាគទាន និងតាវកាលិក។

**ជំពូកទី ៣ ការអនុវត្តរបបថែទាំសុខភាព** ដែលបង្ហាញពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ និងរបបថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។ ហើយក៏មានការបង្ហាញពីរបៀបការប្រើប្រាស់ និងទាមទារតាវកាលិក ការបង់ភាគទាន និងយន្តការនៃការទូទាត់ថ្លៃសេវា។

**ជំពូកទី ៤ បញ្ហាប្រឈម ដំណោះស្រាយ និងទិសដៅអនុវត្តបន្ត** ដែលបង្ហាញពីបញ្ហាប្រឈម

ពាក់ព័ន្ធនឹងការអនុវត្តរបបសន្តិសុខសង្គម ដំណោះស្រាយដែល**ប.ស.ស** បានប្រើប្រាស់កន្លងមក និងទិសដៅអនុវត្តបន្តរបស់**ប.ស.ស**។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍:** ដែលបង្ហាញពីសមិទ្ធិផលកន្លងមករបស់បេឡាជាតិរបបសន្តិសុខសង្គមសម្រេចបាន និងអនុសាសន៍ ដែលស្តែងចេញពីការយល់ឃើញរបស់រូបខ្ញុំផ្ទាល់។

# ជំពូកទី ១

# របបសន្តិសុខសង្គម

# ជំពូកទី ១
# របបសន្តិសុខសង្គម

## ផ្នែកទី ១ ប្រវត្តិរបបសន្តិសុខសង្គម

### កថាខណ្ឌទី ១ ប្រវត្តិនៃការអនុវត្តរបបសន្តិសុខសង្គមនៅលើសកលលោក

#### ក. ការអនុវត្តនៅប្រទេសអាល្លឺម៉ង់

ប្រទេសអាល្លឺម៉ង់ គឺជាប្រទេសទីមួយក្នុងលោកដែលអនុវត្តរបបសន្តិសុខសង្គមមុនគេ។ ប្រទេសអាល្លឺម៉ង់ បានទទួលស្គាល់ដំបូងដោយការផ្តល់នូវការធានារ៉ាប់រងដល់និវត្តជន ដោយកម្មវិធីនេះត្រូវបានអនុវត្តនៅឆ្នាំ ១៨៨៩។

កម្មវិធីនេះត្រូវបានរៀបចំឡើងដោយមានការផ្តួចផ្តើមដោយលោក អធិការបតី **អូតូ វ៉ុន ប៊ីស្មាក់**។ សេចក្តីសម្រេចរបស់លោកអធិការបតី **"អូតូ វ៉ុន ប៊ីស្មាក់"** ត្រូវបានឡាយព្រះហស្តលេខាដោយព្រះចៅអធិរាជ **វិល្លាមទី I** នៅឆ្នាំ១៨៨១។

របបសន្តិសុខសង្គមនៃប្រទេសអាល្លឺម៉ង់ត្រូវបានកំណត់ក្នុង Sozialgesetzbuch, or the "Social Code ដែលមានចំនួន១២ផ្នែករួមមាន ការធានារ៉ាប់រងសម្រាប់ជនគ្មានការងារធ្វើ មន្ត្រីសាធារណ: តំហែទាំសុខភាព និងជរាភាព[1]។

#### ខ. ការអនុវត្តនៅសហរដ្ឋអាមេរិក

របបសន្តិសុខសង្គមត្រូវបានទទួលស្គាល់ដោយច្បាប់នៃសហរដ្ឋអាមេរិកដោយលោកប្រធានាធិបតីអាមេរិក គឺលោក **ហ្វ្រង់ឃ្លីន រ៉ូស្វែល** នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៣៥ តាមរយ:ការផ្តល់ប្រាក់សោធននិវត្តន៍សម្រាប់កម្មករនិយោជិតដែលមានអាយុចាប់ពី ៦៥ឆ្នាំឡើងទៅ[2]។

#### គ. ការអនុវត្តនៅប្រទេសបារាំង

នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ១៨៩៨ រដ្ឋសភាបារាំងបានតម្រូវឱ្យនិយោជកត្រូវធ្វើការចំណាយទៅលើគ្រោះថ្នាក់ការងារ ឬហានិភ័យការងារលើកម្មករនិយោជិតរបស់ខ្លួន។ រហូតដល់ថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩២៨ របបសន្តិសុខសង្គមបារាំងបានពង្រីកវិសាលភាពរបស់ខ្លួនឈានទៅដល់ការអនុវត្ត និងផ្តល់តាវកាលិកលើការថៃទាំសុខភាព ការសម្រាកមាតុភាព និងមរណ:ភាព។រហូតដល់សម័យសាធារណ:រដ្ឋទី៤នៃប្រទេសបារាំងដោយរដ្ឋធម្មនុញ្ញបានបញ្ញត្តិឱ្យមានការផ្តល់នូវការទំនុកបម្រុងខាងផ្នែកហិរញ្ញវត្ថុដល់ជនងាយរងគ្រោះជាអាទិ៍ ស្ត្រី កុមារ និងនិវត្តជន[3]។

---

[1] https://en.wikipedia.org/wiki/Social_security_in_Germany

[2] https://en.wikipedia.org/wiki/Social_Security_(United_States)

[3] https://en.wikipedia.org/wiki/Social_security_in_France

## កថាខណ្ឌទី ២. ប្រវត្តិនៃការអនុវត្តរបបសន្តិសុខសង្គមនៅព្រះរាជាណាចក្រកម្ពុជា

ក្រោមការគ្រប់គ្រងអស់រយៈពេលជិតមួយសតវត្សពីសំណាក់អាណានិគមនិយមបារាំង ចាប់តាំងពីថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ រហូតដល់ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ក្រោយពីទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ ប្រទេសកម្ពុជាបានទទួលរងឥទ្ធិពលយ៉ាងច្រើនរបស់បារាំង ជាពិសេសខាងផ្នែកវប្បធម៌ សេដ្ឋកិច្ច នយោបាយ និងរដ្ឋបាល ហើយក្នុងនោះក៏មានការយកចិត្តទុកដាក់លើការអនុវត្តនូវរបបសន្តិសុខសង្គមផងដែរតាមរយៈ **ព្រះរាជក្រមលេខ៣ ន.ស ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៥៥** មានខ្លឹមសារពាក់ព័ន្ធនឹងសិទ្ធិរបស់កម្មករនិយោជិតក្នុងការទទួលនូវប្រាក់ឧបត្ថម្ភសម្រាប់ប្រពន្ធ និងកូន ដែលបង្ហាញពីការចាប់ផ្តើមឡើងនៃរបបសន្តិសុខសង្គមនៅប្រទេសកម្ពុជាយើង។

ក្រោយពីមានវិបត្តិនយោបាយ និងឈានទៅដល់ការធ្វើរដ្ឋប្រហារថ្ងៃ ទី១៨ ខែមីនា ឆ្នាំ១៩៧០ ទោះបីជារដ្ឋាភិបាលថ្មីបានធ្វើការកែប្រែប្រព័ន្ធរដ្ឋបាលបន្តិចបន្តួចដោយរក្សានូវទម្រង់នៃការដឹកនាំស្ទើរតែដដែលក៏ដោយ ក៏ការអនុវត្តរបបសន្តិសុខសង្គមដែលបានបន្សល់ទុកពីរបបមុនមានការលំបាកដោយសារតែស្ថេរភាពនយោបាយ និងជម្លោះប្រដាប់អាវុធ។

ក្រោយការដួលរលំនៃរបបសាធារណរដ្ឋខ្មែរ ដោយការកាន់កាប់ទីក្រុងភ្នំពេញ ពីសំណាក់កងទ័ពខ្មែរក្រហម នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបសន្តិសុខសង្គមត្រូវបានលុបបំបាត់ទាំងស្រុង។ លើសពីនេះការយកចិត្តទុកដាក់ពីសុខុមាលភាពប្រជាជនគ្រប់រូបភាពត្រូវបានអាក់ខាន និងជំនួសមកវិញនូវការបង្ខំឱ្យធ្វើការហួសកម្លាំង និងការកាប់សម្លាប់។ នេះជាសោកនាដកម្មដ៏សែនឈឺចាប់ដែលតែងតែលងបន្លាចអារម្មណ៍ប្រជាជនខ្មែររហូតដល់សព្វថ្ងៃ។

ក្រោយពីការផ្តួលរំលំរបបប្រល័យពូជសាសន៍ នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩។ ប្រទេសកម្ពុជាហាក់ដូចជាឃើញពន្លឺឡើងវិញបន្តិចបន្ទាប់ពីងងឹតសូន្យឈឹងក្នុងរបបព្រៃផ្សៃអស់រយៈពេល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ។ ចន្លោះពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ ក្រោមការដឹកនាំរបស់របប "សាធារណៈប្រជាមានិតកម្ពុជា" កម្មករនិយោជិតទាំងអស់ ទទួលបានការគាំពារផ្នែកសោធននិវត្តន៍ ទុព្វលភាព មរណភាព និងគ្រោះថ្នាក់ការងារ ប៉ុន្តែជាក់ស្តែងការអនុវត្តមិនបានចេញជារូបរាងអ្វីឡើយ។

នៅឆ្នាំ១៩៨៩ ដោយសារតែមានការធ្វើកំណែទម្រង់សេដ្ឋកិច្ចពីសេដ្ឋកិច្ចតាមបែបផែនការមកសេដ្ឋកិច្ចទីផ្សារ ប្រព័ន្ធសន្តិសុខសង្គមសម្រាប់កម្មករនិយោជិតផ្នែកឯកជនក៏ត្រូវបានកែសម្រួលតាមស្ថានភាពសេដ្ឋកិច្ចជាក់ស្តែង។

ក្រោយពីមានការរៀបចំការបោះឆ្នោតតាមបែបប្រជាធិបតេយ្យក្នុងគោលបំណងសំខាន់ គឺកែប្រែការប្រជែងគ្នាតាមបែបហិង្សាមកជាការប្រជែងតាមរយៈសន្លឹកឆ្នោតនៅឆ្នាំ១៩៩៣ និងឈានទៅដល់ការបង្កើតរដ្ឋធម្មនុញ្ញថ្មី គឺរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលមានលក្ខណៈប្រជាធិបតេយ្យ

និងការគោរពសិទ្ធិមនុស្សជាងមុន។ ការអនុវត្តរបបសន្តិសុខសង្គមក៏មានមូលដ្ឋានគាំទ្រជាច្រើនទៀត។ ជាក់ស្តែងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានទទួលស្គាល់សិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងអស់ស្តីពីសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ[4]។ លើសពីនេះទៀតប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់[5] ហើយរដ្ឋចាត់ចែងឲ្យមានរបបសន្តិសុខសង្គមដល់កម្មករ និងនិយោជិត[6]។ ប្រការនេះបានញាំងឱ្យការអនុវត្តរបបសន្តិសុខសង្គមនៅព្រះរាជាណាចក្រកម្ពុជាកាន់តែមានភាពស៊ីវីល័យ និងគួរឱ្យទុកចិត្តបានជាងមុន។

ផ្អែកតាមសញ្ញាណដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ពាក់ព័ន្ធផ្សេងទៀតត្រូវបានអនុម័តឡើងដែលរួមមាន ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ គ្រប់គ្រងរាល់ទំនាក់ទំនងវិជ្ជាជីវៈ ដែលកើតចេញពីកិច្ចសន្យាការងាររវាងនិយោជក និងកម្មករនិយោជិតដើម្បីធានាឲ្យមានលក្ខខណ្ឌការងារល្អប្រសើររក្សាបាននូវភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ និងពង្រឹងសុវត្ថភាពការងារនៅកន្លែងធ្វើការ។ ច្បាប់នេះក៏បានកំណត់យ៉ាងច្បាស់អំពីនិយមន័យនៃគ្រោះថ្នាក់ការងារ[7] ការទទួលខុសត្រូវរបស់និយោជកចំពោះគ្រោះថ្នាក់ការងារ ដែលកើតឡើងលើកម្មករនិយោជិតរបស់ខ្លួន ការធានារ៉ាប់រងលើការពិនិត្យព្យាបាល ការផ្តល់ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍មួយចំនួនទៀត ដូចមានចែងក្នុងច្បាប់ស្តីពីការងារ (ជំពូកទី៩ ចាប់ពីមាត្រា២៤៩ ដល់ មាត្រា២៥៧ )។

០៥ (ប្រាំឆ្នាំ)ក្រោយមក ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារបានចាប់កំណើតឡើងនៅឆ្នាំ២០០២។ ច្បាប់នេះបង្កើតឡើងក្នុងគោលបំណងបង្កើតឲ្យមាន របបសន្តិសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលរួមមាន៖

១. ផ្នែកសោធននិវត្តន៍ ទទួលបន្ទុកផ្តល់តាវកាលិកជរាភាព ទុព្វលភាព និងមរណៈភាព។

២. ផ្នែកហានិភ័យការងារ ទទួលបន្ទុកផ្តល់តាវកាលិកគ្រោះថ្នាក់ការងារ និងជម្ងឺវិជ្ជាជីវៈ។

ចំពោះផ្នែកផ្សេងៗទៀតនឹងត្រូវកំណត់ដោយអនុក្រឹត្យបន្តបន្ទាប់ដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចជាតិ។

**អនុក្រឹត្យ លេខ១៦ អនក្រ. បក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៧** ស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈ

---

[4] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ មាត្រា៣១ វាក្យខណ្ឌ១

[5] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ មាត្រា៣៦ វាក្យខណ្ឌ៤

[6] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ មាត្រា៧៥

[7] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា២៤៨

រដ្ឋបាលមួយ ដែលមានបេសកកម្មបម្រើសេវាសាធារណៈមានលក្ខណៈសង្គមមានឈ្មោះថា "**បេឡាជាតិរបបសន្តិសុខសង្គម**" សរសេរជាអក្សរកាត់ "**ប.ស.ស**" បេឡាជាតិរបបសន្តិសុខសង្គមមានភារៈកិច្ចគ្រប់គ្រងរបបសន្តិសុខសង្គម ដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញាតិនៃច្បាប់ស្តីពីការងារលើការផ្តល់តាវកាលិក ការប្រមូលភាគទានពីសមាជិក និងការសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីគ្រប់គ្រង និងសម្របសម្រួលការងាររបស់ខ្លួន។

## ផ្នែកទី ២ ស្ថាប័នបេឡាជាតិរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា

### កថាខណ្ឌទី ១ ស្ថានភាពទូទៅ

ផ្អែកតាមអនុក្រឹត្យ លេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ **ប.ស.ស** គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានបេសកកម្មបម្រើសេវាសាធារណៈមានលក្ខណៈសង្គម សរសេរជាអក្សរកាត់ " **ប.ស.ស** "។ **ប.ស.ស** ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប.ស.ស** មានស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ និងជានីតិបុគ្គលសាធារណៈដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ។

**ក. ភារកិច្ច**

**ប.ស.ស** មានភារកិច្ចដូចខាងក្រោម៖

១. គ្រប់គ្រងរបបសន្តិសុខសង្គម ដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញាតិនៃច្បាប់ការងារ។

២. ធានាផ្តល់ឲ្យបានសមស្របនូវតាវកាលិកទាំងឡាយសម្រាប់សមាជិកនៃ**ប.ស.ស** ក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេលជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជម្ងឺ មាតុភាព ជាដើម។

៣.ប្រមូលភាគទានពីសមាជិកនៃ**ប.ស.ស** និងនិយោជក។

៤. សម្របសម្រួល និងរៀបចំឲ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ចសម្រាប់ជាប្រយោជន៍ដល់សមាជិកខ្លួន។

៥. សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បី៖

-អប់រំផ្សព្វផ្សាយអំពីរបៀបបង្ការគ្រោះថ្នាក់ការងារ និងជម្ងឺវិជ្ជាជីវៈ។

-ចាត់វិធានការផ្នែកបច្ចេកទេសសន្តិសុខ និងអនាម័យការងារ

៦. សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីសិក្សាស្រាវជ្រាវ និងអង្កេតហានិភ័យការងារ។

**៧.** ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម[8]។

**៨.** រក្សាទុកនូវបណ្ណសារនិយោជក និងនិយោជិត[9]។

**៩.** ជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណ: អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន[10] និងភារកិច្ចមួយចំនួនទៀតដែលផ្តល់ដោយរាជរដ្ឋាភិបាល។

**ខ. ប្រភពធនធាន**

គ្រប់ស្ថាប័ន ឬអង្គភាពសុទ្ធតែមានធនធានផ្ទាល់សម្រាប់ដំណើរការសកម្មភាពរបស់ខ្លួន ជាក់ស្តែងបេឡាជាតិរបបសន្តិសុខសង្គម មានប្រភពធនធានជាច្រើនរួមមាន៖

១. ធនធានដំបូងដែលរដ្ឋផ្តល់សម្រាប់ការបង្កើត **ប.ស.ស។**

២. ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណ: ដែលមានចែងក្នុងថវិការដ្ឋដូចជាឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភជាមូលធន។

៣.ភាគទានរបស់សមាជិក **ប.ស.ស** និងនិយោជក ដែលទុកសម្រាប់ហិរញ្ញប្បទានលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម។

៤. ប្រាក់ពិន័យពីការយឺតយ៉ាវក្នុងការបង់ភាគទាន ឬការផ្តល់តារាងបៀវត្ស ព្រមទាំងការប្រាក់ពីការយឺតយ៉ាវនេះ។

៥. ផលចំណេញបានមកពីការវិនិយោគ។

៦. អំណោយ ឬអច្ច័យទានផ្សេង។

៧.ប្រភពធនធានដទៃទៀតដែល **ប.ស.ស** ទទួលបានដោយស្របច្បាប់[11]។

**គ. ការចំណាយ**

ក្រោយពីប្រភពធនធានទាំងឡាយរបស់ខ្លួន **ប.ស.ស** ក៏មានមុខចំណាយដើម្បីដំណើរការការងាររបស់ខ្លួនផងដែរ ហើយការចំណាយរបស់ **ប.ស.ស** រួមមាន៖

១. ការចំណាយសម្រាប់តាវកាលិកនៃផ្នែកនីមួយៗ។

២. ការចំណាយសម្រាប់ការងាររដ្ឋបាលនៃប.ស.ស ។

៣. ការចំណាយសម្រាប់សកម្មភាពខាងសុខាភិបាល និងសង្គមកិច្ច។

---

[8] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមឆ្នាំ ២០០៧ មាត្រា៣

[9] ប្រកាសស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងនៃបេឡាជាតិរបបសន្តិសុខសង្គម ប្រការ១

[10] ព្រះរាជក្រឹត្យស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណ: និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណ: អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មាត្រា ៣ និងមាត្រា៥

[11] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមឆ្នាំ ២០០៧ មាត្រា២០

៤. ការចំណាយលើការវិនិយោគដើម្បីជាប្រយោជន៍របស់ **ប.ស.ស**។

ទម្រង់ និងបែបបទនៃការចំណាយខាងលើ ត្រូវចែងលំអិតក្នុងការប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ហើយការចំណាយមួយចំនួនទៀតនឹងត្រូវបានប្រើប្រាស់តាមការចាំបាច់ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល និងក្រសួងអាណាព្យាបាល។

## កថាខណ្ឌទី ២ រដ្ឋបាល និងរចនាសម្ព័ន្ធគ្រប់គ្រង

### ក. ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

#### ក.១. សមាសភាព

បេឡាជាតិរបបសន្តិសុខសង្គមដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានអំណាចដើម្បីគ្រប់គ្រងគ្រឹះស្ថានក្នុងក្របខ័ណ្ឌអនុក្រឹត្យបង្កើត **ប.ស.ស** (អនុក្រឹត្យលេខ ១៦អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧)។ ក្រុមប្រឹក្សាភិបាលកើតឡើងដោយសមាសភាពត្រីភាគីមានមកពីខាងតំណាងរាជរដ្ឋាភិបាល ខាងតំណាងនិយោជក និងខាងតំណាងកម្មករនិយោជិត។

ដោយមានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| – តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| – តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ (មួយ) រូប | សមាជិក |
| – តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ (មួយ) រូប | សមាជិក |
| – តំណាងក្រសួងសុខាភិបាល១ (មួយ) រូប | សមាជិក |
| – តំណាងនិយោជក២ (ពីរ) រូប | សមាជិក |
| – តំណាងកម្មករនិយោជិត២ (ពីរ) រូប | សមាជិក |
| – នាយកនៃ**ប.ស.ស** | សមាជិកស្វ័យប្រវត្តិ[12]។ |

#### ក.២. ការតែងតាំង និងការបាត់បង់សមាជិកភាព

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃប.ស.ស ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រី និងអ្នកដែលសកម្មធ្លាប់បម្រើការងារយ៉ាងតិច ៥(ប្រាំ)ឆ្នាំក្នុងចំណោមឥស្សរជនខ្មែរដែលមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬសេដ្ឋកិច្ច ឬ នីតិសាស្ត្រ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ។

សមាសភាពដែលមកពីតំណាងនិយោជក និងកម្មករនិយោជិត ត្រូវបានជ្រើសរើសដោយអង្គការវិជ្ជាជីវៈរៀងៗខ្លួន។ តំណាងទាំងនេះត្រូវមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមាន

[12] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម មាត្រា៩

សមត្ថភាពក្នុងវិស័យសង្គមកិច្ច ឬសេដ្ឋកិច្ច ឬនីតិសាស្ត្រ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ។

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃប.ស.ស ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ (បី)ឆ្នាំ និងរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រសួង ស្ថាប័ន ឬ អង្គការវិជ្ជាជីវៈដែលខ្លួនតំណាងឱ្យ។

អាណត្តិនេះផងដែរ គឺអាចបញ្ចប់ ឬ អាចបន្តទៀតបានតាមសំណើរបស់ ក្រសួង ស្ថាប័ន ឬអង្គការវិជ្ជាជីវៈដែលខ្លួនតំណាងឱ្យ។

ទោះបីជាទទួលបានសុពលភាពរួចហើយក៏ដោយ ក៏សមាជិកនៃក្រុមប្រឹក្សាភិបាលទាំងអស់អាចនឹងបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីដូចខាងក្រោមៈ

- សមាជិករូបនោះទទួលមរណភាព ឬសុំលាលែង
- សមាជិករូបនោះវិកលចរិត ឬមានស្មារតីមិនប្រក្រតីដោយមានការបញ្ជាក់ពីក្រសួងសុខាភិបាល
- សមាជិករូបនោះក្ស័យធន
- សមាជិករូបនោះទទួលអត្ថប្រយោជន៍ពីកិច្ចសន្យាណាមួយជាមួយ **ប.ស.ស** ឬ បម្រើសេវាកម្មណាមួយឱ្យ **ប.ស.ស** ទោះដោយចំពោះ ឬមិនចំពោះក្តី
- សមាជិករូបនោះត្រូវបានតុលាការផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ
- សមាជិករូបនោះខកខានមិនបានបង់ភាគទានដែលខ្លួនទទួលបន្ទុក
- សមាជិករូបនោះ ដែលបានជាប់ជាសមាជិកសភា ឬរាជរដ្ឋាភិបាល។

ចំពោះសមាជិកក្រុមប្រឹក្សាភិបាលរូបណាដែលបានត្រូវតុលាការចោទប្រកាន់ត្រូវព្យួរការងារជាបណ្តោះអាសន្ន។

ការជំនួសសមាជិកក្រុមប្រឹក្សាភិបាល ដែលបាត់បង់សមាជិកភាពរបស់ខ្លួនត្រូវអនុវត្តដូចគ្នាតាមនីតិវិធីនៃការតែងតាំងដែរ[13]។

### ក.៣. ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវប្រជុំយ៉ាងតិចមួយដងក្នុងរយៈពេល៣ (បី) ខែ ប៉ុន្តែក្រុមប្រឹក្សាភិបាលអាចប្រជុំជាវិសាមញ្ញបានគ្រប់ពេល អាស្រ័យតាមការចាំបាច់របស់ **ប.ស.ស** តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើរបស់នាយកនៃ**ប.ស.ស** ឬ សមាជិកមានចំនួន ៥ (ប្រាំ) នាក់យ៉ាងតិចក្នុងចំណោមសមាជិកទាំងអស់។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃប.ស.ស អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិក

[13] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមឆ្នាំ ២០០៧មាត្រា១០

លើសពី៥០ (ហាសិប) ភាគរយ នៃសមាជិកសរុប។ សមាជិកក្រុមប្រឹក្សាភិបាលដែលពុំមានវត្តមាន ពុំអាចត្រូវបានជំនួសបានទេ។ ប្រសិនបើខ្វះកូរ៉ុម ការប្រជុំត្រូវលើកទៅ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិនក្រោយ ហើយត្រូវពិភាក្សាឡើងវិញលើរបៀបវារៈដដែល។

ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាចំពោះតែបញ្ហាទាំងឡាយណាដែលមានចុះក្នុងរបៀបវារៈ។ របៀបវារៈនៃអង្គប្រជុំនីមួយៗ ព្រមទាំងឯកសារពាក់ព័ន្ធទាំងអស់ ត្រូវផ្ញើរជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឱ្យបានយ៉ាងតិច១០ (ដប់)ថ្ងៃប្រតិទិនមុនពេលបើកសម័យប្រជុំ។ នាយកនៃ**ប.ស.ស** ត្រូវចាត់លេខាធិការកត់ត្រានៃអង្គប្រជុំក្រុមប្រឹក្សាភិបាល[14]។

ចំពោះការប្រជុំពិភាក្សា និងអនុម័តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនទាមទារតែសមាជិកក្រុមប្រឹក្សាភិបាលដែលមកពីផ្នែកសាធារណៈប៉ុណ្ណោះ។ ចំពោះការប្រជុំបែបនេះផងដែរ ត្រូវអញ្ជើញតំណាងបេឡាជាតិសន្តិសុខសង្គម **(ប.ជ.ស)** បេឡាជាតិអតីតយុទ្ធជន **(ប.ជ.អ)** មូលនិធិជនពិការ **(ម.ជ.ព)** និងក្រសួងពាក់ព័ន្ធដើម្បីផ្តល់យោបល់។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលពាក់ព័ន្ធទៅនឹងហានិភ័យការងារ និងថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលបានពិភាក្សា និងអនុម័តត្រូវសុំការពិនិត្យ និងយល់ព្រមពីក្រសួងអាណាព្យាបាលបច្ចេកទេស និងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ ទៅតាមសមត្ថកិច្ចរៀងៗខ្លួន ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល អាចយកជាការបានលុះត្រាតែមានការអនុម័តដោយសម្លេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីសម្លេងស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព។

### ខ. អង្គភាពប្រតិបត្តិនៃបេឡាជាតិរបបសន្តិសុខសង្គម

#### ខ.១. នាយកនៃប.ស.ស

អង្គការប្រតិបត្តិនៃ**ប.ស.ស** ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងមួយចំនួនជាជំនួយការ[15]។ នាយកនៃ**ប.ស.ស** ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ[16]។

នាយកនៃ**ប.ស.ស** ក្រៅពីតួនាទីជាសមាជិកអចិន្ត្រៃយ៍នៃ**ប.ស.ស** គាត់ក៏មានភារកិច្ចជាអ្នកចាត់ចែង និងគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ **ប.ស.ស**។

[14] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម មាត្រា ៧

[15] ប្រកាសស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងនៃបេឡាជាតិរបបសន្តិសុខសង្គម ប្រការ ១

[16] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម មាត្រា ១១

អំណាចសម្រាប់ដំណើរការប្រចាំថ្ងៃដើម្បីដឹកនាំគ្រឹះស្ថាននេះដោយស្របច្បាប់ និងជាតំណាងនៃ**ប.ស.ស** ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់។ ហើយអំណាចនេះត្រូវបានប្រគល់ឱ្យតាមរយៈបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស**។

ក្នុងក្របខ័ណ្ឌនៃអំណាចទាំងនេះ នាយកនៃ**ប.ស.ស** មានភារៈកិច្ចសំខាន់ៗដូចតទៅ៖

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- រៀបចំឯកសារដើម្បីដាក់ជូនក្រុមប្រឹក្សាសម្រេច
- ចាត់ចែងអនុវត្តគ្រប់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងរាយការណ៍តាមដំណាក់កាលនីមួយៗជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាព និងលទ្ធផលការងាររបស់ **ប.ស.ស**
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់**ប.ស.ស** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច
- គ្រប់គ្រងបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបរបស់**ប.ស.ស** ដោយគោរពតាមលក្ខន្តិកៈ ឬច្បាប់ជាធរមាន និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- លើកសំណើជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចចំពោះការជ្រើសរើស តែងតាំង ដំឡើងឋានន្តរៈស័ក្ក ដាក់វិន័យ ឬផ្តល់លាភការដល់បុគ្គលិករបស់ **ប.ស.ស** ដែលនៅក្រៅក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល
- លើកសំណើជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពិនិត្យ និងសម្រេចចំពោះការជ្រើសរើស តែងតាំង ដំឡើងឋានៈ ដាក់វិន័យ ឬ ផ្តល់លាភការដល់មន្ត្រីរាជការនៃ **ប.ស.ស** ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃមន្ត្រីរាជការស៊ីវិល
- ធ្វើជាតំណាងនៃប.ស.ស ចំពោះការតវ៉ា ឬការប្តឹងជំទាស់នានាទាក់ទងដល់ប្រតិបត្តិការរបស់ **ប.ស.ស** និងទទួលខុសត្រូវចំពោះមុខច្បាប់លើគ្រប់ភារកិច្ចការពារផលប្រយោជន៍របស់ **ប.ស.ស**។ (ក្នុងក្របខ័ណ្ឌនៃអំណាចនេះ នាយកនៃប.ស.ស អាចផ្ទេរអំណាចខ្លះ ឬទាំងអស់រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាស្របតាមលក្ខខណ្ឌ ដែលបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ឬ កំណត់ដោយក្រុមប្រឹក្សាភិបាល)[17]។
- ជាអាណាប័កដើមខ្សែរបស់គ្រឹះស្ថាន ដែលអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិឬ អាចបង្កើតនូវរដ្ឋទ័យចំណូល ឬ បុរេប្រទានបាន ដោយមានការយល់ព្រមពីគណនេយ្យករ[18]។
- ជាប្រធានក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីរៀបចំដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីរាជការសាធារណៈ[19] និងតួនាទីមួយចំនួនទៀតតាមការជាក់ស្តែង។

[17] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម មាត្រា១២

[18] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម មាត្រា១៨/១៨.១

### ខ.២. គណនេយ្យករនៃប.ស.ស

**ប.ស.ស** កាន់កាប់គណនេយ្យស្របតាមគោលការណ៍គណនេយ្យសាធារណៈ និងតាមវិធានគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការកំណត់កាលបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំដដែល។

ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុងនៃ**ប.ស.ស**ក្រោមការទទួលខុសត្រូវផ្ទាល់របស់**គណនេយ្យករ**[20]។

គណនេយ្យករនៃ**ប.ស.ស**ត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការយល់ព្រមដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ។

គណនេយ្យករ នេះត្រូវស្ថិតនៅក្រោមឱវាទផ្ទាល់របស់នាយកនៃប.ស.ស [21]។ ក្នុងនាមជាសេនាធិការរបស់នាយក នៃប.ស.ស ដូច្នេះ គណនេយ្យករត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស** ក្នុងនាមជាអ្នកពិគ្រោះយោបល់ តែឥតមានសំឡេងបោះឆ្នោតឡើយ។

ក្នុងក្របខ័ណ្ឌនេះផងដែរ គណនេយ្យករ នៃ**ប.ស.ស**មានភារកិច្ចៈ

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់ **ប.ស.ស**
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ។

ក្នុងលក្ខខណ្ឌដែលគិតថា ការងាររបស់ខ្លួនមានភាពច្រើនជ្រុល ឬដើម្បីបែងចែកការងារឱ្យបានរហ័សគណនេយ្យករនៃ**ប.ស.ស** អាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញាការីរបស់ខ្លួនបាន[22]។

### ខ.៣. អធិការ ឬ អភិបាលរបបសន្តិសុខសង្គម

អធិការ ឬអភិបាលរបបសន្តិសុខសង្គមត្រូវបានបង្កើតឡើងក្នុងគោលដៅត្រួតពិនិត្យលើការអនុវត្តបទប្បញ្ញត្តិនៃ"ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ" នៅតាមសហគ្រាស គ្រឹះស្ថានដើម្បីចុះធ្វើអធិការកិច្ច នៅតាមបណ្តាសហគ្រាសដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃ**ប.ស.ស**តាមផ្តើមអនុវត្តចាប់ពីខែកញ្ញា ឆ្នាំ២០០៩មកម្លេះ[23]។

---

[19] សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីរៀបចំដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ ប្រការ១

[20] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម មាត្រា១៨/១៨.២

[21] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម មាត្រា១៣

[22] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម មាត្រា១៨/១៨.៤

**ខ.៣.១. ការតែងតាំង**

អធិការ និងអភិបាលរបបសន្តិសង្គមត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម។

ការតែងតាំងនេះ ត្រូវតែធ្វើបានចំពោះតែមន្ត្រីរាជការស៊ីវិលនៃបេឡាជាតិរបបសន្តិសុខសង្គម ប៉ុណ្ណោះ។

អធិការ និងអភិបាលរបបសន្តិសុខសង្គម ត្រូវស្បថថានឹងបំពេញភារកិច្ច របស់ខ្លួនឱ្យបានល្អ ដោយស្វាមីភក្តិ និងមិនប្រាប់ឱ្យគេដឹងនូវអាថ៌កំបាំងផលិតកម្ម ពាណិជ្ជកម្ម ឬរបៀបធ្វើ អាជីវកម្ម របស់សហគ្រាសដែលខ្លួនបានដឹងក្នុងពេលបំពេញមុខការរបស់ខ្លួន ទោះបីខ្លួនឈប់ពីតួនាទីរបស់ខ្លួនហើយក្តី[24]។

**ខ.៣.២. បេសកកម្ម និងភារកិច្ច**

ក្នុងក្របខ័ណ្ឌនៃតួនាទីរបស់ខ្លួន អធិការ ឬអភិបាលរបបសន្តិសុខសង្គម មានបេសកកម្ម និង ភារកិច្ចដូចតទៅ៖

- ធានាដល់ការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោម បទប្បញ្ញត្តិនៃច្បាប់ការងារ និងបទបញ្ជាជាធរមាននានា ដែលមានការទាក់ទងនឹងវិស័យ របបសន្តិសុខសង្គម
- ជូនដំណឹង និងផ្តល់ដំបូន្មានបច្ចេកទេសចំពោះនិយោជក និងកម្មករនិយោជិតដែលជា សមាជិកនៃ**ប.ស.ស** អំពីមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការគោរពច្បាប់ និងបទបញ្ជាដទៃ ទៀតនៃរបបសន្តិសុខសង្គម
- ផ្តល់ពត៍មានទៅអាជ្ញាធរមានសមត្ថកិច្ចនូវការមិនគប្បី ឬការរំលោភផ្សេងៗទាក់ទងនឹងវិធាន ការ អនាម័យ និងសន្តិសុខកម្មករនិយោជិត
- អង្កេតគ្រោះថ្នាក់ការងារ និងជម្ងឺវិជ្ជាជីវៈ
- ស៊ើបអង្កេតអំពីស្ថានភាពអ្នកនៅក្នុងបន្ទុក ឬកំណត់ឱ្យច្បាស់អំពីស្ថានភាពសិទ្ធិវន្ត
- ចាត់ចែង និងដោះស្រាយបណ្តឹងតវ៉ានានាទាក់ទងនឹងការអនុវត្តច្បាប់ និងបទបញ្ជា
- ត្រូវរៀចចំកំណត់ហេតុ ជូនគណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងរបស់**ប.ស.ស** ក្នុងករណី វិវាទដោះស្រាយគ្មានការសះជា

[23] សេចក្តីជូនដំណឹងស្តីពីការចុះធ្វើអធិការកិច្ចនៅតាមបណ្តាសហគ្រាស ដែលបានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និង កម្មករនយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩

[24] ប្រកាសស្តីពី ការកំណត់តួនាទី និងភារកិច្ចរបស់អធិការ ឬអភិបាលរបបសន្តិសុខសង្គមនៃបេឡាជាតិរបបសន្តិសុខ សង្គម ប្រការ១

– រៀបចំរបាយការណ៍នៃការប្រព្រឹត្តិល្មើសនឹងបទប្បញ្ញត្តិច្បាប់ជូននាយកនៃ**ប.ស.ស**
– រៀបចំឯកសារនៃការពិន័យជាប្រាក់ជូននាយកនៃ**ប.ស.ស** ដើម្បីពិនិត្យ និងសម្រេច
– រៀបចំសំណុំរឿងបញ្ជូនទៅតុលាការ
– ផ្តល់យោបល់ផ្នែកច្បាប់ និងការអនុវត្តច្បាប់របស់សហគ្រាស គ្រឹះស្ថានជូននាយកនៃ**ប.ស.ស**[25]។

ដើម្បីបំពេញភារកិច្ចរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត អភិបាលដែលមានឯកសណ្ឋានដែលបានកំណត់ដោយច្បាប់ជាធរមាន និងមានលិខិតបញ្ជាបេសកកម្មដែលចេញដោយនាយកនៃ**ប.ស.ស** ត្រូវអនុញ្ញាតឱ្យៈ

- ចូលដោយសេរីទៅក្នុងសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្រោមអំណាចត្រួតពិនិត្យរបស់បេឡាជាតិរបបសន្តិសុខសង្គមដោយមិនបាច់ប្រាប់នៅគ្រប់ម៉ោងធ្វើការ។
- ចាត់ការពិនិត្យផ្សេងៗ ត្រួតពិនិត្យ និងអង្កេតដែលយល់ថាជាការចាំបាច់ ដើម្បីដឹងជាក់ច្បាស់ថាបទប្បញ្ញត្តិត្រូវបានគោរពឱ្យបានហ្មត់ចត់ ជាអាទិ៍ៈ
  – ការសាកសួរនិយោជក សហជីព ឬប្រតិភូបុគ្គលិក ឬកម្មករនិយោជិតម្នាក់ឯងក្តី ចំពោះមុខសាក្សីក្តីអំពីរឿងដែលទាក់ទងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីរបបសន្តិសុខសង្គម
  – ការទាមទារឱ្យនិយោជកប្រគល់នូវសៀវភៅបើកប្រាក់របស់កម្មករនិយោជិត បញ្ជីឯកសារផ្សេងៗ ដែលនិយោជកត្រូវមានតាមការតម្រូវបទប្បញ្ញត្តិច្បាប់ដើម្បីយកមកពិនិត្យនៅនឹងកន្លែងបំពេញបេសកកម្ម។ ក្នុងការពិនិត្យនេះ អធិការ ឬអភិបាលរបបសន្តិសុខសង្គមមានសិទ្ធិថតចម្លង ឬស្រង់សេចក្តីផ្សេងៗចេញពីសៀវភៅ ឬបញ្ជីបើកប្រាក់ ឬឯកសារទាំងអស់នេះតាមការចាំបាច់
  –បង្គាប់ឱ្យបិទផ្សាយនូវប្រកាស ឬអ្វីដែលច្បាប់តម្រូវឱ្យបិទផ្សាយ។
- ក្នុងការត្រួតពិនិត្យម្តងៗ អធិការ ឬអភិបាលរបបសន្តិសុខសង្គមត្រូវប្រាប់វត្តមានរបស់ខ្លួនទៅនិយោជក ឬតំណាងលើកលែងតែករណីដែលខ្លួនយល់ថាការប្រាប់ឱ្យដឹងមុននាំឱ្យខូចប្រសិទ្ធភាពនៃការត្រួតពិនិត្យ។ បន្ទាប់ពីធ្វើកំណត់ហេតុរួចហើយអធិការ ឬអភិបាលរបបសន្តិសុខសង្គមត្រូវដាក់កំណត់ហេតុនេះ ជូននាយកនៃប.ស.សដើម្បីពិនិត្យ និងសម្រេច ដែលក្នុងនោះត្រូវមានបញ្ជាក់អំពីការអនុវត្តតាមច្បាប់ ឬបទល្មើស ឬភាពមិនប្រក្រតីដែលបានរកឃើញផង។

[25] ប្រកាសស្តីពី ការកំណត់តួនាទី និងភារកិច្ចរបស់អធិការ ឬអភិបាលរបបសន្តិសុខសង្គមនៃបេឡាជាតិរបបសន្តិសុខសង្គម ប្រការ២

- អធិការ ឬអភិបាលរបបសន្តិសុខសង្គមអាចហៅសហជីព ឬប្រតិភូបុគ្គលិកម្នាក់ ឬច្រើននាក់ឱ្យដើរជាមួយខ្លួនក្នុងការត្រួតពិនិត្យនោះ[26]។
- ក្នុងករណីទទួលបានដំណឹងអំពីគ្រោះថ្នាក់ការងារ អធិការ ឬ អភិបាលរបបសន្តិសុខសង្គមត្រូវចាត់ចែងចុះអង្កេតដល់ទីកន្លែងឱ្យបានរហ័សបំផុត។ ផ្អែកលើលក្ខខណ្ឌនៃគ្រោះថ្នាក់ការងារ អធិការ ឬអភិបាលរបបសន្តិសុខសង្គមអាចហូត ឬ ដកយកវត្ថុធាតុ ឬសារធាតុ ឬវត្ថុលាយដើម្បីផ្តល់ជូននូវអ្នកជំនាញធ្វើការវិភាគដើម្បីការងារនេះប៉ុណ្ណោះ[27]។ ក្នុងករណីដែលការងារអធិការកិច្ច ឬការអង្កេតគ្រោះថ្នាក់ការងារមានលក្ខណៈស្មុគស្មាញ និងក្នុងករណីចាំបាច់ដោយមានការអនុញ្ញាតពីនាយកនៃ**ប.ស.ស** អធិការ ឬអភិបាលរបបសន្តិសុខសង្គមអាចស្នើអ្នកជំនាញពិតប្រាកដពីក្រសួងពាក់ព័ន្ធ ឬខាងក្រៅ ដូចជាខាង វេជ្ជសាស្ត្រ ខាងយន្តសាស្ត្រ ខាងអគ្គីសនី ខាងគីមី ឬខាងបរិស្ថានជាដើម ដើម្បីពិនិត្យឱ្យបានហ្មត់ចត់អំពីមូលហេតុនៃគ្រោះថ្នាក់នេះ[28]។

**ខ.៤ បុគ្គលិកនៃប.ស.ស**

បុគ្គលិកដែលបម្រើការងារនៅបេឡាជាតិរបបសន្តិសុខសង្គមមានពីរប្រភេទគឺ បុគ្គលិកអន្ត្រៃយ៍ដែលរួមមានមន្ត្រីក្របខ័ណ្ឌក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្រសួងនានា ឬមន្ត្រីដែលជ្រើសរើសតាមសំណើរបស់នាយកនៃ**ប.ស.ស** ឱ្យមកបម្រើការងារនៅស្ថាប័នបេឡាជាតិរបបសន្តិសុខសង្គម(**ប.ស.ស**) និងបុគ្គលិកជាប់កិច្ចសន្យា និងកម្មករ។ បុគ្គលិកជាប់កិច្ចសន្យានេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ស្តីពីការងារ[29]។

**គ. រចនាសម្ព័ន្ធគ្រប់គ្រង**

រចនាសម្ព័ន្ធគ្រប់គ្រង នៃអង្គភាពចំណុះស្ថាប័នបេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**) ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃប.ស.ស។ បច្ចុប្បន្នការិយាល័យចំណុះទាំងអស់មានចំនួន ១២ និងសាខាខេត្ត/ ខណ្ឌដែលគ្រប់ការិយាល័យដឹកនាំដោយប្រធានមួយរូប និងអនុប្រធាន ០២រូប ជាជំនួយការ។

[26] ប្រកាសស្តីពី ការកំណត់តួនាទី និងភារកិច្ចរបស់អធិការ ឬអភិបាលរបបសន្តិសុខសង្គមនៃបេឡាជាតិរបបសន្តិសុខសង្គម ប្រការ៣

[27] ប្រកាសស្តីពី ការកំណត់តួនាទី និងភារកិច្ចរបស់អធិការ ឬអភិបាលរបបសន្តិសុខសង្គមនៃបេឡាជាតិរបបសន្តិសុខសង្គម ប្រការ៤

[28] ប្រកាសស្តីពី ការកំណត់តួនាទី និងភារកិច្ចរបស់អធិការ ឬអភិបាលរបបសន្តិសុខសង្គមនៃបេឡាជាតិរបបសន្តិសុខសង្គម ប្រការ៥

[29] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម មាត្រា១៥

ការិយាល័យទាំងនោះមានរួមមានៈ

- ការិយាល័យរដ្ឋបាល
- ការិយាល័យហិរញ្ញវត្ថុ និងកិច្ចការគណនេយ្យ
- ការិយាល័យសវនកម្មផ្ទៃក្នុង
- ការិយាល័យអធិការកិច្ច និងកិច្ចការនីតិកម្ម
- ការិយាល័យគោលនយោបាយ
- ការិយាល័យតាវកាលិក
- ការិយាល័យបញ្ជិកា និងភាគទាន
- ការិយាល័យពត៌មានវិទ្យា
- ការិយាល័យថែទាំសុខភាព
- ការិយាល័យសាខាខេត្ត/ខណ្ឌ
- ការិយាល័យសោធន
- ការិយាល័យស្តារនីតិសម្បទា
- ការិយាល័យទំនាក់ទំនងសាធារណ:។

ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម និងការរៀបចំរចនាសម្ព័ន្ធ គឺជាការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រនានាដែលពាក់ព័ន្ធទៅនឹងការគាំពារសង្គម និងអនុវត្តរបបសន្តិសុខសង្គមឱ្យស្របតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ដោយផ្អែកលើលក្ខខណ្ឌនៃការរីកចម្រើននៃសេដ្ឋកិច្ច និងសង្គមជាតិក្នុងបរិបទនៃសកលភាវូបនីយកម្ម។ ហើយវាក៏ជាការត្រៀមខ្លួនដើម្បីរៀបចំដាក់ឱ្យអនុវត្តនូវបេសកកម្មលើកដំបូងរបស់បេឡាជាតិរបបសន្តិសុខសង្គមនោះ គឺការដាក់ឱ្យអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារនៅឆ្នាំ២០០៨ នេះ។

# ជំពូកទី ២

# ការអនុវត្តរបបធានារ៉ាប់រង
# ហានិភ័យការងារ

# ជំពូកទី ២

# ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

## ផ្នែកទី ១ ទិដ្ឋភាពទូទៅ និងការរៀបចំដំណើរការ

ដោយសារស្ថានភាពនយោបាយមានស្ថេរភាពល្អ និងអំណោយផលដល់ការប្រកបអាជីវកម្មផ្សេងៗ ជាពិសេសសកម្មភាព ឧស្សាហកម្ម និងសិប្បកម្ម បានញ៉ាំងឱ្យមានការប្រើប្រាស់កម្លាំងពលកម្ម នៃកម្មករនិយោជិតយ៉ាងច្រើនឡើងដើម្បីសម្រេចឱ្យបាននូវមហិច្ឆតាផលិតកម្មរបស់សហគ្រាស គ្រឹះស្ថានរបស់ខ្លួន។

ឆ្លងកាត់តាមការសង្កេតឃើញកន្លងមក បានបង្ហាញថាការបំពេញវិជ្ជាជីវៈជាកម្មករនិយោជិតជារឿយៗតែងតែជួបប្រទះនូវគ្រោះថ្នាក់ជាយថាហេតុ។ គ្រោះថ្នាក់របស់កម្មករនិយោជិតនេះ គឺវាមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងសកម្មភាពផលិតកម្មរបស់សហគ្រាស គ្រឹះស្ថាន។

ដោយមើលឃើញថា កម្មករនិយោជិតគឺ ជាកម្លាំងផលិត ហើយក៏ជាទូទៅត្រូវបានគេកំណត់ថាជាជនខ្សត់ខ្សោយខាងផ្នែកសេដ្ឋកិច្ច (ដោយធៀបនឹងនិយោជក) វាបានជម្រុញឱ្យនីតិនិពន្ធបានរៀបចំតាក់តែងនូវច្បាប់ រួមមានបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗជាច្រើនដើម្បីទុកបង្ការ និងទប់ស្កាត់នូវរាល់ការកើតមានឡើងនូវគ្រោះថ្នាក់ការងារដែលអាចកើតមានឡើងចំពោះកម្មករនិយោជិត ហើយវិធានគតិយុត្តទាំងអស់ គឺតែងតែផ្តោតសំខាន់ និងចង្អុរបង្ហាញអំពីជន ឬស្ថាប័នដែលត្រូវទទួលបន្ទុកចំពោះបញ្ហានេះ។

មុនថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ គ្រោះថ្នាក់ការងារដែលកើតឡើងចំពោះកម្មករនិយោជិត គឺជាបន្ទុករបស់និយោកជកទាំងអស់ដូចមានចែងក្នុងមាត្រា ២៤៨ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ហើយនិយោជកមានកាតព្វកិច្ចមួយចំនួនទៀតដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិតផងដែរ រួមមាន៖

- ត្រូវរៀបចំឱ្យមានការសង្គ្រោះបឋម ដល់ជនរងគ្រោះតាមគ្រប់មធ្យោបាយ
- រក្សាសភាពដើមនៃកន្លែងកើតហេតុ បើតម្រូវឱ្យមានការផ្លាស់ប្តូរកន្លែងកើតហេតុនោះ គឺត្រូវធ្វើកំណត់ហេតុ និងថតទុកជាឯកសារឱ្យបានត្រឹមត្រូវ
- បង្កលក្ខណៈងាយស្រួលដល់ជនដែលដឹងពីគ្រោះថ្នាក់ការងារ ដើម្បីឱ្យជននោះរាយការណ៍ជូនគណៈកម្មការអង្កេតបាន
- ជូនដំណឹងទៅស្ថាប័នមានសមត្ថកិច្ច
- ត្រូវរ៉ាប់រងរាល់ការចំណាយទាំងអស់នៃការអង្កេត
- អនុវត្តឱ្យបានត្រឹមត្រូវនូវវិធានដែលបានចុះក្នុងកំណត់ហេតុ ។

និយាយជារួម គឺរាល់មធ្យោបាយ និងការចំណាយត្រូវធ្លាក់ទៅលើនិយោជក (ឬថៅកែ) តែម្នាក់គត់។ បន្ថែមពីនេះ ការគ្រប់គ្រងទៅលើករណីគ្រោះថ្នាក់ការងារ គឺនៅមានភាពស្មុគស្មាញ និងគ្មានទំនើបកម្ម បានជម្រុញឱ្យរាជរដ្ឋាភិបាលកម្ពុជាបង្កើតបេឡាជាតិរបបសន្តិសុខសង្គម។

ក្រោយការបង្កើតបានជិតមួយឆ្នាំ បេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**)[30] ត្រូវបានទទួលភារកិច្ចលើកដំបូងរបស់ខ្លួនក្នុងក្របខ័ណ្ឌជាស្ថាប័នមួយក្នុងការអនុវត្តរបបសន្តិសុខសង្គមនៅកម្ពុជានៅឆ្នាំ២០០៨[31]។

តាមច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា២៤៨ បានចែងថា " ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គឺជាគ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬក្នុងពេលធ្វើការទោះបីក្នុងហេតុយ៉ាងណាក៏ដោយ ហើយទោះបីមានកំហុសពីកម្មករនិយោជិត ឬមិនមែនក៏ដោយ គឺគ្រោះថ្នាក់ការងារដែលធ្លាក់លើរូបរាងកាយកម្មករនិយោជិតក្នុងពេលបំពេញការងារឱ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈ ទោះមានប្រាក់ឈ្នួលក្តី គ្មានប្រាក់ឈ្នួលក្តី ការមុខងារអ្វី នៅទីកន្លែងណាក៏ដោយ។

ម៉្យាងទៀត ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើរូបកាយកម្មករនិយោជិតក្នុងពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅដ្ឋានខ្លួនត្រង់ឆ្ពោះទៅកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានការឈប់ ឬដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ។ ជម្ងឺដែលបណ្តាលមកពីវិជ្ជាជីវៈទាំងអស់ដូចមានចែងក្នុងច្បាប់នេះ ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ ហើយទទួលបាននូវការជួសជុលដូចគ្នា"។ វាក៏មិនខុសគ្នាពីច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារមាត្រា១២ ។

ចំណែកឯមាត្រា១៣ វាក្យខណ្ឌទី ១ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារបានកំណត់បន្ថែមថា " ជម្ងឺដែលបណ្តាលមកពីវិជ្ជាជីវៈក៏ត្រូវបានចាត់ទុកថាជាហានិភ័យការងារដែរ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គមនិង រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវចេញប្រកាសរួមស្តីពីការកំណត់បញ្ជីជម្ងឺវិជ្ជាជីវៈ ដោយមានភ្ជាប់មកជាមួយនូវបញ្ជីនៃមុខរបរប្រើកម្លាំងកាយ មុខរបរដែលប៉ះពាល់ដោយជាតិពុល និងមុខរបរដែលត្រូវអនុវត្តក្នុងលក្ខខណ្ឌ ឬតំបន់ដែលមានលក្ខណៈមិនប្រក្រតី ដែលនាំឱ្យអ្នកធ្វើការកើតជម្ងឺផ្សេងៗ បន្ទាប់ពីមានការផ្តល់យោបល់ពីក្រុមប្រឹក្សាបច្ចេកទេស" ។

តាមច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ រាល់គ្រោះថ្នាក់ដែលចែងអំពីគ្រោះថ្នាក់ការងារ បានផ្តោតនូវ

[30] អនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧

[31] ប្រកាសលេខ ០២២/០៨កប-ប្រក ស្តីពីការកំណត់ដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨

រាល់គ្រោះថ្នាក់ដែលកើតឡើងនៅពេលធ្វើការពេលធ្វើដំណើរ និងជម្ងឺវិជ្ជាជីវ:។ ចំណែកឯមាត្រា១២ និងមាត្រា១៣ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារហាក់បានបែងចែកអំពីគ្រោះថ្នាក់ក្នុងពេលធ្វើការ ពេលធ្វើដំណើរត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ ហើយនិងជម្ងឺវិជ្ជាជីវ: គឺជាផ្នែកនៃហានិភ័យការងារ។

**កថាខណ្ឌទី ១ ដំណាក់កាលនៃការដាក់ឱ្យអនុវត្ត**

ស្របតាមប្រកាសលេខ០២២/០៨ កប.ប្រក ស្តីពីការកំណត់ដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ ចុះថ្ងៃទី១១ ខែកុម្ភ: ឆ្នាំ២០០៨ ប្រការ២ បានកំណត់ឱ្យអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារនេះ នៅក្នុងដំណាក់កាលដំបូង ត្រូវអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចាប់ពីប្រាំបី (៨)នាក់ឡើងទៅ ចំណែកឯសហគ្រាសផ្សេងពីនេះ ត្រូវបន្តអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងាររហូតដល់មានការកំណត់ថ្មី។ បទដ្ឋានទាំងឡាយដែលពាក់ព័ន្ធនឹងវិស័យការងារ វាគឺស្ថិតនៅក្នុងនីតិរូប ហើយការយល់ដឹងរបស់កម្មករនិយោជិតក៏មានកម្រិត លើសពីនេះពួកគេ គឺកម្លាំងចលករដែលមានឥទ្ធិពលក្នុងសង្គមផងដែរនោះ វាបានញ៉ាំងឱ្យការអនុវត្តនូវប្រកាសនេះត្រូវមានលក្ខណ:ច្បាស់លាស់ និងបត់បែនឱ្យស្របតាមស្ថានការណ៍សង្គម។ ហើយដើម្បីអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ជាដំបូងចាំបាច់ត្រូវធ្វើអធិការកិច្ចតាមគ្រឹះស្ថានទាំងអស់ និងធ្វើការផ្សព្វផ្សាយនូវគោលនយោបាយ និងបទដ្ឋានគតិយុត្តផ្សេងៗដែលទាក់ទងទៅនឹងកាតព្វកិច្ច និងតាវការលិកត្រូវមាន។

**កថាខណ្ឌទី ២ ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងការចុះបញ្ជិកាសមាជិក ប.ស.ស**

**ក. ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន**

សហគ្រាស គ្រឹះស្ថាន សំដៅដល់សហគ្រាស ឬគ្រឹះស្ថាន ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សេវាកម្ម កសិកម្ម សិប្បកម្ម ដឹកជញ្ជូនតាមផ្លូវគោក ឬតាមផ្លូវទឹកទោះជាប្រយោជន៍សាធារណ: ពាក់កណ្តាលសាធារណ: ឬឯកជន ក្រៅសាសនា ឬក្នុងសាសនាក៏ដោយ ទោះមានលក្ខណ:ជាការបង្រៀនវិជ្ជាជីវ: ឬជាការកុសលក៏ដោយ ព្រមទាំងវិជ្ជាជីវ:សេរីនៃសមាគម ឬក្រុមប្រភេទណាក៏ដោយ។ សហគ្រាសអាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗមានប្រើមនុស្សឱ្យធ្វើការក្នុងទីកន្លែងណាមួយប្រាកដ ដូចជារោងចក្រ រោងជាង ការដ្ឋាន ។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំដោយនិយោជក។ គ្រឹះស្ថានស្ថិតនៅក្រោមឱវាទសហគ្រាសមួយជានិច្ច។ គ្រឹះស្ថានអាចមានប្រើមនុស្សតែម្នាក់ក៏បាន

ដែរ។ ករណីគ្រឹះស្ថាននេះមានតែមនុស្សមួយឯកឯង និងមិនស្ថិតនៅក្រោមសហគ្រាសណាទេ នោះគ្រឹះស្ថាននោះត្រូវចាត់ទុកជាសហគ្រាស។[32]

នេះហាក់បង្ហាញនូវចេតនា នៃការធ្វើបញ្ជិកាសហគ្រាស គ្រឹះស្ថានសំដៅដល់ការរៀបចំចងក្រងរៀបចំឱ្យមានរបៀបនូវបណ្ដាសហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតក្នុងដែននៃការអនុវត្តរបបសន្តិសុខសង្គមតាមរយៈការមកចុះបញ្ជីដើម្បីឱ្យខាងបេឡាជាតិរបបសន្តិសុខសង្គមផ្ដល់នូវអត្តលេខសំគាល់សហគ្រាសមួយដល់សហគ្រាសនីមួយៗទៅតាមពេលវេលាមួយដែលកំណត់ដោយច្បាប់លើវិស័យនេះ។

**ក.១. រយៈពេលនៃការចុះបញ្ជិកាសហគ្រាស**

បន្ទាប់ពីធ្វើការផ្សព្វផ្សាយ និងការធ្វើអធិការកិច្ចតាមបណ្ដាសហគ្រាស គ្រឹះស្ថានរួចមក ក្រុមអធិការកិច្ចក៏បានកំណត់បង្ហាញឱ្យបណ្ដាសហគ្រាសណា ដែលស្ថិតនៅក្នុងដែនអនុវត្តនៃបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ និងបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធ។ ការចុះបញ្ជិកាសហគ្រាសគ្រឹះស្ថាន គឺតម្រូវឱ្យតំណាងសហគ្រាសមកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានរបស់ខ្លួននៅស្នាក់ការបេឡាជាតិរបបសន្តិសុខសង្គម។

ចំពោះរយៈពេលនៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានត្រូវបានកំណត់ដូចខាងក្រោម៖

– ចំពោះសហគ្រាស គ្រឹះស្ថាន ដែលកំពុងដំណើរការ និងមិនទាន់ចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គមត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គមរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីប្រកាស លេខ៤៤៨ ក.ប/ប្រ.ក.ប.ស.សស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសង្គម **(ប.ស.ស)** សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧។

– ចំពោះសហគ្រាស គ្រឹះស្ថានដែលបើកដំណើរការថ្មី ក្រោយពីប្រកាសនេះចូលជាធរមានត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានរបស់ខ្លួននៅបេឡាជាតិរបបសន្តិសង្គមយ៉ាងយូរ៣០ (សាមសិប) ថ្ងៃក្រោយពីកាលបរិច្ឆេទបើកសហគ្រាស គ្រឹះស្ថាន។

– ចំពោះសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងថែទាំសុខភាពរួចហើយ មិនតម្រូវឱ្យមកចុះបញ្ជិកាឡើងវិញទេ[33]។

[32] ប្រកាសលេខ៤៤៨ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ប្រការ៤

**ក.២. នីតិវិធីនៃការចុះបញ្ជិកា**

ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើតាមទម្រង់ "**បញ្ជិកាសហគ្រាស គ្រឹះស្ថាន**" ឬហៅថាទម្រង់ "**១.០១**" ។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវភ្ជាប់មកជាមួយនូវទម្រង់ "**១.០១**" នូវវិញ្ញាបនបត្របញ្ជិកាពាណិជ្ជកម្មដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬ លិខិតតួបករណ៍គតិយុត្តសមមូលដទៃទៀត។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះកម្មករនិយោជិតក្នុងពេលដំណាលគ្នានឹង ទម្រង់បញ្ជិកាសហគ្រាស គ្រឹះស្ថាន។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវមានកាតព្វកិច្ចជូនដំណឹងមក **ប.ស.ស** ក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃបន្ទាប់ពីមានការព្យួរ បិទ ឬផ្អាកសកម្មភាពអាជីវកម្ម ការប្តូរនិយោជក ឬម្ចាស់សហគ្រាស ឬតំណាង អាសយដ្ឋាន ឬនាមករណ៍សហគ្រាស[34]។

ក្រោយពីតំណាងសហគ្រាស គ្រឹះស្ថានបានរៀបចំទម្រង់ "**បញ្ជិកាសហគ្រាស គ្រឹះស្ថាន**" និងឯកសារពាក់ព័ន្ធបានសព្វគ្រប់ និងបានយកមកស្នាក់ការបេឡាជាតិរបបសន្តិសុខសង្គមដើម្បីធ្វើការចុះបញ្ជិកាហើយនោះ បេឡាជាតិរបបសន្តិសុខសង្គមត្រូវពិនិត្យ រួចផ្តល់លេខអត្តសញ្ញាណសម្រាប់សហគ្រាសគ្រឹះស្ថាននីមួយៗដោយសហគ្រាស គ្រឹះស្ថានមួយត្រូវទទួលបានលេខអត្តសញ្ញាណតែមួយគត់ ដែលមានឈ្មោះថា "**លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន**"។

បេឡាជាតិរបបសន្តិសុខសង្គមត្រូវផ្តល់ "**វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន**" ជូនទៅសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិការួច។ វិញ្ញបនបត្រនេះចាំបាច់ត្រូវមានចុះលេខ "**អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន**" និងកាលបរិច្ឆេទចុះបញ្ជិកា។ និយោជកត្រូវដាក់តាំងវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាននៅនឹងការិយាល័យបើកប្រាក់ឈ្នួលរបស់សហគ្រាស គ្រឹះស្ថាន[35]។

[33] ប្រកាសលេខ៤៤៨ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ប្រការ៦

[34] ប្រកាសលេខ៤៤៨ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ប្រការ៦

[35] ប្រកាសលេខ៤៤៨ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ប្រការ៩

**ខ. ការចុះបញ្ជិកាសមាជិក ប.ស.ស**

ការចុះបញ្ជិកាសមាជិក **ប.ស.ស** គឺជាការកំណត់អត្តសញ្ញាណសមាជិក ឬជនដែលត្រូវអនុវត្តនូវរបបសន្តិសុខសង្គមផ្នែកធានារ៉ាប់រងហានិភ័យការងារតាមរយៈការផ្តល់នូវតាវកាលិកសម្រាប់ពួកគាត់។

ក្នុងការចុះបញ្ជិកាសមាជិករបស់ខ្លួន ដើម្បីឈានទៅដល់ការអនុវត្តនូវរបបសន្តិសុខសង្គមដែលជាភារកិច្ច និងដើម្បីសម្រេចបេសសកម្មរបស់ខ្លួន បេឡាជាតិរបបសន្តិសុខសង្គមដោយយោងតាមប្រកាសស្តីពី "**ការកំណត់ដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ**" ការចុះបញ្ជិកាចាប់ផ្តើមដំបូងនៅឆ្នាំ២០០៨ និងចំពោះតែកម្មករនិយោជិតណាដែលបម្រើការនៅក្នុងសហគ្រាស គ្រឹះស្ថានណាដែលប្រើប្រាស់កម្មករនិយោជិតចាប់ពី៨ (ប្រាំបី) នាក់ឡើងតែប៉ុណ្ណោះ។ ប៉ុន្តែចាប់ពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ របបធានារ៉ាប់រងហានិភ័យការងារនេះក៏ត្រូវបានអនុវត្តទៅលើមន្ត្រីរាជការសាធារណៈផងដែរ[36]។ ផងដែរវាបានធ្វើឱ្យការកំណត់អត្តសញ្ញាណសមាជិក **ប.ស.ស** ក៏ត្រូវបានបែងចែកជាពីរខុសគ្នាដែរ។

**ខ.១. ការចុះបញ្ជិកាកម្មករនិយោជិតចូលក្នុងបេឡាជាតិរបបសន្តិសុខសង្គម**

កម្មករនិយោជិត សំដៅដល់ជនគ្រប់ប្រភេទ និងគ្រប់សញ្ជាតិ ដែលបានចុះកិច្ចសន្យាយកកំរៃជាសាធារណៈ ឬឯកជន។ លក្ខណៈសម្បត្តិនៃកម្មករនិយោជិត មិនត្រូវគិតពីលក្ខន្តិកៈគតិយុត្តនៃនិយោជក ឬលក្ខន្តិកៈនៃកម្មករនិយោជិត ព្រមទាំងមិនត្រូវគិតពីប្រាក់ឈ្នួលតិច ឬច្រើន[37]។

តើត្រូវធ្វើដូចម្តេចដើម្បីឱ្យកម្មករនិយោជិតទទួលបានលេខអត្តសញ្ញាណសមាជិក **ប.ស.ស**? ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារលើកដំបូងដោយតម្រូវឱ្យតែខាងសហគ្រាស គ្រឹះស្ថានផ្ញើរបញ្ជីឈ្មោះកម្មករនិយោជិតរបស់ខ្លួនមកស្នាក់ការបេឡាជាតិរបបសន្តិសុខសង្គម នោះបេឡាជាតិរបបសន្តិសុខសង្គមនឹងផ្តល់នូវកាតសម្គាល់ខ្លួនសម្រាប់សមាជិករបស់ខ្លួនជាកម្មករ ដែលបម្រើការងារនៅតាមគ្រឹះស្ថាននោះម្នាក់មួយ ដោយភ្ជាប់ជាមួយនូវឈ្មោះ និងលេខអត្តសញ្ញាណសមាជិក **ប.ស.ស**។ លេខអត្តសញ្ញាណដំបូងនោះ មិនត្រឹមតែសម្រាប់សម្គាល់សមាជិក **ប.ស.ស** ប៉ុណ្ណោះទេ គឺវាក៏ជាអត្តលេខសម្រាប់ឱ្យខាងសហគ្រាស យកទៅរៀបចំបង់ភាគទានផ្នែកធានារ៉ាប់រងហានិភ័យការងារសម្រាប់កម្មករនិយោជិតរបស់ខ្លួនមក **ប.ស.ស** ដែរ។

ដើម្បីធានាឱ្យកាន់តែមានភាពត្រឹមត្រូវនៃអត្តសញ្ញាណនៃសមាជិកនីមួយៗ និងដើម្បីអនុវត្ត

[36] អនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ អតីតយុទ្ធជន មាត្រា៣

[37] ប្រកាសលេខ៤៤៨ ស្តីពីបញ្ជិកាសហក្រាស គ្រឹះស្ថាន និងកម្មករនយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ប្រការ៤

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងវិជ្ជាជីវៈឆ្នាំ២០១៤-២០១៨ ដែលជាការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារជាពិសេសការរៀបចំ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកសោធននិវត្តន៍ កម្មករនិយោជិតទាំងអស់ត្រូវបានតម្រូវឱ្យចុះបញ្ជិកាកម្មករនិយោជិតនៅបេឡាជាតិរបបសន្តិសុខសង្គមសារឡើងវិញ ដើម្បីទទួលនូវលេខអត្តសញ្ញាណថ្មីដែលមានលេខសំគាល់ខ្លួន (**លេខសំគាល់ខ្លួន ១៥ខ្ទង់**) និងរូបថត រួមទាំងស្នាមខ្មៅដៃផងដែរ តែស្នាមខ្មៅដៃនោះមិនត្រូវបានដាក់នៅលើកាតសមាជិក**ប.ស.ស** ដូចលេខអត្តសញ្ញាណ និងរូបថតនោះទេ។

**ខ.២. នីតិវិធី**

ដូចរៀបរាប់ខាងលើអញ្ចឹង កាលដើមឡើយ សហគ្រាស គ្រឹះស្ថានគ្រាន់តែផ្ញើរបញ្ជីឈ្មោះកម្មករនិយោជិតរបស់ខ្លួន ជាឯកសារ ដោយមិនចាំបាច់ឱ្យមកជួបខាងមន្ត្រី**ប.ស.ស** ដោយផ្ទាល់ក៏ពួកគេទទួលបានលេខអត្តសញ្ញាណសមាជិកដែរ។

តាមរយៈសេចក្តីជូនដំណឹង"លេខ១២៧ ក.ប/ស.ជ.ណ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជិកាកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម"មក ការចុះបញ្ជិកាកម្មករនិយោជិតមកចុះនៅស្នាក់ការ **ប.ស.ស** ឬចុះបញ្ជិកាជាមួយក្រុមការងារកំណត់អត្តសញ្ញាណកម្មករនិយោជិតរបស់ **ប.ស.ស** ដែលចុះដល់មូលដ្ឋានសហគ្រាស គ្រឹះស្ថានដែលពួកគេកំពុងបម្រើការនោះតែម្តង ប៉ុន្តែតាមពិតទៅការចុះបញ្ជីបែបទំនើបកម្មថ្មីនេះបានចាប់ផ្តើមតាំងពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៥មកម្លេះ។

ការចុះបញ្ជិកានៅតាមស្នាក់ការបេឡាជាតិរបបសន្តិសុខសង្គមដោយផ្ទាល់ គឺជាការមកចុះបញ្ជិកាដោយដោយផ្ទាល់ទៅលើប្រព័ន្ធលើប្រព័ន្ធប្រតិបត្តិការគ្រប់គ្រងទិន្នន័យបញ្ជិការ និងភាគទានដោយផ្ទាល់ (ONLINE REGISTATION)។ តាមរយៈការចុះបញ្ជិបែបនេះ គឺកម្មករនិយោជិតទាំងអស់នឹងទទួលបានលេខអត្តសញ្ញាណសមាជិក**ប.ស.ស**ភ្លាមរួមជាមួយនឹងកាតនោះផងដែរ (ការទទួលបានកាតភ្លាមៗ គឺសម្រាប់តែការចុះបញ្ជិកានៅស្នាក់ការការិយាល័យបញ្ជិកា និងភាគទាននៃបេឡាជាតិរបបសន្តិសុខសង្គមតែប៉ុណ្ណោះ ចំណែកឯការចុះបញ្ជិកានៅតាមការិយាល័យសាខាខេត្ត ឬ ខណ្ឌនឹងត្រូវតម្រូវឱ្យមកយកកាតដោយខ្លួនឯងម្តងទៀត) ។

ចំណែកឯការចុះបញ្ជិកាជាមួយក្រុមការងារបញ្ជិកាកម្មករនិយោជិត ដែលពួកគាត់ចុះទៅដល់មូលដ្ឋានសហគ្រាស គ្រឹះស្ថាន នោះ គឺជាការចុះបញ្ជិកាដោយប្រើអនុប្រព័ន្ធនៃបណ្តាញប្រតិបត្តិការផ្នែកគ្រប់គ្រងទិន្នន័យបញ្ជិកា និងភាគទាន (OFFLINE REGISTATION) ។ ការចុះបញ្ជិកាបែបនេះគឺគេគ្រាន់តែប្រមូលទិន្នន័យ ស្កេនស្នាមខ្មៅដៃ និងថតរូបទុកក្នុងសិនតែប៉ុណ្ណោះ។ បន្ទាប់ពីប្រមូលទិន្នន័យតាមរយៈការចុះកំណត់អត្តសញ្ញាណនៅតាមមូលដ្ឋានសហគ្រាស គ្រឹះស្ថានរួចមក ក្រុម

ការងារនឹងធ្វើការបញ្ចូលនូវពត៌មានទាំងអស់របស់កម្មករនិយោជិត ដែលមានចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ រួចផ្តល់លេខអត្តសញ្ញាណម្តងមួយៗ រួចផលិតកាត និងផ្ញើរកាតសមាជិកទាំងអស់ទៅតាមតំណាងសហគ្រាស គ្រឹះស្ថានទៅឱ្យកម្មករនិយោជិតជាការស្រេច។ ការសម្រួលដោយការចុះកំណត់អត្តសញ្ញាណជូនកម្មករនិយោជិតដល់មូលដ្ឋានសហគ្រាស គ្រឹះស្ថានបែបនេះ គឺអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថានណាដែលប្រើប្រាស់កម្មករនិយោជិតចាប់ពី៥០ (ហាសិប) នាក់ឡើងទៅតែប៉ុណ្ណោះ[38]។

### ខ.៣. ការរៀបចំឯកសារ

ការរៀបចំឯកសារសម្រាប់ចុះបញ្ជិកាកម្មករនិយោជិត គឺជាកាតព្វកិច្ចរបស់និយោជក ឬម្ចាស់សហគ្រាស។ មុនចេញប្រកាសលេខ៤៤៨ ក.ប / ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ គ្រប់កម្មករនិយោជិតត្រូវភ្ជាប់នូវសាលាកប័ត្រពត៌មានសម្រាប់កម្មករ និងឯកសារយោង ដែលមានដូចជាអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សំបុត្របញ្ជាក់កំណើត លិខិតឆ្លងដែន និងលិខិតបញ្ជាក់ទីលំនៅ ចំពោះឯកសារយោងទាំងប្រាំនេះ ភ្ជាប់មកមួយណាក៏បានដែរ។ ប៉ុន្តែក្រោយពីប្រកាសខាងលើចូលជាធរមាន ទម្រង់សាលាកប័ត្រពត៌មានកម្មករនិយោជិតត្រូវប្តូរទម្រង់ ហើយចំណែកឯកសារយោងវិញ ដោយចំពោះជនជាតិខ្មែរតម្រូវឱ្យយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហើយសម្រាប់ជនបរទេស គឺតម្រូវឱ្យភ្ជាប់មកជាមួយនូវលិខិតឆ្លងដែន[39] និងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍។ តាមខ្លឹមសារនៃប្រកាសលេខ៤៤៨ បានបង្ហាញថាសម្រាប់ជនជាតិខ្មែរ គឺយកតែអត្តសញ្ញាណប័ណ្ណតែមួយមុខគត់ ប៉ុន្តែជាក់ស្តែងសម្រាប់អ្នកគ្មានអត្តសញ្ញាណប័ណ្ណអាចប្រើលិខិតឆ្លងដែនជំនួសបាន។

ចំពោះឯកសារយោងនេះផងដែរ បើកម្មករនិយោជិតណាមកចុះបញ្ជីនៅស្នាក់ការ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវភ្ជាប់មកជាមួយនូវឯកសារយោងច្បាប់ដើម (អត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែន...ច្បាប់ដើម) មកជាមួយនឹងទម្រង់សាលាកប័ត្រពត៌មានរបស់ខ្លួន។ ចំណែកកម្មករនិយោជិតដែលចុះបញ្ជីជាមួយក្រុមការងារដែលចុះកំណត់អត្តសញ្ញាណនៅមូលដ្ឋានសហគ្រាស របស់ខ្លួន គឺគ្រាន់តែថតចម្លងឯកសារយោងរបស់ខ្លួនរួចកឹបភ្ជាប់ជាមួយសាលាកប័ត្រពត៌មានរបស់ខ្លួនដើម្បីឱ្យខាងក្រុមការងារដែលចុះកំណត់អត្តសញ្ញាណនោះពិនិត្យជាការស្រេច។

[38] សេចក្តីណែនាំលេខ ៦៩/ ១៥ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០៥ ស្តីពីការចុះបញ្ជិកាកម្មករនិយោជិតមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម

[39] ប្រកាសលេខ៤៤៨ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ប្រការ៨

### ខ.៤. ភាពមិនប្រក្រតីចំពោះការចុះបញ្ជិកា

ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារប៉ុន្មានឆ្នាំមកនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈបេឡាជាតិរបបសន្តិសុខសង្គមបានជួបនូវភាពមិនប្រក្រតី និងបញ្ហាមួយចំនួនក្នុងការចុះបញ្ជីកម្មករនិយោជិត។ បញ្ហាទាំងអស់នោះមានរួមមាន ការខ្ចីឈ្មោះអ្នកដទៃមកប្រើប្រាស់ដើម្បីបានចូលធ្វើការហើយឈានទៅដល់ការយកឈ្មោះរបស់អ្នកដទៃនេះមកធ្វើការចុះបញ្ជិកា ការខុសឈ្មោះ, ការខុសភេទ, ការខុសថ្ងៃខែឆ្នាំកំណើត, ការខុសទីកន្លែងកំណើតជាដើម ដែលអាចបង្កបាតុភាពមិនប្រក្រតីនានា ធ្វើឱ្យភាគីពាក់ព័ន្ធជាពិសេសនិយោជក និងកម្មករនិយោជិតមានការព្រួយបារម្ភចំពោះផលប៉ះពាល់តាមផ្លូវច្បាប់នានា ទាក់ទងទៅនឹងការក្លែងបន្លំឯកសារ, សៀវភៅការងារ, បញ្ជិកាអង្គការវិជ្ជាជីវៈ ការបណ្តេញចេញពីការងារ ការចោទប្រកាន់ចំពោះការប្រើប្រាស់ពលកម្មកុមារ។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងអស់ និងចៀសវាងនូវបាតុភាពជាយថាហេតុ គ្រប់ភាគីពាក់ព័ន្ធត្រូវអនុវត្តដូចខាងក្រោម៖

- មិនត្រូវចាត់ទុកជាកំហុស ចំពោះគ្រប់រូបភាពមិនប្រក្រតីខាងលើកម្មករនិយោជិត
- នៅពេលចុះបញ្ជិកាឡើងវិញនូវកម្មករនិយោជិតទាំងអស់ដែលមានបញ្ហាដូចរៀបរាប់ខាងលើត្រូវបានរក្សានូវសិទ្ធ និងអត្ថប្រយោជន៍ផ្សេងៗដូចជា អតីតភាពការងារ តួនាទីក្នុងអង្គការវិជ្ជាជីវៈ និងកិច្ចសន្យាការងារ
- និយោជក មិនត្រូវបានការចោទប្រកាន់ថាប្រើប្រាស់ពលកម្មកុមារ ចំពោះករណីដែលកម្មករនិយោជិតប្រើប្រាស់អត្តសញ្ញាណប័ណ្ណខុសប្រក្រតីនោះទេ
- កម្មករនិយោជិត ដែលបានការធ្វើនិយ័តកម្មអត្តសញ្ញាណកម្មឱ្យបានត្រឹមត្រូវឡើងវិញមិនតម្រូវឱ្យបង់ថ្លៃសេវាពិត្យកាយសម្បទា, បណ្ណការងារ សៀវភៅការងារ និងបញ្ជិកាអង្គការវិជ្ជាជីវៈ ចំពោះរាល់ការធ្វើនិយ័តកម្មឯកសារនេះឡើងវិញ។
- ក្នុងការជ្រើសរើសកម្មករនិយោជិតថ្មី សហគ្រាស គ្រឹះស្ថានចាំបាច់ត្រូវទាមទារឯកសារបញ្ជាក់អត្តសញ្ញាណរបស់សាមីខ្លួន ដូចជាអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែនឱ្យបានត្រឹមត្រូវ។

នៅក្នុងដំណើការនៃការចុះបញ្ជិកាឡើងវិញ កម្មករនិយោជិត ត្រូវបំពេញសាលាកប័ត្រព័ត៌មាន និងមានឯកសារផ្ទាល់ខ្លួនសំខាន់ដូចជា អត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែន។ ការធ្វើប័ណ្ណថ្មីនេះ គឺដើម្បីទទួលបាននូវប័ណ្ណសម្គាល់ខ្លួនថ្មី ដែលភ្ជាប់ដោយលេខអត្តសញ្ញាណសមាជិក **ប.ស.ស**

ដើម្បីជាមូលដ្ឋានដើម្បីឱ្យខាងសហគ្រាស គ្រឹះស្ថាន រៀបចំបង់ភាគទានសម្រាប់ពួកគាត់មកកាន់ **ប.ស.ស** ដើម្បីឱ្យពួកគាត់ទទួលបាននូវតារកាលិកផ្សេងៗដែលកំណត់ដោយច្បាប់[40]។

**កថាខណ្ឌទី ៣ ភាគទានសម្រាប់របបធានារ៉ាប់រងហានិភ័យការងារ**

**ក. អត្រាភាគទាន**

ដូចជាបានរៀបរាប់ខាងលើមកហើយ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកធានារ៉ាប់រងហានិភ័យការងារនេះ ដំបូងរហូតមកដល់ពេលនេះ គឺអនុវត្តតែសម្រាប់កម្មករនិយោជិតណាដែលបម្រើការនៅតាមសហគ្រាស គ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពី៨ (ប្រាំបី) នាក់ឡើងតែប៉ុណ្ណោះ។

ក្នុងការអនុវត្តរបបសន្តិសុខសង្គមផ្នែកធានារ៉ាប់រងហានិភ័យការងារនេះ អត្រាភាគទានដែលត្រូវបង់ គឺមានចំនួន០,៨ (សូន្យក្បៀសប្រាំបី) ភាគរយ នៃប្រាក់ឈ្នួលមធ្យមជាប់ភាគទាន នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតមុនកាត់ពន្ធ[41] (ប្រាក់ឈ្នួលមធ្យមជាប់ភាគទាន នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតនឹងបង្ហាញក្នុងប្រកាសលេខ៤៩៩។ ចំពោះប្រាក់ឈ្នួលមធ្យមជាប់ភាគទាន (អប្បរមា) ត្រូវបានកំណត់ចាប់ពី២០០០០០ (ពីសែន) រៀលឡើងទៅ គឺមានន័យថាទោះបីប្រាក់ខែរបស់កម្មករនិយោជិតនោះតិចជាង ២០០០០០ (ពីរសែន) រៀលក៏ដោយ ក៏ការគិតភាគទានចាប់ពី២០០០០០ (ម្ភៃម៉ឺន) រៀលដែរ។

**ឧទាហរណ៍៖** លោក **ម៉ុម មករា** ធ្វើការនៅក្នុងរោងចក្រមួយ ដោយក្នុងមួយខែគាត់ទទួលបានប្រាក់ឈ្នួល ១០០ ០០០ (មួយសែន) រៀល ហើយអត្រាបង់ភាគទានគឺ ០,៨ (សូន្យក្បៀសប្រាំបី)ភាគរយ ដូច្នេះចំពោះកម្មករឈ្មោះ **ម៉ុម មករា** នេះ និយោជករបស់គាត់ត្រូវបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារជូនគាត់គឺ ០,៨ % នៃ២០ ០០០០ គឺស្មើនឹង ១ ៦០០រៀល។ ក្នុងករណីដែលសហគ្រាស គ្រឹះស្ថាន បើកប្រាក់ឈ្នួលជារូបិយប័ណ្ណបរទេស ប្រាក់ខែត្រូវគិតជារៀល តាមអត្រាប្តូរប្រាក់របស់ធនាគារជាតិ ដែលជូនដំណឹងដោយ **ប.ស.ស**។

ហើយប្រាក់ឈ្នួលមធ្យមជាប់ភាគទាន (អតិបរមា) គិតត្រឹម ១ ២០០ ០០០ (មួយលានពីរសែន) រៀល ទោះបីប្រាក់ខែរបស់កម្មករនិយោជិតនោះច្រើនជាងនេះក៏ដោយ។

**ឧទាហរណ៍៖** លោក **ម៉ុម កុម្ភះ** ធ្វើការនៅក្រុមហ៊ុនឯកជនមួយ ដោយក្នុងមួយខែគាត់

[40] សេចក្តីជូនដំណឹងលេខ១២៧ កប/ស.ជ.ណ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជិកាកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម

[41] ប្រកាសលេខ៤៩៩ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ វិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារប្រការ ៤

ទទួលបានប្រាក់ឈ្នួល១០ ០០០០ ០០០ (ដប់លាន) រៀល ក៏និយោជកបង់ភាគទានសម្រាប់បុគ្គលឈ្មោះ **ម៉ុម កុម្ភៈ** នេះត្រឹមតែ០,៨ %នៃ ទឹកប្រាក់១ ២០០ ០០០រៀលប៉ុណ្ណោះ គឺស្មើនឹង ៩ ៦០០ រៀលគត់។

ប៉ុន្តែក្នុងករណីដែលនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានខកខានមិនបានបង់ភាគទានតាមកាលបរិច្ឆេទដែលបានកំណត់ដោយក្រសួងការងារទេនោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវបង់នូវការប្រាក់ប្រចាំខែតាមអត្រា ១,៥ (មួយក្បៀស) ភាគរយ នៃចំនួនភាគទានជាក់ស្តែង ដែលត្រូវបង់ក្នុងខែនីមួយៗ និងត្រូវពិន័យជាប្រាក់ថែមទៀតផង[42] ។

គ្រាន់តែចាប់ផ្តើមអនុវត្តបានមួយឆ្នាំ ដោយសារឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចសកល ដែលធ្វើឱ្យម្ចាស់សហគ្រាស គ្រឹះស្ថានធំៗនៅកម្ពុជាពិតជាលំបាក និងជួបបញ្ហាផ្នែកហិរញ្ញវត្ថុ។ ដូច្នេះរាជរដ្ឋាភិបាលកម្ពុជា បានជួយសម្រាលដល់អ្នកវិនិយោគក្នុងផ្នែកកាត់ដេរ និងស្បែកជើង ដែលជាឧស្សាហកម្មមានកម្លាំងពលកម្មច្រើន ដោយកាត់បន្ថយអត្រាភាគទានផ្នែកធានារ៉ាប់រងហានិភ័យការងារពី ០,៨ភាគរយ មកត្រឹម០,៥ភាគរយ សម្រាប់រយៈពេល២ឆ្នាំ គឺចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១០។ ចំណែកឯ០,៣ភាគរយទៀត គឺត្រូវរដ្ឋជាអ្នកបង់ជំនួស។ សរុបទៅ ២ឆ្នាំដែលជួយសម្រាលភាគទាន០,៣ ភាគរយនោះ គឺរដ្ឋចំណាយអស់ថវិកា ៨ ៧១៧ ១៥៥ ៩៥៩ រៀល[43]។ ក្រោយពីឆ្នាំ២០១០មក បន្ទាប់ពីស្ថានភាពសេដ្ឋកិច្ចសកលមានភាពធូរស្រាលវិញ ការបង់ភាគទានក៏ត្រូវអនុវត្តជាធម្មតាដូចមុនគឺ ខាងនិយោជក ត្រូវបង់០,៨% នៃប្រាក់ឈ្នួលមធ្យមជាប់ភាគទាន នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតម្នាក់ៗដដែល។

**ខ. នីតិវិធីនៃការបង់ភាគទាន**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានចូលមកក្នុងគណនីរបស់បេឡាជាតិរបបសន្តិសុខសង្គម ដែលស្ថិតនៅក្នុងធនាគារដែលបានកំណត់ ចាប់ពីឆ្នាំពី២០០៨ មកអាចបង់តាមរយៈដែលមានលេខគណនី ០០១ ១០៩៦៥៨៨៩ ១៨ នៅធនាគារអេស៊ីលីដា ឬសាខារបស់ធនាគារនេះ។ រហូតដល់ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ តាមសេចក្តីជូនដំណឹងលេខ ០០៤/១៩ **ប.ស.ស** បានជម្រាបឱ្យសាធារណជន ជាពិសេសនិយោជក ឬម្ចាស់សហគ្រាសអំពីធនាគារដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស** ដែលមានដូចជាធានាគារកាណាឌីយ៉ា ក.អ ដែលមានលេខគណនី ០០១០ ០០៩៣ ៩៨៣៣៣ និងធនាគារឯកទេសវីង ដែលមានលេខគណនី ៩១១៩។ ដែល

[42] ប្រកាសលេខ៩៩៩ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ វិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារប្រការ ៦

[43] យុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ឆ្នាំ២០១៤-២០១៨ ទំព័រទី២៨ ចំណុចទី១០៩

ការចុះកិច្ចព្រមព្រៀងជាមួយធនាគារទាំងបីនេះ បានធ្វើឱ្យការបង់ភាគទានកាន់តែងាយស្រួលជាងមុន ហើយយើងសង្ឃឹមថានៅថ្ងៃមុខនឹងមានការពង្រីកដៃគូនេះបន្ថែមទៀត។

ក្រោយពីបង់ភាគទាននៅធនាគារដែល បានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស** ទាំងបីខាងលើនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវយកលិខិតប្រកាសឥណទាន (Bank slip) របស់ធនាគារមកកាន់ **ប.ស.ស** ដើម្បីទទួលបាន "លិខិតបញ្ជាក់ការបង់ភាគទាន" ពី **ប.ស.ស**។

និយោជក ឬម្ចាស់គ្រឹះស្ថានត្រូវដាក់ជូនមក **ប.ស.ស** ដើម្បីពិនិត្យនូវ

១. របាយការណ៍ចំនួនកម្មករនិយោជិតដែលប្រើប្រាស់ក្នុងខែនីមួយៗ "ទម្រង់**១.០២**" (របាយការណ៍ត្រូវផ្ញើរជា soft ដោយភ្ជាប់លិខិតអម ដែលចុះហត្ថលេខាដោយ និយោជក ឬតំណាងបញ្ជាក់ពីចំនួនកម្មករនិយោជិតដែលមានសរសេរក្នុង soft នោះ)។

២. លិខិតប្រកាសបង់ភាគទានហានិភ័យការងារ ដែលចុះហត្ថលេខាដោយនិយោជក ឬតំណាង និងមានភ្ជាប់ទម្រង់ ២.០១ (បែបបទបង់ភាគទាន)។ ទម្រង់២.០១ នេះ ត្រូវធ្វើជា soft ដូចមាននៅក្នុងSoftwareរបស់ **ប.ស.ស** ដែលបានផ្តល់ជូន។ (គំរូលិខិតប្រកាសបង់ភាគទានហានិភ័យការងារ ប៉ុន្តែចាប់ពីខែឧសភា ឆ្នាំ២០១៦ទៅ ការបង់ភាគទានធានារ៉ាប់រងហានិភ័យការងារត្រូវបង់រួមជាមួយនឹងរបបថែទាំសុខភាពតែម្តង)។

### គ. កាលបរិច្ឆេទបង់ភាគទាន

កាលបរិច្ឆេទបង់ភាគទាន គឺជាពេលវេលាដែលត្រូវបានកំណត់ឱ្យខាងសហគ្រាស គ្រឹះស្ថានធ្វើការបង់នូវភាគទានផ្នែកធានារ៉ាប់រងហានិភ័យការងារជូនមក **ប.ស.ស**។ ដើម្បីធានាបាននូវតម្លាភាព ការទទួលខុសត្រូវ និងធានានិរន្តរភាពនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ។

កាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទានដំបូង ត្រូវបានកំណត់ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទបានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ដែល**ប.ស.ស**បានចេញវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន។ ការប្រគល់វិញ្ញាបនបត្រនេះត្រូវមានបញ្ជាក់កាលបរិច្ឆេទ ដែលសហគ្រាស គ្រឹះស្ថានបានទទួលពី **ប.ស.ស**។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវបង់ភាគទានផ្នែកហានិភ័យការងារ និងថែទាំសុខភាពក្នុងពេលដំណាលគ្នាសម្រាប់ខែនីមួយៗ យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់[44] ។

**ឧទាហរណ៍៖** សហគ្រាស គ្រឹះស្ថានដែលត្រូវបានចុះបញ្ជិកានៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៨ ត្រូវបង់ភាគទានសម្រាប់ខែធ្នូ ឆ្នាំ២០០៨ ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ យ៉ាងយូរ

[44] ប្រកាសលេខ៤៤៩ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ វិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារប្រការ ៥

ក្នុងករណី ដែលនិយោជក ឬម្ចាស់សហគ្រាសខកខានមិនបានមកបង់ភាគទានតាមកាលបរិច្ឆេទដែលបានកំណត់ដូចកថាខណ្ឌខាងលើ គឺ ត្រូវបង់នៅខែបន្ទាប់ ដោយត្រូវទទួលនូវទណ្ឌកម្មដូចជាៈ ត្រូវបង់ការប្រាក់ប្រចាំខែ តាមអត្រា១,៥ (មួយក្បៀសប្រាំ) ភាគរយនៃចំនួនភាគទានជាក់ស្តែងដែលត្រូវបង់ក្នុងខែនីមួយៗ និងការផាកពិន័យដូចមានចែងក្នុងមាត្រា៦ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ។

## ផ្នែកទី ២ តាវកាលិកហានិភ័យការងារ

### កថាខណ្ឌទី ១ លក្ខខណ្ឌទទួលបានតាវកាលិក

តាវកាលិក គឺជាប្រាក់ វត្ថុ ឬសេវាដែលត្រូវផ្តល់ឱ្យដល់សមាជិក **ប.ស.ស** នៅពេលចាស់ជរាទុព្វលភាព និងនៅពេលទទួលរងហានិភ័យការងារទៅតាមកាលកំណត់មួយ។ ដើម្បីទទួលបាននូវតាវកាលិកនៃហានិភ័យការងារដែលបានចែងក្នុងប្រកាស លេខ១០៩កប/ប្រ.កចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលលិកហានិភ័យការងារ និងប្រកាសលេខ២៣៣ក.ប/ប្រ.កចុះថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាស លេខ១០៩ខាងលើបានលុះត្រាតែពួកគេត្រូវបានទទួលស្គាល់ថាជាកម្មករនិយោជិត ដែលកំពុងបម្រើការងារនៅតាមសហគ្រាសគ្រឹះស្ថានដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម ហើយពួកគេបានជួបនូវឧប្បទេវហេតុដែលត្រូវបានកំណត់ថាជាគ្រោះថ្នាក់ការងារ[45]។

#### ក. ការជូនដំណឹងពីហានិភ័យការងារ

កម្មករនិយោជិតសមាជិកនៃ**ប.ស.ស** ត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬអ្នកតំណាងនិយោជកអំពីហានិភ័យការងារ (គ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជម្ងឺវិជ្ជាជីវៈ) ដែលធ្លាក់មកលើខ្លួន។ ក្នុងករណីដែលមានគ្រោះថ្នាក់បណ្តាលឱ្យបាត់បង់ជីវិត កាតព្វកិច្ចនៃការជូនដំណឹងនេះត្រូវធ្លាក់លើសិទ្ធិវន្តនៃជនរងគ្រោះ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ហើយដែលបានចុះបញ្ជិកានៅក្នុង**ប.ស.ស** ត្រូវជូនដំណឹងទៅ**ប.ស.ស** ក្នុងរយៈពេលយ៉ាងយូរបំផុត ៤៨ (សែសិបប្រាំបី)ម៉ោង នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលដំណឹងអំពីហានិភ័យការងារដែលធ្លាក់មកលើកម្មករនិយោជិតរបស់ខ្លួន។

ករណីគ្រោះថ្នាក់ការងារត្រូវផ្ញើរបាយការណ៍ហានិភ័យការងារ ដោយភ្ជាប់មកជាមួយនឹងឯកសារពាក់ព័ន្ធតាមរយៈសារអេឡិចត្រូនិច benefit@nssf.gov.kh ។

---

[45] ប្រកាសលេខ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ ប្រការ ១

ទម្រង់របាយការណ៍ហានិភ័យការងារ មានក្នុងឧបសម្ព័ន្ធនៃប្រកាសរួម លេខ១១០ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីការជូនដំណឹងហានិភ័យការងារ។

ខាងក្រោមនេះ គឺជាគំនូសតាងនៃនីតិវិធីនៃការជូនដំណឹងអំពីហានិភ័យការងារ




**ខ. ការអង្កេតគ្រោះថ្នាក់ការងារ**

បន្ទាប់ពីទទួលបានរបាយការណ៍ពីការទាមទារសំណងហានិភ័យការងារ ការិយាល័យតាវកាលិក ឬការិយាល័យខេត្ត ខណ្ឌ/ ក្រុងនៃ**ប.ស.ស** ត្រូវជូនដំណឹងទៅការិយាល័យអធិការកិច្ច និងកិច្ចការនីតិកម្ម ដើម្បីចាត់អធិការ ឬអភិបាលរបបសន្តិសុខសង្គមធ្វើការអង្កេតនិងផ្ដល់លទ្ធផលលើករណីនីមួយៗមកការិយាល័យតាវកាលិកវិញឱ្យបានយ៉ាងឆាប់បំផុត។

ដើម្បីបំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព អធិការ ឬអភិបាលរបបសន្តិសុខសង្គមអាចស្នើសុំព័ត៌មានទាក់ទងនឹងទីកន្លែង ពេលវេលា មូលហេតុនៃគ្រោះថ្នាក់ពីសាក្សី ឬអាជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែងកើតហេតុ[46]។

ក្នុងករណីដែលការងារអធិការកិច្ច ឬការអង្កេតមានភាពស្មុគស្មាញ និងក្នុងករណីចាំបាច់បន្ទាប់ពីមានការអនុញ្ញាតពីនាយកនៃ**ប.ស.ស** អធិការ ឬអភិបាលរបបសន្តិសុខសង្គមអាចស្នើសុំជំនួយពីអធិការការងារ ឬអធិការពេទ្យការងារ ឬ អ្នកជំនាញការ និងអ្នកបច្ចេកទេសមានសមត្ថភាពពិតប្រាកដពីក្រសួងពាក់ព័ន្ធ ឬខាងក្រៅ ដូចជាខាងវេជ្ជសាស្ត្រ ខាងយន្តសាស្ត្រ ខាងអគ្គីសនី ខាងគីមី ឬខាងបរិស្ថានជាដើម ដើម្បីពិនិត្យឱ្យបានហ្មត់ចត់អំពីមូលហេតុនៃគ្រោះថ្នាក់នេះ។ ការចំណាយទាំងអស់ខាងលើជាបន្ទុករបស់**ប.ស.ស**[47]។

---

[46] ប្រកាសលេខ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីតាវកាលិកហានិភ័យការងារ ប្រការ ៣

[47] ប្រកាសលេខ០៨១/០៩ កប/ប្រក៩.កចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការកំណត់តួនាទី ភារកិច្ចរបស់អធិការ និងអភិបាលរបបសន្តិសុខសង្គមនៃបេឡាជាតិរបបសន្តិសុខសង្គម ប្រការ ៥

ផ្អែកលើលក្ខខណ្ឌនៃគ្រោះថ្នាក់ អធិការ ឬអភិបាលរបបសន្តិសុខសង្គម អាចដកហូត ឬដកយកវត្ថុធាតុឬសារធាតុប្រើប្រាស់ ឬវត្ថុលាយដើម្បីផ្តល់ជូននូវអ្នកជំនាញធ្វើការវិភាគដើម្បីការងារតែប៉ុណ្ណោះ។

អធិការ ឬអភិបាលរបបសន្តិសុខសង្គមត្រូវធ្វើកំណត់ហេតុអង្កេតគ្រោះថ្នាក់ការងារមួយ ដែលមានលក្ខណៈអាចឆ្លើយតបនឹងពត៌មានគ្រប់ជ្រុងជ្រោយសម្រាប់ការវាយតម្លៃ[48]ដើម្បីផ្ញើរបាយការណ៍ត្រឡប់ទៅការិយាល័យតាវកាលិក ដើម្បីចាត់ចែងផ្តល់តាវកាលិក។

យោងតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ឆ្នាំ២០០២ មាត្រា១៥ បានកំណត់នូវតាវកាលិកនៃហានិភ័យការងារជាបួនផ្នែកសំខាន់ៗគឺៈ ការថែទាំ និងព្យាបាល ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃ ការផ្តល់ប្រាក់ធនលាភ ឬប្រាក់វិភាជន៍ និងការផ្តល់ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព និងធនលាភឧត្តរជីវីនៃជនរងគ្រោះ។

បន្ថែមពីនេះ ប្រកាស លេខ១០៩ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារក៏បាននិយាយផងដែរអំពីការផ្តល់សេវាសង្គ្រោះបន្ទាន់ ការថែទាំ និងព្យាបាល ប្រាក់បំណាច់ប្រចាំថ្ងៃ ប្រាក់បន្ថែមសម្រាប់អ្នកថែរក្សាជនរងគ្រោះ សោហ៊ុយបូជាសព តាវកាលិកឧត្តរជីវី និងសេវាបុននីតិសម្បទា។

ដូច្នេះតាវកាលិកត្រូវបានចាត់ថ្នាក់ជាពីរក្រុម គឺទី ១ ជាតាវកាលិកក្នុងករណីដែលគ្រោះថ្នាក់ការងារបង្កឱ្យកម្មករនិយោជិតបាត់បង់សមត្ថភាពជាបណ្តោះអាសន្ន និងទី ២ ជាតាវកាលិកក្នុងករណីដែលគ្រោះថ្នាក់ការងារនោះ ដែលបានបណ្តាលឱ្យកម្មករនិយោជិតគាត់បាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ឬរហូតដល់បាត់បង់ជីវិត។

### កថាខណ្ឌទី ២ តាវកាលិកចំពោះការបាត់បង់សមត្ថភាពការងារជាបណ្តោះអាសន្ន

បន្ទាប់ពីកើតមានគ្រោះថ្នាក់ការងារលើកម្មករនិយោជិត សាមីខ្លួន ឬនិយោជកត្រូវបញ្ជូនកម្មករនិយោជិតមកព្យាបាលនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។ ប៉ុន្តែក្នុងករណីសង្គ្រោះបន្ទាន់ និយោជកត្រូវផ្តល់ការសង្គ្រោះ ឬបញ្ជូនទៅសង្គ្រោះដែលនៅជិតបំផុត និងបន្ទាប់មកត្រូវមកបញ្ជូនមកមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គមវិញ។ មិនថាការទូទាត់សង្គ្រោះបន្ទាន់ ឬការគ្រោះថ្នាក់នៅ
ពេលធ្វើដំណើរការទាមទារសំណង និងថ្លៃដឹកជញ្ជូន គឺជាបន្ទុករបស់ (**ប.ស.ស**) ទាំងអស់[49]។

---

[48] ប្រកាសលេខ០៨១/០៩ កប/ប្រក៥.កចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ស្តីពីការកំណត់តួនាទី ភារកិច្ចរបស់អធិការ និងអភិបាលរបបសន្តិសុខសង្គមនៃបេឡាជាតិរបបសន្តិសុខសង្គម ប្រការ ៤

[49] ប្រកាសលេខ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ ប្រការ ៤ និង៥

**ក. ការផ្តល់សេវាថែទាំ និងព្យាបាល**

ការព្យាបាលចំពោះកម្មករនិយោជិតដែលរងគ្រោះថ្នាក់ការងារត្រូវប្រព្រឹត្តទៅនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។ សេវា និងការផ្គត់ផ្គង់ទាំងនោះរួមមាន៖

១. ការជួយរ៉ាប់រងក្នុងការព្យាបាល ការវះកាត់ កិច្ចការទន្តសាស្ត្រ ព្រមទាំងការពិនិត្យដោយវិទ្យុរស្មីX ការពិនិត្យរបស់មន្ទីរពិសោធន៍ និងការវិភាគផ្សេងៗ។

២. ការផ្គត់ផ្គង់ឱសថសម្រាប់ព្យាបាល និងសម្ភារៈប្រើប្រាស់បន្ទាប់បន្សំសម្រាប់ការព្យាបាល។ បើសិនជាគ្រូពេទ្យតម្រូវឱ្យទិញឱសថ ឬសម្ភារៈឧបករណ៍សម្រាប់គាំទ្រការព្យាបាលដែលពុំមាននៅក្នុងកិច្ចព្រមព្រៀងនោះ បេឡាជាតិរបបសន្តិសុខសង្គមនឹងទូទាត់សងវិញទៅជនរងគ្រោះ ឬអ្នកតំណាងវិញ លុះត្រាតែមានវេជ្ជបញ្ជា និងវិក័យប័ត្រត្រឹមត្រូវ។

៣. ការដឹកជនរងគ្រោះពីកន្លែងគ្រោះថ្នាក់មកមន្ទីរពេទ្យ និងទៅកាន់លំនៅដ្ឋានក៏ត្រូវបានរាប់បញ្ចូលតារលិកនេះផងដែរ។

៤. ប្រសិនបើការព្យាបាលនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលផ្សេងក្រៅពីការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម ការទូទាត់សងវិញត្រូវធ្វើការអត្រាតម្លៃដែលបេឡាជាតិរបបសន្តិសុខសង្គមបានកំណត់[50]។

**ខ. ការឧបត្ថម្ភប្រាក់បំណាច់ប្រចាំថ្ងៃ**

ក្នុងករណីដែលមាន ការបាត់បង់សមត្ថភាពការងារជាបណ្តោះអាសន្នដោយមានការបញ្ជាក់យ៉ាងត្រឹមត្រូវពីគ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យដែលទទួលស្គាល់ដោយ **ប.ស.ស** អ្នករងគ្រោះមានសិទ្ធិទទួលបាននូវប្រាក់បំណាច់ប្រចាំថ្ងៃដោយគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទកើតឧបទេវហេតុគ្រោះថ្នាក់ការងាររហូតដល់មុខរបួសជាសះស្បើយតាមវេជ្ជបញ្ជា ឬដល់ថ្ងៃជនរងគ្រោះទទួលមរណភាព។

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារជាបណ្តោះអាសន្ន ត្រូវផ្តល់ចំពោះតែហានិភ័យការងារដែលតម្រូវឱ្យសម្រាកព្យាបាលលើសពី០៤ (បួន) ថ្ងៃឡើងទៅ។
ចំនួនប្រាក់បំណាចប្រចាំថ្ងៃនេះ គឺមានចំនួនស្មើនឹង ៧០ (ចិតសិប) ភាគរយនៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ។ ក្នុងករណីដែលគ្រោះថ្នាក់ធ្ងន់ធ្ងរដែលតម្រូវឱ្យមានអ្នកថែទាំនោះ អ្នកថែទាំជនរងគ្រោះអាចទទួលបាន៥០ (ហាសិប) ភាគរយនៃប្រាក់ធនលាភប្រចាំថ្ងៃ ឬប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ[51]។

[50] ប្រកាសលេខ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតារកាលិកហានិភ័យការងារ ប្រការ១៤ ចំណុច១

ប្រាក់ឈ្នួលមធ្យម គឺជាផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទានរយៈពេល ០៦ (ប្រាំមួយ) ខែមុនកាលបរិច្ឆេទគ្រោះថ្នាក់ការងារ។ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែកនៃប្រាក់ឈ្នួលមធ្យមនឹង ៣០ (សាមសិប) ថ្ងៃ។

**គ. បែបបទនៃការទាមទារ**

ការទាមទារតាវកាលិកសម្រាប់ការថែទាំ និងព្យាបាល អាចត្រូវបានធ្វើឡើងដោយមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលព្យាបាលជនរងគ្រោះ ឬនិយោជក ឬក៏ជនរងគ្រោះផ្ទាល់តាមទម្រង់ "**តាវកាលិកថែទាំ និងព្យាបាល**" ឬទម្រង់ "**៣.០២**"។

ការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារជាបណ្តោះអាសន្ន ត្រូវធ្វើដោយជនរងគ្រោះ ឬអ្នកតំណាងតាមទម្រង់"**តាវកាលិកបាត់បង់សមត្ថភាពការងារជាបណ្តោះអាសន្ន**" ឬ ទម្រង់"**៣.០៣**"។

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារជាបណ្តោះអាសន្ន អាចផ្តល់ជូនជនរងគ្រោះដោយហានិភ័យការងារ ក្នុងរយៈពេលយ៉ាងយូរបំផុត ១៨០ (មួយរយប៉ែតសិប) ថ្ងៃ[52]។

**កថាខណ្ឌទី ៣ ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ និងបាត់បង់ជីវិត**

**ក. តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍**

ចំពោះកម្មករនិយោជិតណាដែលទទួលរងនូវហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍នូវផ្នែកណាមួយ ឬទាំងស្រុងនៃសរីរាង្គ។

**ក.១. ប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ**

ក្នុងករណីដែលកម្មករនិយោជិតទទួលរងនូវហានិភ័យការងារតិចជា ២០ (ម្ភៃ) ភាគរយ មានសិទ្ធិទទួលបាននូវប្រាក់វិភាជន៍ផ្តល់ជូនជនរងគ្រោះតែម្តងគត់ ដោយគិតតាមរូបមន្តដូចខាងក្រោម៖

**វបក = បឈម x កបក x ២០%មតប**

ដោយ:

| | |
|---|---|
| **វបក:** | វិភាជន៍បាត់បង់សមត្ថភាពការងារ |
| **បឈម:** | ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ |
| **កបក:** | កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ |
| **មតប:** | មេគុណតម្លៃបច្ចុប្បន្ន |

[51] ប្រកាសលេខ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ ប្រការ ៧ និងច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ឆ្នាំ ២០០២ មាត្រា១៧

[52] ប្រកាសលេខ២៣៣ កប/ប្រ.ក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលប្រការ ៨ និងប្រការ១០នៃ ប្រកាសលេខ១០៩ ស្តីពីតាវកាលិកហានិភ័យការងារ

ទោះបីជាសមាជិក **ប.ស.ស** (កម្មករនិយោជិត) ដែលកំពុងទទួលប្រាក់វិភាជន៍ដោយការបាត់បង់សមត្ថភាពការងារ ប៉ុន្តែត្រូវរងនូវហានិភ័យការងារថ្មីដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារយ៉ាងតិច ២០ (ម្ភៃ) ភាគរយ ជននេះមានសិទ្ធិទទួលបាននូវប្រាក់ធនលាភតាមកម្រិតនៃការបាត់បង់សមត្ថភាពការងារជាក់ស្តែងរបស់ខ្លួន។ បើនៅពេលរងគ្រោះថ្នាក់លើកក្រោយនេះ អ្នករងគ្រោះទទួបាលប្រាក់ឈ្នួលមធ្យមខ្ពស់ជាងមុន ត្រូវយកប្រាក់ឈ្នួលនេះសម្រាប់ការគណនាប្រាក់ធនលាភថ្មីផងដែរ[53]។

**ក.២. ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ**

កម្មករនិយោជិតដែលទទួលរងនូវហានិភ័យការងារ ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារចាប់ពី២០ (ម្ភៃ) ភាគរយឡើងមានសិទ្ធិទទួលបានប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍នោះ។ ប្រាក់ធនលាភនេះត្រូវគិតតាមរូបមន្តៈ

**ធល = បឈម x [កបក - ១/៥កបក]**

**ធលៈ** តាងឱ្យប្រាក់ធនលាភ

ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំដោយអនុលោមតាមអត្រាអតិផរណា ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ត្រូវបានចាត់ទុកជាបណ្តោះអាសន្នជានិច្ច។ បេឡាជាតិរបបសន្តិសុខសង្គមត្រូវរៀបចំឱ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងារ ជនរងគ្រោះឡើងវិញក្នុងរយៈពេល ០១ (មួយ) ឆ្នាំ យ៉ាងយូរ។ ជនរងគ្រោះមានកាតព្វកិច្ចមកពិនិត្យសុខភាព តាមការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម[54]។

ក្នុងករណីដែលសមាជិក **ប.ស.ស** (កម្មករនិយោជិត) បានទទួលប្រាក់ធនលាភដោយការបាត់បង់សមត្ថភាពការងារដោយផ្នែក ប៉ុន្តែត្រូវរងនូវហានិភ័យការងារថ្មីម្តងទៀត ត្រូវមានការគិតគូរឡើងវិញនូវចំនួនទឹកប្រាក់ធនលាភថ្មី ដោយផ្អែកលើកម្រិតនៃការបាត់បង់សមត្ថភាពការងារថ្មីនេះ។ ទោះជាយ៉ាងនេះក៏ដោយ បើក្នុងពេលរងគ្រោះថ្នាក់ខាងក្រោយនេះ អ្នករងគ្រោះទទួលប្រាក់ឈ្នួលមធ្យមខ្ពស់ជាងមុនត្រូវយកប្រាក់ឈ្នួលនេះសម្រាប់ជាមូលដ្ឋានក្នុងការគណនាប្រាក់ធនលាភថ្មី។

ក្នុងករណីដែលសមាជិក**ប.ស.ស** (កម្មករនិយោជិត) ទទួលរងនូវហានិភ័យការងារបណ្តាល

[53] ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ឆ្នាំ២០០២ មាត្រា២១ ចំណុចទី២

[54] ប្រកាសលេខ២៣៣ ក.ប/ ប្រ.ក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលប្រការ៨ និង១០ នៃប្រកាសលេខ ១០៩ ស្តីពីតាវកាលិកហានិភ័យការងារ

ឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ក្នុងកម្រិត ១០០ (មួយរយ) ភាគរយ នោះមានសិទ្ធិទទួលបានប្រាក់បន្ថែមសម្រាប់អ្នកថែរក្សាដល់ខ្លួន (អ្នករងគ្រោះ) ។ ប្រាក់បន្ថែមសម្រាប់អ្នកថែរក្សាត្រូវស្មើនឹង ៥០ (ហាសិប) ភាគរយ នៃប្រាក់ធនលាភរបស់ជនរងគ្រោះ។

និយាយជារួម កម្រិតនៃការបាត់បង់សមត្ថភាពអចិន្ត្រៃយ៍ ត្រូវកំណត់ដោយ**ប្រកាសលេខ ១០៩ ស្តីពីតាកាលិក និង ប្រកាសលេខ២៣៣ ស្តីពីការកែសម្រួលប្រកាសលេខ១០៩ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**។

### ក.៣. សេវាបុននីតិសម្បទា

កម្មករនិយោជិតដែលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានឧបករណ៍ ឬអវៈយវៈសិប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

លើសពីការផ្តល់ឱ្យនូវឧបករណ៍ សិប្បនិម្មិត កម្មករនិយោជិតដែលទទួលគ្រោះថ្នាក់នោះមានសិទ្ធិទទួលបាននូវការសម្រួលមុខងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ស្របតាមលក្ខខណ្ឌដែលកំណត់ដោយឡែកផ្សេងទៀត របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ[55]។

## ខ. តាវកាលិកសម្រាប់ការបាត់បង់ជីវិតដោយហានិភ័យការងារ

ដូចក្នុងមាត្រា១២ នៃច្បាប់ស្តីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ បានចែងថា ក្នុងករណីមាន ហានិភ័យការងាររហូតបណ្តាលឱ្យជនរងគ្រោះបាត់បង់ជីវិត បេឡាជាតិរបបសន្តិសុខសង្គមត្រូវផ្តល់ប្រាក់វិភាជន៍សម្រាប់ជាសោហ៊ុយបូជាសព និងប្រាក់ធនលាភចំពោះអ្នកសិទ្ធិវន្តនៃជនរងគ្រោះ។

### ខ.១. សោហ៊ុយបូជាសព

មុនប្រកាស លេខ២៣៣ ស្តីពីការកែសម្រួលតាវកាលិកហានិភ័យការងារ វិភាជន៍សោហ៊ុយបូជាសពត្រូវបានផ្តល់ជូនត្រឹមតែ ១ ០០០ ០០០ (មួយលាន) រៀលប៉ុណ្ណោះ។ ដោយសារកត្តាសេដ្ឋកិច្ចជាតិមានការរីកចម្រើន និងលទ្ធភាពរបស់**ប.ស.ស** ប្រាក់វិភាជន៍សោហ៊ុយបូជាសពបានកើនដល់រហូតដល់ ៤ ០០០ ០០០ រៀល។ ថ្វីត្បិតតែវាមិនច្រើនប៉ុន្មាន តែវាក៏បានកើនច្រើនជាងមុនបន្តិច ដែលអាចសម្រាលបន្ទុកក្នុងការចាត់ចែងបុណ្យសពរបស់ជនរងគ្រោះបានមួយកម្រិតទៀត។

ប្រាក់នេះ ត្រូវផ្តល់ជូនជនដែលទទួលបន្ទុកក្នុងការរៀបចំ ចាត់ចែងបូជាសពតែហើយការទាមទារប្រាក់វិភាជន៍នេះផងដែរ មានសុពលភាពត្រឹមតែរយៈពេល ០១ (មួយ)ឆ្នាំប៉ុណ្ណោះ ដោយត្រូវធ្វើតាមទម្រង់ "**វិភាជន៍បូជាសព**" ឬ ទម្រង់ "**៣.០៦**" នៃ**ប្រកាសលេខ១០៩** នេះ[56]។

[55] ប្រកាសលេខ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ ប្រការ១២

[56] ប្រកាសលេខ២៣៣ កប/ប្រ.ក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលប្រកាសលេខ១០៩ ស្តីពីតាវកាលិក

### ខ.២. គារកាលិកឧត្តរជីវី

គារវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្តល់ឱ្យសិទ្ធិវន្ត ឬឧត្តរជីវីនៃជនរងគ្រោះ។ ដូចមានក្នុងមាត្រ ៣៣ នៃអនុក្រឹត្យបង្កើតបេឡាជាតិរបបសន្តិសុខសង្គម សិទ្ធិវន្តដែលត្រូវទទួលបាន "គារវកាលិកឧត្តរជីវី" ត្រូវកំណត់ដូចខាងក្រោម៖

- ប្រពន្ធ ឬប្តី មិនមានការលែងលះ ឬក៏បែកបាក់គ្នា បានរៀបការពេញច្បាប់ដោយមានការចុះបញ្ជីអត្រានុកូលដ្ឋានមុនពេលមានគ្រោះថ្នាក់ ឬមុនពេលជនរងគ្រោះការងារនៃប្តី ឬប្រពន្ធដែលជាសមាជិកនៃប.ស.ស ។
- កូនដែលមានអាយុត្រឹម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ និងមានស្ថានភាពដូចខាងក្រោម:
    - កូននៃសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវ។ ក្នុងករណីមានការលែងលះ ឬករណីមរណៈភាពនៃប្តី ឬប្រពន្ធ កូននៃអាពាហ៍ពិពាហ៍ក្រោយក៏មានសិទ្ធិ ដូចកូននៃអាពាហ៍ពិពាហ៍ទី ១ដែរ
    - កូនចិញ្ចឹមរបស់សមាជិក **ប.ស.ស** ។ ស្ថានភាពរបស់កូនចិញ្ចឹមត្រូវកំណត់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អាយុកូននៅក្នុងបន្ទុកអាចកំណត់ដល់អាយុ ២១ (ម្ភៃមួយ)ឆ្នាំចំពោះកូនដែលបានកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ កូនកំពុងរៀននៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ឬឯកជនដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច និងមានលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ និងកូនពិការ ឬមានជម្ងឺរ៉ាំរ៉ៃមិនមានលទ្ធភាពធ្វើការងារដែលមានប្រាក់ឈ្នួល។

- ឪពុកម្តាយ ឬមនុស្សចាស់ជរាដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់សមាជិក**ប.ស.ស** ។

ហើយគារវកាលិកឧត្តរជីវីនេះ នឹងត្រូវផ្តល់ទៅឱ្យសិទ្ធិវន្តតាមអត្រាដូចខាងក្រោម៖

- ករណីដែលសិទ្ធិវន្ត រួមមានទាំងប្តី ឬប្រពន្ធ កូន និងឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក
    - ប្រពន្ធ ឬប្តី = ៣/៥ x ៦៣%បឈម
    - ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៦៣%បឈម
    - ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក = ៧%បឈម
- ក្នុងករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្តី និងឬកូន
    - ប្រពន្ធ ឬប្តី = ៣/៥ x ៧០%បឈម
    - ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៧០%បឈម
- ក្នុងករណីដែលសិទ្ធិវន្តមានតែឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក

– ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក ២៨%បឈម

- ក្នុងការណីសិទ្ធិវន្តមានតែកូន និងឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក
  – ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២៨%បឈម
  – ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម
- ក្នុងករណីសិទ្ធិវន្តមានតែប្តី/ប្រពន្ធ និងឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក
  – ប្រពន្ធ ឬប្តី = ២៨%បឈម
  – ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម។

សិទ្ធិទទួលបានធនលាភនៃសិទ្ធិវន្តត្រូវបានរំលាយនៅពេលដែលសាមីជនទទួលមរណៈភាព[57]។

ការអនុវត្តរបបសន្តិសុខសង្គមផ្នែកធានារ៉ាប់រងហានិភ័យការងារគឺជាជំហានដំបូងបង្អស់នៃការចេញដំណើររបស់ខ្លួនរបស់បេឡាជាតិរបបសន្តិសុខសង្គម។ ចាប់តាំងពីឆ្នាំ២០០៨ រហូតដល់បច្ចុប្បន្នការអនុវត្តនេះបានជួបការលំបាកខ្លះៗ ដោយសារតែឥទ្ធិពលទាំងក្នុង និងក្រៅប្រទេស ប៉ុន្តែបញ្ហាភាគច្រើនត្រូវបានដោះស្រាយជាបន្តបន្ទាប់ នេះក៏ដោយសារតែមានការជួយជ្រោមជ្រែងទាំងផ្នែកនយោបាយ និងហិរញ្ញវត្ថុពីរាជរដ្ឋាភិបាល។ បន្ទាប់ពីការខិតខំប្រឹងប្រែងក្នុងការអនុវត្តរបបសន្តិសង្គមផ្នែកធានារ៉ាប់រងហានិភ័យការងាររួចមកបេឡាជាតិរបបសន្តិសុខសង្គមក៏បានបន្តដំណើររបស់ខ្លួនទៅអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពជាបន្តទៀតនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៦។

[57] ប្រកាសលេខ១០៩ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ ប្រការ១១

# ជំពូកទី ៣
# ការអនុវត្តរបបថែទាំសុខភាព

# ជំពូកទី ៣
# ការអនុវត្តរបបថែទាំសុខភាព

របបថែទាំសុខភាព គឺជាយន្តការនៃការជួយសម្រាលបន្ទុករបស់ជនដែលជាគោលដៅដូចជាកម្មករនិយោជិត មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជននៅពេលដែលពួកគេមានបញ្ហាផ្នែកសុខភាព។

ក្នុងដំណាក់កាលដំបូងនៃការអនុវត្តរបបថែទាំសុខភាពនេះ គឺត្រូវកំណត់គោលដៅទៅលើជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារតែប៉ុណ្ណោះ មុននឹងឈានទៅដល់ការអនុវត្តចំពោះមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

របបធានាថែទាំសុខភាពនេះ ត្រូវបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលហើយរៀបចំដាក់ឱ្យដំណើរការនាឆ្នាំ២០១៤។ ដោយសារតែមើលឃើញពីស្ថានភាពសុខភាពរបស់កម្មករនិយោជិតនាប៉ុន្មានឆ្នាំចុងក្រោយនេះមានបាតុភាពករណីដួលសន្លប់នៅក្នុងសហគ្រាស គ្រឹះស្ថានមួយចំនួនដែលនៅឆ្នាំ២០១៣កន្លងទៅមានប្រមាណជា០៤ (បួន)ភាគរយនៃគ្រោះថ្នាក់ការងារ ដែលមួយចំនួនធំមានបញ្ហាពាក់ព័ន្ធនឹងសុខភាព និងរបបអាហាររបស់កម្មករនិយោជិតផ្ទាល់ ជាពិសេសទម្លាប់នៃការរស់នៅខ្វះអនាម័យ ការសន្សំសំចៃ និងការមិនហ៊ានទៅរកសេវាវេជ្ជសាស្ត្រព្រោះមានតម្លៃខ្ពស់។

ស្ថានភាពនេះ ធ្វើឱ្យមានការព្រួយបារម្ភយ៉ាខ្លាំង ចំពោះជីវភាពរស់នៅរបស់កម្មករនិយោជិតដែលរងគ្រោះ ដែលត្រូវទទួលបន្ទុកចំណាយការព្យាបាលរបស់ខ្លួន ហើយវានឹងប៉ះពាល់ខ្លាំងថែមទៀត ប្រសិនបើគ្រោះថ្នាក់ ឬបញ្ហាសុខភាពរហូតដល់បាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ឬបាត់បង់ជីវិតនោះ គ្រួសាររបស់ជនរងគ្រោះ និងសង្គមជាតិទាំងមូលដែលត្រូវទទួលបន្ទុកជនពិការ ក្មេងកំព្រា និងចាស់ជរាក្នុងបន្ទុក[58]។

ដើម្បីឆ្លើយតបនឹងបញ្ហានេះ រាជរដ្ឋាភិបាលក៏បានរៀបចំនូវយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ការចុះបញ្ជិកាសមាជិក ការផ្តល់តាវកាលិក យន្តការនៃការទូទាត់ថ្លៃសេវាសុខាភិបាល និងលិខិតបទដ្ឋានដែលពាក់ព័ន្ធមួយចំនួនទៀត។

ក្នុងការអនុវត្តរបបថែទាំសុខភាព បេឡាជាតិរបបសន្តិសុខសង្គមមិនមែនមានភារកិច្ចគ្រប់គ្រងតែទៅលើកម្មករនិយោជិតតែប៉ុណ្ណោះទេ។ បេឡាជាតិរបបសន្តិសុខសង្គមត្រូវបានរាជរដ្ឋាភិបាលប្រគល់ភារកិច្ចថែមទៀត គឺការទទួលខុសត្រូវក្នុងការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនផងដែរ។ ហើយការអនុវត្ត ការផ្តល់

[58] យុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ទំព័រ៣១ និង ៣២

តាវកាលិកក៏មានលក្ខណៈខុសគ្នាពីជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារមួយចំនួនផងដែរ។

## ផ្នែកទី ១ របបថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

### កថាខណ្ឌទី ១ សាវតា

ដូចក្នុងការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារដែរ ការអនុវត្តរបបថែទាំសុខភាព ត្រូវបានចាប់អារម្មណ៍តាំងពីឆ្នាំ២០០៩ ដោយរាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឱ្យអង្គការ "GRET" របស់បារាំងអនុវត្តគម្រោងធានារ៉ាប់រងសុខភាព"HIP" ដៃគូជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា"(GMAC)" ផ្តល់ជំនួយដោយទីភ្នាក់ងារអភិវឌ្ឍន៍បារាំង"AFD" ចាប់ផ្តើមអនុវត្តសាកល្បងលើគម្រោងធានារ៉ាប់រងសុខភាពកម្មកររោងចក្រកាត់ដេរ។

ដោយមើលឃើញពីបញ្ហានេះ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់ចំណារឯកភាពចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១១ ឱ្យមានការរៀបចំការអនុវត្តរបបថែទាំសុខភាពដើម្បីលើកកម្ពស់សុខភាពកម្មករនិយោជិត។ ជាលទ្ធផលនៃកិច្ចសហប្រតិបត្តិការគម្រោងធានារ៉ាប់រងសុខភាព"HIP" ដែលមានរោងចក្រចំនួន១១ និងកម្មករនិយោជិតចំនួន ៧ ២០០នាក់បានកាត់បញ្ចូលមកឱ្យបេឡាជាតិរបបសន្តិសុខសង្គមគ្រប់គ្រងនៅឆ្នាំ២០១៣[59]។

ក្រោមកិច្ចខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ធ្វើឱ្យមានការវិវត្តជាវិជ្ជមាន។ របបថែទាំសុខភាពត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការនៅឆ្នាំ២០១៦តាមរយៈអនុក្រឹត្យ លេខ០១អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការការងារ និងលម្អិតដោយប្រកាសលេខ ០៩៣/១៩ ក.ប/ប្រ.ក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការ អនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព។

ដោយការអនុវត្តដោយចាប់ផ្តើមចេញពីភូមិសាស្ត្ររាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងឈានទៅកាន់ខេត្តដទៃទៀតស្របតាមស្ថានភាពបច្ចេកទេស និងភូមិសាស្ត្រជាក់ស្តែង។ ហើយត្រូវចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦ តទៅ[60] ។

[59] យុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ទំព័រ៣៣ ដល់ ៣៥

[60] ប្រកាសលេខ០៩៣/១៩ ក.ប/ប្រ.ក ចុះថ្ងៃទី០៧ ខែ មីនា ឆ្នាំ ២០១៦ ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ប្រការ ៤

តពីការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ ដល់របបថែទាំសុខភាពដែលការងារបញ្ជិកាកម្មករនិយោជិតត្រូវបានផ្លាស់ប្តូរក្នុងន័យដើម្បីពង្រឹងការកំណត់អត្តសញ្ញាណរបស់សមាជិក**ប.ស.ស** ដើម្បីឱ្យការផ្តល់នូវតាវកាលិកកាន់តែចំគោលដៅ និងមានប្រសិទ្ធភាព។

**កថាខណ្ឌទី ២ ការចុះបញ្ជិកាកម្មករនិយោជិត និងការបង់ភាគទាន**

**ក. ការចុះបញ្ជិកាសមាជិក ប.ស.ស**

ក្រោយពីប្រកាស លេខ០៩៣ ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចូលជាធរមាន។ ការអនុវត្តរបបថែទាំសុខភាព បានប្រើប្រាស់យន្តការដែលមានស្រាប់ពីការអនុវត្តរបបហានិភ័យការងារខ្លះដូចជាការផ្សព្វផ្សាយពីគោលនយោបាយ និងការធ្វើអធិការកិច្ចតាមសហគ្រាសជាដើម។ ប៉ុន្តែការចុះបញ្ជិកាកម្មករនិយោជិត ឬសមាជិក**ប.ស.ស** ត្រូវបានកែប្រែទាំងស្រុង ដូចបានរៀបរាប់នៅ "**កថាខណ្ឌទី ២ ចំណុច ខ នៃជំពូកទី ២**" ម្តងរួចហើយ។

តាមរយៈ**សេចក្តីជូនដំណឹង លេខ១២៧ ក.ប/ស.ជ.ណ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជិកាកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម** មានការចុះបញ្ជិកាកម្មករនិយោជិតមកចុះនៅស្នាក់ការ**ប.ស.ស** ឬ ចុះបញ្ជិកាជាមួយក្រុមការងារកំណត់អត្តសញ្ញាណកម្មករនិយោជិតរបស់**ប.ស.ស** ដែលចុះដល់មូលដ្ឋានសហគ្រាស គ្រឹះស្ថានដែលពួកគេកំពុងបម្រើការនោះតែម្តង ប៉ុន្តែតាមពិតទៅការចុះបញ្ជីបែបទំនើបកម្មថ្មីនេះបានចាប់ផ្តើមតាំងពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៥មកម្លេះ។

ការចុះបញ្ជិកានៅតាមស្នាក់ការបេឡាជាតិរបបសន្តិសុខសង្គមដោយផ្ទាល់ គឺជាការមកចុះបញ្ជិកាដោយប្រើប្រតិបត្តិការដោយផ្ទាល់ទៅលើប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជិកា និងភាគទានដោយផ្ទាល់(ONLINE REGISTATION)។ តាមរយៈការចុះបញ្ជិកាបែបនេះ គឺកម្មករនិយោជិតទាំងអស់នឹងទទួលបានលេខអត្តសញ្ញាណសមាជិក**ប.ស.ស**ភ្លាម រួមជាមួយនឹងកាតនោះផងដែរ (ការទទួលបានកាតភ្លាមៗ គឺសម្រាប់តែការចុះបញ្ជិកានៅស្នាក់ការការិយាល័យបញ្ជិកា និងភាគទាននៃបេឡាជាតិរបបសន្តិសុខសង្គមតែប៉ុណ្ណោះ ចំណែកឯការចុះបញ្ជិកានៅតាមការិយាល័យសាខាខេត្ត ឬខណ្ឌនឹងត្រូវតម្រូវឱ្យមកយកកាតដោយខ្លួនឯងម្តងទៀត) ។

ចំណែកឯ ការចុះបញ្ជិកាជាមួយក្រុមការងារបញ្ជិកម្មការនិយោជិត ដែលពួកគាត់ចុះទៅដល់មូលដ្ឋានសហគ្រាស គ្រឹះស្ថាន នោះគឺ ជាកចុះបញ្ជិកាដោយប្រើអនុប្រព័ន្ធនៃបណ្តាញប្រតិបត្តិការផ្នែកគ្រប់គ្រងទិន្នន័យបញ្ជិកា និងភាគទាន (OFFLINE REGISTATION) ។ ការចុះបញ្ជិកាបែបនេះ គឺគេគ្រាន់តែប្រមូលទិន្នន័យ ស្កេនស្នាមខ្មៅដៃ និងថតរូបទុកក្នុងសិនតែប៉ុណ្ណោះ។ បន្ទាប់ពីប្រមូលទិន្នន័យតាមរយៈការចុះកំណត់អត្តសញ្ញាណនៅតាមមូលដ្ឋានសហគ្រាស គ្រឹះស្ថានរួចមក ក្រុម

ការងារនឹងធ្វើការបញ្ចូលនូវពត៌មានទាំងអស់របស់កម្មករនិយោជិត ដែលមានចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួចផ្តល់លេខអត្តសញ្ញាណម្តងមួយៗ រួចផលិតកាត និងផ្ញើរកាតសមាជិកទាំងអស់ទៅតាមតំណាងសហគ្រាស គ្រឹះស្ថានទៅឱ្យកម្មករជាការស្រេច។ ការសម្រួលដោយការចុះកំណត់អត្តសញ្ញាណជូនកម្មករនិយោជិតដល់មូលដ្ឋានសហគ្រាស គ្រឹះស្ថានបែបបនេះ គឺអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថានណាដែលប្រើប្រាស់កម្មករនិយោជិតចាប់ពី៥០ (ហាសិប)នាក់ឡើងទៅតែប៉ុណ្ណោះ[61]។

ចំពោះអត្តលេខសម្គាល់សមាជិក**ប.ស.ស** ដែលផ្តល់ឱ្យលើកក្រោយតាមរយៈកាតនេះ គឺមកប្រើប្រាស់សម្រាប់បង់ភាគទានទាំងហានិភ័យការងារ និងថែទាំសុខភាពក្នុងពេលតែមួយតែម្តង។

**ខ. ការបង់ភាគទានសម្រាប់របបធានារ៉ាប់រងសុខភាព**

យោងតាមអនុក្រឹត្យ លេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ អត្រាបង់ភាគទានមានចំនួន ២,៦ (ពីរក្បៀសប្រាំមួយ)ភាគរយនៃប្រឈ្នួលមធ្យមជាប់ភាគទាន។ ដោយតម្រូវឱ្យខាងនិយោជក និងសាមីជន ដែលជាកម្មករនិយោជិតត្រូវបង់ម្នាក់ពាក់កណ្តាល។ ប៉ុន្តែក្រោយពីមានអនុក្រឹត្យ លេខ១៩០ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៧នៃអនុក្រឹត្យ លេខ០១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ គឺតម្រូវឱ្យតែនិយោជកតែម្ខាងគត់ជាអ្នកបង់ភាគទានទាំងស្រុង ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨តទៅ។

ចំណែកបែបបទ នៃការបង់វិញគឺ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវបង់ភាគទានចូលមកក្នុងគណនីរបស់បេឡាជាតិរបបសន្តិសុខសង្គម ដែលស្ថិតនៅក្នុងធនាគារដែលបានកំណត់តាមរយៈលេខគណនី: ០០១ ១០៤៦៥៨៨៩ ១៨ នៅធនាគារអេស៊ីលីដា ឬសាខារបស់ធនាគារនេះ។ រហូតដល់ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ តាមសេចក្តីជូនដំណឹងលេខ:០០៤/១៩ ប.ស.ស បានបង្ហាញឱ្យសាធារណៈជន ជាពិសេសនិយោជក ឬម្ចាស់សហគ្រាសអំពីធនាគារដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស** មានដូចជាធនាគារ កាណាឌីយ៉ា ក.អ ដែលមានលេខគណនី: ០០១០ ០០៤៣ ៤៨៣៣៣ និងធនាគារឯកទេសវីង ដែលមានលេខគណនី: ៩១១៩ ហើយថ្លៃសេវា អ៊ិនធឺណែតប៉ែងឃីង គឺជាបន្ទុករបស់និយោជក។ ការចុះកិច្ចព្រមព្រៀងជាមួយធនាគារទាំងបីនេះបានធ្វើឱ្យការបង់ភាគទានកាន់តែងាយស្រួលជាងមុន ហើយគេសង្ឃឹមថានៅថ្ងៃមុខនឹងមានការពង្រីកដៃគូនេះបន្ថែមទៀត។

[61] សេចក្តីណែនាំលេខ ៦៩/ ១៥ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការចុះបញ្ជិកាកម្មករនិយោជិតមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម

ក្រោយពីបង់ភាគទាននៅធនាគារដែលបានចុះកិច្ចព្រមព្រៀងជាមួយ**ប.ស.ស** ទាំងបីខាងលើ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវយកលិខិតប្រកាសឥណទាន (Bank slip) របស់ធនាគារ មកកាន់**ប.ស.ស** ដើម្បីទទួលបាន "**លិខិតបញ្ជាក់ការបង់ភាគទាន**" ពី **ប.ស.ស**។

និយោជក ឬម្ចាស់គ្រឹះស្ថានត្រូវដាក់ជូនមក **ប.ស.ស** ដើម្បីពិនិត្យនូវៈ

១. របាយការណ៍ចំនួនកម្មករនិយោជិតដែលប្រើប្រាស់ក្នុងខែនីមួយៗ "ទម្រង់**១.០២**" (របាយការណ៍ត្រូវផ្ញើរជា soft ដោយភ្ជាប់លិខិតអម ដែលចុះហត្ថលេខាដោយ និយោជក ឬតំណាង បញ្ជាក់ពីចំនួនកម្មករនិយោជិតដែលមានសរសេរក្នុង soft នោះ)។

២. លិខិតប្រកាសបង់ភាគទាន ដែលចុះហត្ថលេខាដោយនិយោជក ឬតំណាង និងមានភ្ជាប់ ទម្រង់"**២.០១**" (បែបបទបង់ភាគទាន)។ ទម្រង់"**២.០១**"នេះ ត្រូវធ្វើsoft ដូចមាននៅក្នុងSoftware របស់**ប.ស.ស** ដែលបានផ្តល់ជូន។ ។

និយាយជារួមមក ការបង់ភាគទានលើរបបហានិភ័យការងារ និងថែទាំសុខភាព គឺរបៀបតែមួយព្រោះឱ្យតែសហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវធ្វើការណែនាំរបស់ថ្មីរបស់ក្រសួងការងារស្តីពីការបង់ភាគទាន ហើយភាគទានទាំងហានិភ័យការងារ និងថែទាំសុខភាពត្រូវបង់ក្នុងពេលជាមួយគ្នា។

## កថាខណ្ឌទី ៣ តាវកាលិកសម្រាប់របបថែទាំសុខភាព

### ក. ប្រភេទតាវកាលិក

តាវកាលិកថែទាំសុខភាព សំដៅដល់របបធានារ៉ាប់រងដែលផ្តល់កញ្ចប់តាវកាលិកសុខភាព និងសេវាបង្ការដែលបានកំណត់។ ហើយតាវកាលិកថែទាំសុខភាពដែលត្រូវបានផ្តល់ក្នុងការអនុវត្ត របបថែទាំសុខភាពរួមមានៈ កញ្ចប់តាវកាលិកសុខភាព (សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះ និងសេវាបញ្ជូនសព និងប្រាក់បំណាច់ប្រចាំថ្ងៃ) និងសេវាបង្ការសុខភាព។

#### ក.១. កញ្ចប់តាវកាលិកសុខភាព

១. សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ

១.១. ការព្យាបាលដោយសម្រាកក្នុងមន្ទីរពេទ្យ

- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រ និងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗដែលជាតម្រូវការចាំបាច់សម្រាប់ការព្យាបាល

- ឱសថតាមវេជ្ជបញ្ជា
- បន្ទប់ (ធម្មតា) និងអាហារដែលផ្តល់ដោយមូលដ្ឋានសុខាភិបាល។

១.២. សេវាពិគ្រោះជម្ងឺក្រៅ

- សេវាព្យាបាលថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ សេវារូបសាស្ត្រ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រ និងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗដែលជាតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា

១.៣. សេវាសង្គ្រោះបន្ទាន់ សំដៅដល់ការធ្វើអន្តរាគមទាំងឡាយណា ដែលធ្វើឡើងក្នុងកាលៈទេសៈមួយដែលមិនបានគ្រោងទុក ហើយអន្តរាគមន៍ទាំងនោះអាចត្រូវធ្វើឡើងភ្លាមក្នុងគោលបំណងសង្គ្រោះជីវិត ឬជួយការពារការបាត់បង់អវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជម្ងឺ ឬ ជនរងគ្រោះ។

១.៤. សេវាព្យាបាលដោយស្នំ និងដោយចលនា។

១.៥. សេវាសម្រាលកូន និងព្យាបាលថែទាំមុន និងក្រោយពេលសម្រាលកូន។

១.៦. សេវាស្តារនីតិសម្បទា គឺជាការព្យាបាលថែទាំវេជ្ជសាស្ត្រសម្រាប់ការថែទាំសុខភាពក្នុងគោលបំណងជួយដល់ជនរងគ្រោះរក្សា ស្តារ ឬធ្វើឱ្យប្រសើរឡើងវិញញនូវសមត្ថភាពជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ និងជំនាញប្រាស្រ័យទាក់ទងដែលបានបាត់បង់ ឬខូចខាតដោយសារជម្ងឺ ការរងរបួស ឬពិការភាព។

២. សេវាបញ្ជូនអ្នកជម្ងឺ ឬ ជនរងគ្រោះ និងសេវាបញ្ជូនសពៈ ការបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះពីមូលដ្ឋានសុខាភិបាលមួយ ទៅមូលដ្ឋានសុខាភិបាលមួយទៀតក្នុងករណីដែលអ្នកជម្ងឺ ឬជនរងគ្រោះមានអការៈធ្ងន់ធ្ងរ និងបញ្ជូនសពពីមូលដ្ឋានសុខាភិបាលទៅគេហដ្ឋាន ឬកន្លែងដែលចាំបាច់។

៣. ប្រាក់បំណាច់ប្រចាំថ្ងៃៈ ប្រាក់នេះត្រូវបានផ្តល់ជូនក្នុងពេលមានជម្ងឺ ឬជួបឧប្បទេវហេតុផ្សេងៗ ដោយគិតទាំងការសម្រាកព្យាបាលដោយគោលនយោបាយសុខាភិបាលសាធារណៈដូចចំណុច១ ប្រការ ៤ នៃប្រកាសលេខ១០៩ខាងលើនេះ។

**ក.២. សេវាបង្ការសុខភាព**

សេវាបង្ការសុខភាព ផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម កម្មវិធីជាតិ ឬស្ថាប័ន និងអង្គភាពដែលពាក់ព័ន្ធទៅនឹងបញ្ហាសុខភាពដទៃទៀត[62]។

**ខ. លក្ខខណ្ឌ និងនីតិវិធីក្នុងការទទួលបានតាវកាលិក**

**ខ.១. ចំពោះសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ**

ដើម្បីទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ កម្មករនិយោជិតទាំងអស់ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមៈ

- កំពុងបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់របបថែទាំសុខភាព
- បានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)
- បានបង់ភាគទានចំនួន ០២ (ពីរ) ខែជាប់គ្នា ឬបានបង់ភាគទានយ៉ាងតិច ០៦ (ប្រាំមួយ) ខែក្នុងកំឡុង១២ (ដប់ពីរ) ខែចុងក្រោយ គិតរហូតមកទល់ខែដែលមានបញ្ហាសុខភាព ឬមាតុភាព។

ក្នុងករណីដែលសមាជិកបានបង់ភាគទាន ០២ (ពីរ ខែជាប់គ្នាហើយ ប៉ុន្តែអស់កាតព្វកិច្ចបង់ភាគទានដោយសារការបញ្ចប់កិច្ចសន្យាការងារ សមាជិកមានសិទ្ធិទទួលសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្ររយៈពេល ០២ (ពីរ)ខែថែមទៀតគិតចាប់ពីកាលបរិច្ឆេទនៃការបញ្ចប់កិច្ចសន្យាការងាររបស់សាមីជន[63]។

ការប្រើប្រាស់សេវាសុខាភិបាល ត្រូវធ្វើនៅតាមមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយ**ប.ស.ស**។ បេឡាជាតិរបបសន្តិសុខសង្គមនឹងទទួលខុសត្រូវទូទាត់ថ្លៃសេវាដូចមានកំណត់ក្នុងកញ្ចប់តាវកាលិកសុខភាព។ ប្រសិនបើសមាជិក **ប.ស.ស** ទៅប្រើប្រាស់សេវាក្រៅពី មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងនោះ**ប.ស.ស**នឹងទូទាត់សងវិញក្នុងករណីដែលសង្គ្រោះបន្ទាន់ប៉ុណ្ណោះ។

សមាជិក **ប.ស.ស** អាចប្រើប្រាស់សេវាបានគ្រប់បញ្ហាសុខភាព លើកលែងតែសេវាណាដែលមិនរាប់បញ្ចូលក្នុងសេវាព្យាបាលវេជ្ជសាស្ត្រ មានដូចជាៈ

- ការព្យាបាលដោយមិនគិតថ្លៃដែលមានចែងក្នុងគោលនយោបាយសុខាភិបាលសាធារណៈ
- ការថែទាំធ្មេញ (ការសម្អាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)
- ការព្យាបាល និងការវះកាត់ប្តូរភេទ

[62] ប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព ប្រការ៣

[63] ប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព ប្រការ៦

- ការផ្សាំ ឬ ប្តូរសរីរាង្គផ្សេងៗ
- សេវាបង្ករកំណើតដោយសិប្បនិម្មិត
- ការព្យាបាលដោយខ្លួនឯង
- ការព្យាបាល ឬវះកាត់ដើម្បីជាប្រយោជន៍នៃការកែលម្អផ្នែកណាមួយនៃរាងកាយ
- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ
- ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន
- ការព្យាបាលអសមត្ថភាពផ្តល់កំណើត
- ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត
- ការវះកាត់បេះដូង និងសរសៃឈាមបេះដូង
- ការលាងឈាម
- ការព្យាបាលមហារីកដោយសារធាតុគីមី

ក្នុងករណីសង្គ្រោះបន្ទាន់សេវាដូចមានចែងខាងលើត្រូវបានផ្តល់ជូន[64]។

ការទាមទារតាវកាលិកត្រូវធ្វើតាមទម្រង់ "**តាវកាលិកព្យាបាល និងថែទាំវេជ្ជសាស្ត្រ**" ឬហៅថាទម្រង់ "**៤.០២**" ឧបសម្ព័ន្ធ ២នៃប្រកាសលេខ១០៩ ស្តីពីតាវកាលិកត្រូវមានភ្ជាប់ជាមួយនូវឯកសារវេជ្ជសាស្ត្រ និងវិក្ក័យបត្រនានាព្រមទាំងឯកសារពាក់ព័ន្ធចាំបាច់ដទៃទៀត។ សិទ្ធិទាមទារតាវកាលិកព្យាបាលមានអាជ្ញាយុកាល ១២ (ដប់ពីរ)ខែគិតចាប់ពីថ្ងៃមានបញ្ហាសុខភាព[65]។

ចំពោះជម្ងឺរ៉ាំរ៉ៃទាំង១៤ប្រភេទ ដែលមានៈ

1. ជម្ងឺខ្សោយបេះដូង (Cardiac Failure )
2. ជម្ងឺសាច់ដុំបេះដូង (Cadiomyopathy)
3. ជម្ងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ Chronic Hepatitis B)
4. ជម្ងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ (Chronic Hepatitis C)
5. ជម្ងឺតម្រងនោមរ៉ាំរ៉ៃ (Chronic renal disease)
6. ជម្ងឺក្រិនថ្លើម (Cirrhosis)
7. ជម្ងឺសរសៃឈាមក្រហមបេះដូង (Coronary Artery Disease)
8. ជម្ងឺទឹកនោមផ្អែមប្រភេទទី ១ និង ទី២ (Diabetes Mellitus Type 1 & 2)
9. ជម្ងឺវិវត្តចង្វាក់បេះដូង (Dysrhthias)
10. ជម្ងឺក្រិនសរីរាង្គ (Mutiple Sclerosis)

[64] ប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព ប្រការ៩

[65] ប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព ប្រការ១០ ចំណុច ១០.១

11. ជម្ងឺវិកលចរិត (Schizophrenia )
12. ជម្ងឺលុយពុស (System lupus Erythematosus)
13. ជម្ងឺលើសឈាម (Hypertension)
14. ជម្ងឺតាឡាសស៊ីមី (Thalassemia)

ការផ្តល់សេវាត្រូវធ្វើឡើងតែក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ និងត្រូវប្រើប្រាស់ឱសថសារវន្តតែប៉ុណ្ណោះ។ ចំពោះឱសថក្រៅបញ្ជីជាបន្ទុកផ្ទាល់របស់អ្នកជម្ងឺ[66]។

**ខ.២. ប្រាក់បំណាច់ប្រចាំថ្ងៃ**

ក្រៅពីការព្យាបាលដោយឥតគិតថ្លៃនៅតាមមូលដ្ឋានសុខាភិបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម លើកលែងតែជម្ងឺរ៉ាំរ៉ៃ។ ក្នុងពេលសម្រាកពេទ្យនេះផងដែរ សមាជិក **ប.ស.ស** ត្រូវសុំច្បាប់សម្រាកពីនិយោជកតាមទម្រង់ដែលបានកំណត់ដោយ**ប.ស.ស** និងបានបង់ភាគទានជាប់គ្នាយ៉ាងតិច ០៤ (ប្រាំបួន) ខែជាប់គ្នាអាចទទួលបាននូវ៖

– ប្រាក់បំណាច់ប្រចាំថ្ងៃ ចំនួន៧០ (ចិតសិប) ភាគរយនៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់សាមីជនសម្រាប់រយៈពេលអាកខានមិនបានបំពេញការងារ ដោយសារការសម្រាកព្យាបាលថែទាំជម្ងឺ ឬរបួសតាមវេជ្ជបញ្ជាមានរយៈពេលជាប់គ្នាលើសពី ០៧ (ប្រាំពីរ) ថ្ងៃ។

– ប្រាក់ឈ្នួលពីនិយោជក ក្នុងករណីដែលការអាក់ខានធ្វើការងារ ដោយការឈប់សម្រាកព្យាបាលថែទាំជម្ងឺ ឬរបួសតាមវេជ្ជបញ្ជាជាប់គ្នាត្រឹម០៧ (ប្រាំពីរ) ថ្ងៃចុះ។

– ប្រាក់បំណាច់ប្រចាំថ្ងៃ ៧០ (ចិតសិប) ភាគរយនៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់សាមីជនសម្រាប់រយៈពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃឈប់សម្រាកមុន និងក្រោយសម្រាលកូនកាលណាបើបានបង់ភាគទាន ០៩ (ប្រាំបួន)ខែជាប់គ្នាមុនពេលសម្រាល[67]។ លើសពីនេះទៅទៀត រាល់ការសម្រាលកូនរបស់កម្មករនិយោជិតជាស្ត្រីនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈនឹងទទួលបានប្រាក់ឧបត្ថម្ភបន្ថែម៖

- សម្រាលកូនទោល (មួយ) ទទួលបាន ៤០០ ០០០០ (បួនសែន) រៀល
- សម្រាលកូនភ្លោះ (ពីរ) ទទួលបាន ៨០០ ០០០ (ប្រាំបីសែន) រៀល
- សម្រាលកូនភ្លោះ (បី) ទទួលបាន ១ ២០០ ០០០ (មួយលានពីរសែន) រៀល

ប្រាក់ឧបត្ថម្ភនេះត្រូវផ្តល់ជូនដោយផ្ទាល់ពី**ប.ស.ស** ក្រោយពេលសម្រាលកូនទោះបីជាស្លាប់

[66] ប្រកាសលេខ២៣៨ ក.ប/ប្រ.ក ស្តីពីការកំណត់បញ្ជីជម្ងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ប្រការ ២
[67] ប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតារកាលិកថែទាំសុខភាព ប្រការ៧

ឬរស់ក៏ដោយ[68]ដោយគិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨តទៅ។

សម្រាប់ការសម្រាលបានកូនភ្លោះ (បី) នឹងបន្ថែមប្រាក់ឧត្ថម្ភរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចំនួន ៥ ០០០ ០០០ (ប្រាំលាន) រៀលទៀតផង។

ការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃ ត្រូវធ្វើឡើងដោយអ្នកជម្ងឺ ឬជនរងគ្រោះ ឬអ្នកតំណាងតាមទម្រង់ "**ប្រាក់បំណាច់ប្រចាំថ្ងៃ**" ឬហៅថាទម្រង់ "**៤.០៣**" នៃឧបសម្ព័ន្ធ ៣នៃប្រកាសលេខ១០៩ ស្តីពីតាកាលិក។ បែបបទនៃការទាមទារនេះត្រូវភ្ជាប់មកជាមួយនូវលិខិតចេញពីមន្ទីរពេទ្យដោយមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ**ប.ស.ស** ដែលជនរងគ្រោះចូលសម្រាកព្យាបាល។ លិខិតអនុញ្ញាតច្បាប់អាចចេញ ដោយគ្រូពេទ្យសហគ្រាស និងមានការយល់ព្រមពីនិយោជក ឬអ្នកតំណាងសហគ្រាស គ្រឹះស្ថាននោះ។

សិទ្ធិនៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃមានអាជ្ញាយុកាលត្រឹម១២ (ដប់ពីរ)ខែគិតចាប់ពីថ្ងៃមានបញ្ហាសុខភាពដំបូង។

### ខ.៣. សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះ និងបញ្ជូនសព

សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះត្រូវបានផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ និងដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាលតែប៉ុណ្ណោះ។ ចំពោះសេវាបញ្ជូនអ្នកជម្ងឺធ្ងន់ធ្ងរដែលមិនអាចព្យាបាលឲ្យជា ឬសពត្រូវផ្តល់ជូនទៅតាមតម្លៃមូលដ្ឋានសុខាភិបាល ដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

### ខ.៤.សេវាបង្ការសុខភាព

តាមប្រកាសលេខ ០៤៩/១៧ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្តីពីការដាក់បញ្ចូលសេវាបង្ការសុខភាពក្នុងរបបសន្តិសុខសង្គម សេវាទាំងនោះមានដូចជា៖

១. សេវាចាក់វ៉ាក់សាំងការពារជម្ងឺឆ្កែឆ្កួត (Rabies Vaccination)

២. សេវាចាក់សេរ៉ូមប្រឆាំងជម្ងឺឆ្កែឆ្កួត (Antirabic serum)

៣.សេវាចាក់សេរ៉ូមប្រឆាំងជម្ងឺតេតាណូស ( Anti-Tetanous Serum)

៤. សេវាចាក់សេរ៉ូមប្រឆាំងពិសពស់( Antivenom Immunogiubulin)

៥. សេវាពិនិត្យឈាមរកជម្ងឺពក ក ៖TSH ( Thyriod – Stimulating Hormone ) និង Free T3 (Free Triioldothyronine ) , Free T4 (Freet Thyroxine)

---

[68] ប្រកាសអន្តរក្រសួងលេខ ៩០៤ ក.ប/ប្រ.ក.ប.ស.ស ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន ប្រការ ៨

៦. សេវាពិនិត្យឈាម កំណត់អបោធាតុមហារីក (Cancer Humeraux Marcueurs) ក្រោយការព្យាបាលជម្ងឺមហារីកដោយវះកាត់ និង/ឬការព្យាបាលជម្ងឺមហារីកដោយចាក់គីមី និង/ឬការព្យាបាលជម្ងឺមហារីកដោយកាំរស្មី អ៊ិច រួមមាន៖ CA 15-3 (Cancer Antigen 15-3), CA 19-9 (Antigen 19-9) , CA 125 (Antigen 125) , PSA (Prostate Specific Antigen), HCG (Beta-Human chorionic Gonadotropin) .

សេវាបង្ការសុខភាពដែលបានកំណត់ក្នុងប្រកាសនេះត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលសាធារណ: ឬវិទ្យាស្ថានសាធារណ:។

សេវានេះមិនត្រូវទូទាត់សងវិញទេ ចំពោះការប្រើប្រាស់សេវានៅតាមមូលដ្ឋានសុខាភិបាលឯកជន ឬមន្ទីរពិសោធន៍ឯកជនក្នុង និងក្រៅប្រទេស លើកលែងតែមានការអនុញ្ញាតពីបេឡាជាតិរបបសន្តិសុខសង្គម។

ការកំណត់នេះ អាចនឹងមានការផ្លាស់ប្តូរតាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ផ្នែកទី ២ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីរាជការសាធារណ: អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

យោងតាម "ព្រះរាជក្រឹត្យ **នស/រកត/០១៧/០៧៨** ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីរាជការសាធារណ: និងថែទាំសុខភាពសម្រាប់មន្ត្រីរាជការសាធារណ: អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន" មាត្រា៥ ចែងថា "បេឡាជាតិរបបសន្តិសុខសង្គម(**ប.ស.ស**) គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលមានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យនេះ។"

មាត្រា៣ "ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះ៖

១. មន្ត្រីសាធារណ:ដូចខាងក្រោម៖

ក. មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណ: ដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិក:មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

ខ. មន្ត្រីរាជការដែលបម្រើក្នុងស្ថាប័ននីតិប្បញ្ញាត្តិ។

គ. មន្ត្រីរាជការដែលបម្រើក្នុងស្ថាប័នតុលាការ។

ឃ. មន្ត្រីនគរបាលជាតិ

ង. មន្ត្រីជាប់កិច្ចសន្យាដែលបម្រើការនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានការទទួលស្គាល់ពីក្រសួងមុខងារសាធារណៈ។

២. អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

៣. មន្ត្រីសាធារណៈក្រៅពីចំណុច១ខាងលើ និងអ្នកនៅក្នុងបន្ទុកដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យដោយផ្អែកលើស្ថានភាពសង្គម និងសេដ្ឋកិច្ចជាក់ស្តែង។

ចំពោះរបបសន្តិសុខសង្គមសម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទនឹងមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។"

នេះបានបង្ហាញពីភារកិច្ចថ្មីមួយថែមទៀតបន្ថែមក្នុងការអនុវត្តជំហានទី ២របស់បេឡាជាតិរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពក៏ត្រូវបានអនុវត្តផងដែរចំពោះមន្ត្រីរាជការសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

ដើម្បីអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាពដូចដែលអនុវត្តចំពោះការអនុវត្តទៅលើជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនោះចាំបាច់ណាស់ បេឡាជាតិរបបសន្តិសុខសង្គមត្រូវរៀបចំការធ្វើចុះបញ្ជិកាសមាជិកថ្មីរបស់ខ្លួន (ការកំណត់អត្តសញ្ញាណ) ដែលជាមន្ត្រីសាធារណៈ រួមទាំងការបង់ភាគទានដើម្បីធានាដល់ការផ្តល់នូវតាវកាលិកប្រកបដោយប្រសិទ្ធភាព និងភាពទុកចិត្ត។

**កថាខណ្ឌទី ១ ការចុះបញ្ជីមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនចូលទៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម**

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវសហការផ្តល់ទិន្នន័យមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនមកបេឡាជាតិរបបសន្តិសុខសង្គមដើម្បីបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព។

**ប.ស.ស** ត្រូវចេញលេខអត្តសញ្ញាណសមាជិក **ប.ស.ស** សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដោយអនុលោមតាមលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។ ដើម្បីអនុវត្តការចេញលេខអត្តសញ្ញាណសមាជិកនេះ ក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធមានភារកិច្ចៈ

- ក្រសួងមុខងារសាធារណៈត្រូវផ្តល់ទិន្នន័យមន្ត្រីសាធារណៈ និងទំហំថវិកាភាគទានតាមក្រសួងមក**ប.ស.ស** ជារៀងរាល់ខែ
- ក្រសួង ស្ថាប័ន ឬអង្គភាព ដែលគ្រប់គ្រងផ្ទាល់លើមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនត្រូវផ្តល់ទិន្ន័យមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន និងទំហំថវិកាភាគទាន ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមុខងារសាធារណៈមក**ប.ស.ស** ជារៀងរាល់ខែ។

ដើម្បីងាយស្រួលក្នុងការអនុវត្តសន្តិសុខសង្គមផ្នែកធានារ៉ាប់រងផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

**កថាខណ្ឌទី ២ ការបង់ភាគទាន**

**ក. អត្រាបង់ភាគទាន**

ដោយយោងតាមអនុក្រឹត្យ លេខ៥៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។ មាត្រា៤ បានចែងថា "ភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ ជាបន្ទុករួមគ្នារវាងរដ្ឋ និងសាមីជន។ អត្រាភាគទាននេះត្រូវកំណត់ស្មើនឹង០១ (មួយ)ភាគរយនៃប្រាក់បៀវត្សន៍មូលដ្ឋាន ឬប្រាក់ប្រចាំខែរបស់មន្ត្រីសារធារណៈ ដែលក្នុងនោះ៖

- 0,៥0 (សូន្យក្បៀសហាសិប) ភាគរយ ជាបន្ទុករបស់រដ្ឋ
- 0,៥0 (សូន្យក្បៀសហាសិប) ភាគរយ ជាបន្ទុករបស់សាមីជន។

និងមាត្រា៥ ចែងថា "ភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនជាបន្ទុករបស់សាមីជន។ អត្រាភាគទាននេះត្រូវកំណត់ស្មើនឹង 0,៥0 (សូន្យក្បៀសហាសិប) ភាគរយនៃប្រាក់សោធនរបស់សាមីជនដោយមិនរាប់បញ្ចូលប្រាប់បន្ទាប់បន្សំ ឬប្រាក់ឧបត្ថម្ភផ្សេងៗ"

ត្បិតតែមាត្រាទាំងពីរនេះចង់ឱ្យមានការចូលរួមទទួលខុសត្រូវក្នុងការបង់ភាគទានសម្រាប់ការធានារ៉ាប់រងរបស់ខ្លួនក៏ដោយ ប៉ុន្តែមាត្រា១៦ នៃអនុក្រឹត្យដដែលនេះ បានបង្វែរបន្ទុករបស់សាមីជនដូចក្នុងមាត្រា៤ និងមាត្រា៥ខាងលើនេះមកជាបន្ទុករបស់រាជរដ្ឋាភិបាលសិនរហូតដល់មានការសម្រេចថ្មីលើចំណុចនេះ។

ជាបណ្តោះអាសន្ន ចាប់តាំងពីចាប់អនុវត្តនាខែមករា ឆ្នាំ២០១៨ រហូតមកដល់ពេលនេះ រាល់ភាគទានលើផ្នែកថែទាំសុខភាពនេះ សាមីជនមិនត្រូវបានកាត់ប្រាក់ដើម្បីមកបង់ភាគទានឡើយ។ នេះបានបង្ហាញពីចំណែកមួយក្នុងការយល់ទុកធុរៈរបស់រាជរដ្ឋាភិបាល ដល់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

**ខ. នីតិវិធីនៃការបង់ភាគទាន**

**ខ.១. ចំពោះប្រាក់ភាគទានដែលជាបន្ទុករបស់រដ្ឋ**

ឥណទានថវិកាភាគទានផ្នែកថែទាំសុខភាពដែលជាបន្ទុករបស់រដ្ឋ ត្រូវគ្រោងក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសុខាភិបាល។ នៅពេលរៀបចំថវិកាប្រចាំឆ្នាំ ក្រសួងសុខាភិបាលមានភារកិច្ចគ្រោងឥណទានថវិកាថែទាំសុខភាពដែលជាបន្ទុករបស់រដ្ឋដោយផ្អែកលើមូលដ្ឋានផែនការ

ក្របខ័ណ្ឌមន្ត្រីសាធារណៈប្រចាំឆ្នាំរបស់ក្រសួងមុខងារសាធារណៈ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។

**ខ.២. ចំពោះប្រាក់ភាគទានដែលជាបន្ទុករបស់សាមីជន**

ឥណទានថវិការជួសម្រាប់បង់ភាគទានផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ ដែលជាបន្ទុករបស់សាមីជន ត្រូវគ្រោងក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងអង្គភាពដែលគ្រប់គ្រងមន្ត្រីសាធារណៈនោះ។

ឥណទានថវិការជួសម្រាប់បង់ភាគទានផ្នែកថែទាំសុខភាពសម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលជាបន្ទុករបស់សាមីជនត្រូវគ្រោងក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់សាមីក្រសួង ស្ថាប័ន និងអង្គភាពដែលគ្រប់គ្រងផ្ទាល់លើអតីតមន្ត្រីរាជការ និងអតីតយុទ្ធជននោះ។

ប៉ុន្តែជាបណ្តោះអាសន្ននេះ ភាគទានរបស់សាមីជន ត្រូវបានរ៉ាប់រងដោយរាជរដ្ឋាភិបាល។

**កថាខណ្ឌទី ៣ អាវកាលិក**

**ក. ការព្យាបាល និងថែទាំវេជ្ជសាស្ត្រ**

សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ រួមមាន៖

១. ការផ្តល់ការព្យាបាលដោយសម្រាកនៅមន្ទីរពេទ្យ

- ការព្យាបាល និងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រ និងសម្ភារៈផ្នែកវេជ្ជសាស្ត្រផ្សេងៗ តាមតម្រូវការចាំបាច់សម្រាប់ ការព្យាបាល។
- ឱសថតាមវេជ្ជបញ្ជា
- បន្ទប់សម្រាកព្យាបាល (តាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋានសុខាភិបាល)។

២. ការផ្តល់សេវាពិគ្រោះជម្ងឺក្រៅ រួមមាន៖

- សេវាព្យាបាល និងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា

៣.ការផ្តល់សេវាសម្រាលកូន និងការព្យាបាលថែទាំមុន និងក្រោយសម្រាល

៤. ការផ្តល់សេវាព្យាបាលដោយស្ទំ ឬការព្យាបាលដោយចលនា ឬសេវាស្តារនីតិសម្បទាដទៃទៀត

៥. ការព្យាបាលដោយស្ទំ និងដោយចលនា

៦. សេវាស្តារនីតិសម្បទា

៧.សេវាបង្ការសុខភាពត្រូវអនុវត្តដូចគ្នាទៅនឹងរបបថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ

៨. សេវា ឬការព្យាបាលដែលមិនរាប់បញ្ចូលរួមមាន៖

- ការព្យាបាលដោយមិនគិតថ្លៃដែលមានចែងក្នុងគោលនយោបាយសុខាភិបាលជាតិ
- ការពិនិត្យសុខភាពជាទូទៅ
- ការថែទាំធ្មេញ (ការសម្អាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)
- សេវាវះកាត់ប្តូរភេទ
- ការព្យាបាល ឬវះកាត់កែសម្ផស្ស ឬកែលម្អផ្នែកណាមួយនៃរាងកាយ
- សេវាបង្ករកំណើតដោយសិប្បនិម្មិត
- ការផ្សាំ ឬ ប្តូរសរីរាង្គផ្សេងៗ
- ការព្យាបាលដោយខ្លួនឯង
- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត
- ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន
- ការព្យាបាលអសមត្ថភាពផ្តល់កំណើត
- ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត
- ការវះកាត់បេះដូង និងសរសៃឈាមបេះដូង
- ការលាងឈាម

រាល់សេវា ឬការព្យាបាលដែលមិនរាប់បញ្ចូលនេះត្រូវបានផ្តល់ជូនក្នុងករណីសង្គ្រោះបន្ទាន់។

០៩. ចំពោះជម្ងឺរ៉ាំរ៉ៃ៖ ត្រូវបានអនុវត្តដូចគ្នាទៅនឹងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដែរ។

**ខ. សេវាសង្គ្រោះបន្ទាន់**

ការផ្តល់សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះ ត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ និងដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាលតែប៉ុណ្ណោះ។ ករណីសង្គ្រោះបន្ទាន់ សមីជនរងគ្រោះអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត។ បើសិនជាមូលដ្ឋានសុខាភិបាលនោះមិនមានកិច្ចព្រមព្រៀងជាមួយ**ប.ស.ស** ទេ សាមីជនរងគ្រោះ ឬអ្នកតំណាងត្រូវជូនដំណឹងជាបន្ទាន់មកបេឡាជាតិរបបសន្តិសុខសង្គម។

ការទូទាត់ថ្លៃសង្គ្រោះបន្ទាន់តាមតម្លៃសមស្របរបស់មូលដ្ឋានសុខាភិបាលនោះតែម្តង។ ហើយសិទ្ធិក្នុងការទាមទារថ្លៃការព្យាបាល និងថែទាំវេជ្ជសាស្ត្រមានអាជ្ញាយុកាលត្រឹមរយ:ពេល ១២ (ដប់ពីរ)ខែគិតចាប់ពីថ្ងៃមានបញ្ហាសុខភាព។

នៅពេលទៅប្រើប្រាស់សេវា៖

- សម្រាប់មន្ត្រីសាធារណ: ត្រូវភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ កាតមន្ត្រីរាជការ ឬលិខិតបង្គាប់ការ និងលិខិតបញ្ជាក់អត្តសញ្ញាណដទៃទៀតដែលចេញដោយក្រសួង ស្ថាប័ន និងអង្គភាពរបស់ខ្លួន។
- សម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន: ត្រូវភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅធនាគារ ឬលិខិតបញ្ជាក់អត្តសញ្ញាណដទៃទៀតដែលចេញដោយក្រសួង ស្ថាប័ន និងអង្គភាពរបស់ខ្លួន។

## ផ្នែកទី ៣ មូលដ្ឋានសុខាភិបាល និងយន្តការនៃការទូទាត់ថ្លៃសេវាសុខាភិបាល

ក្រៅពីការផ្តល់តាវកាលិកជាសម្ភារ: និងថវិកាទៅដល់ជនគោលដៅរបស់យើងដែលជាសមាជិក**ប.ស.ស** នោះ។ ការផ្តល់តាវកាលិកដ៏សំខាន់ជាងគេនោះគេ ការផ្តល់នូវសេវាសុខាភិបាលដល់ពួកគាត់នៅពេលដែលពួកគាត់ជួបនូវគ្រោះថ្នាក់ដោយសារហានិភ័យការងារ និងជួបបញ្ហាផ្នែកសុខភាព។ ដើម្បីផ្តល់នូវសេវាសុខាភិបាលនេះបាន បេឡាជាតិរបបសន្តិសុខសង្គមមិនមានលទ្ធភាពផ្តល់ទៅដល់សមាជិករបស់ខ្លួនដោយខ្លួនឯងផ្ទាល់បានឡើយ។ ដូច្នេះដើម្បីបម្រើនូវសេវាទាំងនេះបានច្បាស់ណាស់ បេឡាជាតិរបបសន្តិសុខសង្គមត្រូវការសហការយ៉ាងពេញទំហឹងជាមួយនឹងមូលដ្ឋានសុខាភិបាល ដែលជាអង្គភាពជំនាញធ្វើការផ្តល់នូវតាវកាលិកលើផ្នែកសេវាសុខាភិបាលដើម្បីគាំទ្រ និងបំពេញតម្រូវការអនុវត្តរបបសន្តិសុខសង្គមទាំងផ្នែកធានារ៉ាប់រងហានិភ័យការងារ និងថែទាំសុខភាព។

ទន្ទឹមនឹងការសហការគ្នារវាងបេឡាជាតិរបបសន្តិសុខសង្គមជាមួយនឹងមូលដ្ឋានសុខាភិបាល បេឡាជាតិរបបសន្តិសុខសង្គមត្រូវរៀបចំការទូទាត់នូវរាល់ការចំណាយទៅលើការប្រើប្រាស់សេវាសុខាភិបាលពីសំណាក់របស់សមាជិករបស់ខ្លួនទៅឱ្យមូលដ្ឋានសុខាភិបាលដែលផ្តល់សេវាឱ្យបានត្រឹមត្រូវផងដែរ។

នៅក្នុងផ្នែកទី ៣នេះផងដែរ ខ្ញុំនឹងធ្វើការរ៉ាយរ៉ាប់អំពីមូលដ្ឋានសុខាភិបាល ដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម និងយន្តការនៃការទូទាត់ថ្លៃសេវាសុខាភិបាល។

### កថាខណ្ឌទី ១ មូលដ្ឋានសុខាភិបាលដៃគូ

#### ក. លក្ខណៈសម្បត្តិមូលដ្ឋានសុខាភិបាលដែលអាចចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស

មូលដ្ឋានសុខាភិបាលសាធារណៈត្រូវមានកាតព្វកិច្ចចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម(**ប.ស.ស**) ដោយអនុវត្តតាមទម្រង់កិច្ចព្រមព្រៀងដូចមានចែងក្នុងឧបសម្ព័ន្ធ ១ (សម្រាប់មណ្ឌលសុខភាព) ឧបសម្ព័ន្ធ ២ (សម្រាប់មន្ទីរពេទ្យបង្អែកកម្រិត១ កម្រិត២ និងកម្រិត៣) និងឧបសម្ព័ន្ធ ៣ (សម្រាប់មន្ទីរពេទ្យថ្នាក់ជាតិ) នៃប្រកាសអន្តរក្រសួង លេខ២៩១ ក.ប/ប្រ.ក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ "ស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលរវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថៃសុខភាព"

មូលដ្ឋានសុខាភិបាលឯកជន អាចចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គមបាន លុះត្រាតែមានការអាជ្ញាប័ណ្ណទទួលស្គាល់ដោយក្រសួងសុខាភិបាល និងត្រូវឆ្លងកាត់ការវាយតម្លៃលើកម្រិតផ្តល់សេវា និងគុណភាពពីបេឡាជាតិរបបសន្តិសុខសង្គម។

មុននឹងឈានទៅដល់ការចុះកិច្ចព្រមព្រៀង គណៈកម្មការវេជ្ជសាស្ត្រ នៃ**ប.ស.ស** ត្រូវចុះធ្វើការត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីកំណត់ពីលទ្ធភាពនៃការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាល។ ចំពោះការកំណត់ពីកម្រិតផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលទៅលើមូលដ្ឋានសុខាភិបាលនេះ គឺមិនត្រូវទាបជាងកម្រិតដែលកំណត់ដោយក្រសួងសុខាភិបាលឡើយ។

**ប.ស.ស** អាចចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល ដោយផ្អែកលើសេចក្តីត្រូវការចាំបាច់ ទីតាំងភូមិសាស្ត្រ និងស្ថានភាពមូលដ្ឋានសុខាភិបាលព្រមទាំងមានធនធានហេដ្ឋារចនាសម្ព័ន្ធសមស្រប ឬគ្រប់គ្រាន់សម្រាប់ការផ្តល់សេវាសុខាភិបាលឱ្យមានប្រសិទ្ធភាព និងគុណភាព។

ជាមួយគ្នានេះផងដែរមន្ទីរពេទ្យត្រូវមាន៖

- អាគារសមរម្យ និងបរិស្ថានអនាម័យល្អ
- ឱសថ សម្ភារៈ បរិក្ខារ និងឧបករណ៍ពេទ្យ និងមធ្យោបាយចាំបាច់នានាសម្រាប់គាំទ្រការធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាល និងថៃទាំតាមវិធាន បទបញ្ជា និងអាជ្ញាប័ណ្ណផ្សេងៗរបស់ក្រសួងសុខាភិបាល។ បុគ្គលិកមានសមត្ថភាពបច្ចេកទេស និងក្រមសីលធម៌ និងមានចំនួនសមស្របតាមការកំណត់របស់ក្រសួងសុខាភិបាល[69]។

#### ខ. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មូលដ្ឋានសុខាភិបាល

មណ្ឌលសុខភាព មន្ទីរពេត្យបង្អែក(កម្រិត ១,២ និង៣) និងមន្ទីរពេទ្យថ្នាក់ជាតិ ដែលធានាការ

[69] ប្រកាសអន្តរក្រសួងលេខ២៩១ ក.ប/ប្រ.ក ស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថៃទាំសុខភាព ប្រការ ៣

ផ្តល់សេវាប្រកបដោយគុណភាព សុវត្ថិភាព និងទាន់ពេលវេលាជូនសមាជិក**ប.ស.ស** មានតួនាទីភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោមៈ

- មានបុគ្គលិកបំពេញការងារ និងប្រចាំការនៅតាមមូលដ្ឋានសុខាភិបាល ២៤/២៤ម៉ោង និង៧(ប្រាំពីរ)ថ្ងៃក្នុងមួយសប្តាហ៍។ រយៈពេលរង់ចាំទទួលការពិគ្រោះ និងព្យាបាល មិនត្រូវយឺតយូរ និងគ្មានហេតុផលបន្ទាប់ពីអ្នកជម្ងឺ ឬជនរងគ្រោះចូលដល់ក្នុងមណ្ឌលសុខភាព
- ការផ្តល់ការពិគ្រោះ ព្យាបាល និងថែទាំវេជ្ជសាស្ត្រ និងវេជ្ជបញ្ជាស្របតាមពិធីសារ ឬសេចក្តីណែនាំប្រតិបត្តិគ្លីនិករបស់ក្រសួងសុខាភិបាល និងផ្តល់សេវាផ្សេងទៀតដែលមានចែងក្នុងកិច្ចព្រមព្រៀងដើម្បីធានាការព្យាបាលមានប្រសិទ្ធភាព
- ការផ្តល់ឱសថសារវន្ត និងបន្ទប់សម្រាក
- ការវះកាត់តូច មធ្យម និងធំ
- ធ្វើការបញ្ជូនបន្តនូវអ្នកជម្ងឺ ឬជនរងគ្រោះណាដែលមណ្ឌលសុខភាពមិនមានលទ្ធភាពក្នុងការព្យាបាល ទៅមូលដ្ឋានសុខាភិបាលផ្សេង
- កត់ត្រា និងរក្សាទុកនូវឯកសារវេជ្ជសាស្ត្រ និងឯកសារពាក់ព័ន្ធផ្សេងទៀតរបស់សមាជិក**ប.ស.ស** ដែលបានប្រើប្រាស់សេវាសម្រាប់ជាទិន្នន័យដល់ភាគី **"ក" (ប.ស.ស)** ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់តាមដាននិងវាយតម្លៃ
- អនុញ្ញាតឱ្យមន្ត្រី ឬបុគ្គលិក ឬគណៈកម្មការវេជ្ជសាស្ត្រនៃប.ស.ស ឬគ្រូពេទ្យត្រួតពិនិត្យគុណភាពសេវា ឬមន្ត្រីអធិការកិច្ច ដែលត្រូវបានចាត់តាំងជាផ្លូវការជាលាយលក្ខណ៍អក្សរពីនាយកនៃ**ប.ស.ស** ដើម្បីត្រួតពិនិត្យមើលប្រតិបត្តិការរបស់មូលដ្ឋានសុខាភិបាល និងពិនិត្យឯកសារអ្នកជម្ងឺ ឬជនរងគ្រោះដែលជាសមាជិក**ប.ស.ស** ឬឯកសារពាក់ព័ន្ធចាំបាច់ផ្សេងៗទៀតទាក់ទងនឹងការផ្តល់សេវា និងទូទាត់ថ្លៃសេវា [70]។

### គ. ការត្រួតពិនិត្យ និងវាយតម្លៃគុណភាពនៃសេវាសុខាភិបាល

#### គ.១. ការត្រួតពិនិត្យសេវាសុខាភិបាល

ការត្រួតពិនិត្យសេវាសុខាភិបាលនៅតាមមូលដ្ឋានសុខាភិបាល គឺជាការត្រួតពិនិត្យដើម្បីធានាពីភាពត្រឹមត្រូវនៃការផ្តល់សេវវានៅតាមមូលដ្ឋានសុខាភិបាល ដែលជាដៃគូ។

ការត្រួតពិនិត្យត្រូវធ្វើឡើងដោយមន្ត្រី/បុគ្គលិក ឬគណៈកម្មការវេជ្ជាសាស្ត្រនៃ**ប.ស.ស** ឬគ្រូពេទ្យ

[70] ប្រកាសអន្តរក្រសួងលេខ២៩១ ក.ប/ប្រ.ក ស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព ឧបសម្ព័ន្ធ១,២, និង ៣

ត្រួតពិនិត្យគុណភាពសេវា ឬមន្ត្រីអធិការកិច្ច ដែលត្រូវបានចាត់តាំងជាផ្លូវការជាលាយលក្ខណ៍អក្សរពីនាយកនៃ**ប.ស.ស**ដើម្បីៈ ត្រួតពិនិត្យមើលប្រតិបត្តិការរបស់មូលដ្ឋានសុខាភិបាល និងពិនិត្យឯកសារអ្នកជម្ងឺ ឬជនរងគ្រោះដែលជាសមាជិក**ប.ស.ស** ឬឯកសារពាក់ព័ន្ធចាំបាច់ផ្សេងៗទៀតទាក់ទងនឹងការផ្តល់សេវា និងទូទាត់ថ្លៃសេវា។ ដើម្បីឱ្យការងារនេះធ្វើការដោយប្រសិទ្ធភាព គ្រប់មូលដ្ឋានសុខាភិបាលត្រូវៈ

- អនុញ្ញាតឱ្យភាគីបេឡាជាតិរបបសន្តិសុខសង្គមធ្វើការមើលនូវប្រតិបត្តិការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលរបស់ខ្លួន ថាតើវាល្អ ឬ មានបញ្ហាយ៉ាងណាៈ ការមើលនូវប្រតិបត្តិការនេះ គឺមើលទាំងក្រមសីលធម៌វិជ្ជាជីវៈសុខាភិបាលរបស់មូលដ្ឋានសុខាភិបាល របៀបរបបនៃការផ្តល់សេវា អនាម័យ និងការគោរពនូវគោលការណ៍ផ្សេងៗទៀតដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង។
- រៀបចំឯកសាររបស់អ្នកជម្ងឺ ឬជនរងគ្រោះ ដែលជាសមាជិក**ប.ស.ស** ឬឯកសារពាក់ព័ន្ធចាំបាច់ផ្សេងៗទៀតទាក់ទងនឹងការផ្តល់សេវា និងការទូទាត់ថ្លៃសេវាឱ្យខាង**ប.ស.ស** ធ្វើការពិនិត្យដើម្បីធានាភាពត្រឹមត្រូវ។
- ត្រូវទទួលយកភ្នាក់ងារ និងមានបន្ទប់ធ្វើការសម្រាប់ភ្នាក់ងារ**ប.ស.ស** នៅក្នុងមន្ទីរពេទ្យទាំងអស់ដើម្បីត្រួតពិនិត្យសុពលភាពនៃការប្រើប្រាស់សេវារបស់សមាជិកនីមួយៗ និងសម្របសម្រួលលើការប្រើប្រាស់សេវាពីសំណាក់សមាជិក**ប.ស.ស**។
- ធ្វើការស្ទង់មតិពីភាពពេញចិត្តរបស់សមាជិក**ប.ស.ស** ពីភាគី"**ខ**"។ និងផ្តល់ពត៌មានត្រឡប់ទៅឱ្យភាគី"**ខ**" ព្រមទាំងក្រសួងក្រសួងអាណាព្យាបាលអំពីលទ្ធភាពនៃការស្ទង់មតិនេះ។

**គ.២. ការវាយតម្លៃគុណភាព**

ការវាយតម្លៃមិនត្រឹមតែជួយជម្រុញឱ្យការបម្រើសេវាកាន់តែមានភាពល្អប្រសើរនោះទេ ប៉ុន្តែវាក៏បានចូលរួមចំណែកនៅក្នុងការសម្រួល និងកាន់តែមានភាពច្បាស់លាស់ក្នុងការទូទាត់ថ្លៃសេវាផងដែរ។ សូចនាករណ៍វាយតម្លៃគុណភាពសេវាត្រូវធ្វើក្នុងរយៈពេល០៦ (ប្រាំមួយ)ខែម្តង និងអនុលោមតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវា។

| **តារាងទី១ តារាងសូចនាករណ៍គុណភាពសេវា** | | | |
|---|---|---|---|
| **សូចនាករណ៍(Indicator)** | **ទិសដៅ** | **មធ្យោបាយផ្ទៀងផ្ទាត់** | **ពេលវេលា** |
| រយៈពេលរង់ចាំរបស់អ្នកជម្ងឺ ឬជនរងគ្រោះមិនលើសពី ៣០នាទី | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |

| | | | |
|---|---|---|---|
| បុគ្គលិកសុខាភិបាលមានឯកសណ្ឋានត្រឹមត្រូវ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| មានអនាម័យជាទូទៅ និងតាមបន្ទប់ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| ការទទួលស្គាល់គុណភាពពីអ្នកជម្ងឺថាល្អ | ៨០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| របាយកាណ៍អំពីឥរិយាបថល្អរបស់បុគ្គលិកពេទ្យចំពោះអ្នកជម្ងឺ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| ការចុះសួរសុខទុកអ្នកជម្ងឺអំពីបុគ្គលិកពេទ្យយ៉ាងតិច ០២ដង ក្នុង ០១ថ្ងៃ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| គ្មានការបង់ប្រាក់ក្រៅផ្លូវការក្នុងគ្រប់ករណី | ១០០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| គ្មានការទាមទារ ឬតម្រូវឲ្យសមាជិក **ប.ស.ស** ទិញឱសថ លើកលែងតែមានចែងក្នុងកិច្ចព្រមព្រៀង | ១០០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |

| **តារាងទី២ ពិន្ទុសម្រាប់ការវាយតម្លៃគុណភាពសេវា** | |
|---|---|
| **ពិន្ទុ** | **អត្រាបង់ថ្លៃសេវា** |
| >៩០% | បង់១២០% |
| ធំជាង ៨៥% ទៅ ៩០% | បង់១០០% |
| ធំជាង៧០% ទៅ ៨៥% | បង់៨០% |
| ធំជាង៦០% ទៅ ៧០% | បង់៧០% |
| ធំជាង៥០% ទៅ ៦០% | បង់៦០% |
| ចាប់ពី៥០% ចុះ | មិនអាចចុះកិច្ចព្រមព្រៀងបាន |

កិច្ចព្រមព្រៀងនេះអាចត្រូវបានពិនិត្យ និងកែសម្រួល ឬសើរើឡើងវិញដោយផ្អែកទៅតាមលទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវា និងអនុលោមតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវា។

កិច្ចព្រមព្រៀងនេះត្រូវធ្វើជាច្បាប់ដើមចំនួន ០២ (ពីរ) ច្បាប់ ជាភាសាខ្មែរ ហើយមានតម្លៃស្មើ

គ្នានៅចំពោះមុខច្បាប់នៃព្រះរាជាណាចក្រកម្ពុជា[71]។

បន្ទាប់ពីបានវាយតម្លៃ និងឈានទៅចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល ដើម្បីបម្រើសេវាសុខាភិបាលជូនសមាជិក**ប.ស.ស** **ប.ស.ស**ត្រូវរៀបចំទូទាត់ថវិកាមកឱ្យខាងមូលដ្ឋានសុខាភិបាលវិញជាចាំបាច់ដើម្បីធានានិរន្តរភាពនៃការផ្តល់សេវា និងអភិវឌ្ឍលើផ្នែកសុខាភិបាលរបស់មូលដ្ឋានសុខាភិបាល។ ការទូទាត់នេះទៀតសោត ត្រូវធ្វើតាមយន្តការនៃការទូទាត់ថ្លៃសេវាសុខាភិបាល ដែលកំណត់ដោយប្រកាសអន្តរក្រសួង នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល។

### កថាខណ្ឌទី ២ យន្តការនៃការទូទាត់ថ្លៃសេវាសុខាភិបាល

#### ក. លក្ខណៈរួមនៃការទូទាត់ថ្លៃសេវា

ដើម្បីទទួលបាននូវការទូទាត់ថ្លៃសេវា មូលដ្ឋានសុខាភិបាលត្រូវដាក់ពាក្យស្នើសុំតាមទម្រង់ដែលមានកំណត់ដោយ **ប.ស.ស** ដោយអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

- មូលដ្ឋានសុខាភិបាលត្រូវបើកគណនីនៅធានាគារដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស**ដើម្បីទទួលបានការទូទាត់ថ្លៃសេវាពី**ប.ស.ស** ។
- រាល់ការទូទាត់ថ្លៃសេវាត្រូវធ្វើឡើងនៅរៀងរាល់ថ្ងៃដំណាច់ខែនីមួយៗ ដោយមានភ្ជាប់មកជាមួយនូវលិខិតស្នើសុំទូទាត់ទិន្នន័យប្រើប្រាស់សេវា ដោយមានតម្លៃតាមប្រភេទករណី និងតាមតម្លៃនៃប្រភេទសេវាដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ១នៃប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព រួមទាំងវិក្កយបត្រ ប័ណ្ណវិភាគអមវេជ្ជសាស្ត្រ និងលទ្ធផល និងវេជ្ជបញ្ជាព្រមទាំងលិខិតចេញពីមូលដ្ឋានសុខាភិបាលរបស់សមាជិក **ប.ស.ស**។ **ប.ស.ស**ត្រូវទូទាត់ក្នុងកំឡុង៣០ (សាមសិប)ថ្ងៃនៃប្រតិទិនបន្ទាប់ពីកាលបរិច្ឆេទទទួលបានលិខិតស្នើទូទាត់ថ្លៃសេវា និងឯកសារពាក់ព័ន្ធ។

ការទូទាត់ថ្លៃសេវាត្រូវបានពិនិត្យកែសម្រួលឡើងវិញ បន្ទាប់ពីលទ្ធផលនៃការវាយតម្លៃផ្អែកលើសូចនាករណ៍ និងពិន្ទុនៃតម្លៃសូចនាករណ៍នោះរៀងរាល់០៦ (ប្រាំមួយ)ខែម្តង។

#### ខ. ការទូទាត់តាមប្រភេទករណី

ដើម្បីអនុវត្តវិធីសាស្ត្រទូទាត់ថ្លៃសេវាតាមករណីនេះ **ប.ស.ស**ត្រូវធ្វើការវាយតម្លៃ និងចាត់ថ្នាក់មូលដ្ឋានសុខាភិបាល ដែលត្រូវចុះកិច្ចព្រមព្រៀងជាកម្រិត MPA កម្រិតCPA1 កម្រិតCPA2 កម្រិតCPA3 កម្រិតចម្រុះ ឬកម្រិតNH ទៅតាមវិសាលភាព និងគុណភាពសេវារបស់មូលដ្ឋាន

[71] ប្រកាសអន្តរក្រសួងលេខ២៩១ ក.ប/ប្រ.ក ស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព ឧបសម្ព័ន្ធ១,២, និង៣ ប្រការ ៥

សុខាភិបាលនោះ។ មូលដ្ឋានសុខាភិបាលមួយអាចទទួលកិច្ចព្រមព្រៀងសម្រាប់សេវាកម្រិតចម្រុះបាន។

**ឧទាហរណ៍:** មណ្ឌលសុខភាព បើមណ្ឌលសុខភាពនោះមានគ្រែមួយ នោះសេវាសម្រាកពេទ្យអាចចាត់ថ្នាក់ជាកម្រិតCPA1 ហើយសេវាដទៃទៀតចាត់ថ្នាក់ MPA ។ ហើយមន្ទីរពេទ្យកម្រិតCPA1ខ្លះ ទទួលការវះកាត់ធំ ក្នុងករណីនេះ ការវះកាត់ធំនេះអាចចាត់ថ្នាក់កម្រិត CPA2 ទោះបីសេវាដទៃទៀតចាត់ថ្នាក់កម្រិត CPA1 ក៏ដោយ។

យោងតាមប្រព័ន្ធសុខាភិបាល ដែលចេញដោយគេហទំព័រផ្លូវការរបស់ក្រសួងសុខាភិបាល បានកំណត់វិសាលភាព និងកម្រិតគុណភាពនៃការផ្ដល់សេវាសាធារណៈដូចខាងក្រោម៖

- **ទី១ មន្ទីរពេទ្យជាតិ៖** ផ្ដល់សំណុំសេវាឯកទេសខ្ពស់ ( NH ) ហើយនៅតាមមន្ទីរពេទ្យមួយចំនួនសេវាខ្លះនៅកម្រិត ៣(CPA3)នៅឡើយ
- **ទី២ មន្ទីរពេទ្យបង្អែករាជធានី/ខេត្ត៖** ផ្ដល់សំណុំសេវាបង្គ្រប់កម្រិត ២(CPA2) និងកម្រិត៣ (CPA3)
- **ទី៣ មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ៖** ផ្ដល់សំណុំសេវាបង្គ្រប់កម្រិត ១(CPA1) និងកម្រិត២ (CPA2)
- **ទី៤ មណ្ឌលសុខភាព៖** ផ្ដល់សំណុំសេវាសុខភាពសកម្មភាពអប្បបរមា (GPA)។

ហើយការទូទាត់តាមករណីត្រូវបានកំណត់យកប្រភេទករណី សរុប៥២ ដោយបែងចែក ៥ កម្រិតនៃសេវាព្យាបាលថែទាំវេជ្ជសាស្ត្រ។

ករណីសេវាខ្លះ គឺមានឈ្មោះដូចគ្នា ប៉ុន្តែកម្រិតសេវាដែលផ្ដល់ទៅឱ្យជនរងគ្រោះមានភាពខុសគ្នាទៅតាមកម្រិតនៃលទ្ធភាពរបស់មូលដ្ឋានសុខាភិបាល។ ដូច្នេះតម្លៃរបស់វាក៏ប្រែប្រួល ឬខុសគ្នាទៅតាមនេះដែរ។

**ឧទាហរណ៍៖ ករណីការព្យាបាលជម្ងឺរបេង នៅមូលដ្ឋានសុភិបាល**

| | **ការទូទាត់ទៅតាមកម្រិតសេវា (គិតជារៀល)** | | | | |
|---|---|---|---|---|---|
| ករណី(ជម្ងឺ) | MPA | CPA1 | CPA2 | CPA3 | NH |
| ជម្ងឺរបេង | គ្មាន | ១៦០ ០០០៛ | ១៨០ ០០០៛ | ២០០ ០០០៛ | ៣០០ ០០០៛ |

**គ. ការទូទាត់តាមប្រភេទសេវា**

ចំណុចនេះ មានគោលបំណងរៀបចំវិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា សម្រាប់ករណីពិសេសតាមតារាងតម្លៃសេវាព្យាបាលថែទាំវេជ្ជសាស្ត្ររបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម **(ប.ស.ស)** សម្រាប់ផ្នែកថែទាំសុខភាព។

វិធីសាស្ត្រនេះ ត្រូវអនុវត្តចំពោះប្រភេទករណីដែលមានក្នុងចំណុច "ការទូទាត់តាមករណី" (ឧបសម្ព័ន្ធ ១ នៃប្រកាសអន្តរក្រសួង លេខ១៧៣ កប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០៦ ស្ដីពីយន្តការទូទាត់ថ្លៃសេវាផ្នែថែទាំសុខភាព) ហើយដែលត្រូវការសេវាពិសេសបន្ថែម ឬសេវាព្យាបាលបន្ត

និងអនុវត្តចំពោះករណីពិសេសទៀតដែលគ្មានក្នុងប្រភេទករណីនៃចំណុច "ការទូទាត់តាមករណី"។

**គ.១. ប្រភេទករណីដែលមាន នៅក្នុងឧបសម្ព័ន្ធ ៦ ហើយដែលត្រូវការសេវាពិសេសបន្ថែម ឬ សេវាព្យាបាល និងថែទាំបន្តមានៈ**

- ការលាងឈាមៈ ជាការលាងបណ្តាលមកពីឧបទេវហេតុគ្រោះថ្នាក់ផ្សេងៗ ឬសង្គ្រោះបន្ទាន់។ (ករណីលាងឈាមតាមការគ្រោងទុកដែលបណ្តាលមកពីជម្ងឺរ៉ាំរ៉ៃមិនត្រូវបានរាប់បញ្ចូលឡើយ)
- MRI (Magnetic Resonance Imaging) និង CT Scan
- ការព្យាបាលដោយកាំរស្មី អ៊ិចៈ សម្រាប់ការព្យបាលជម្ងឺមហារីកដោយកាំរស្មីអ៊ិច ដោយមូលដ្ឋានសុខាភិបាល
- ការវិភាគរកជម្ងឺមហារីកៈ គឺជាវិភាគចំណិតដុំសាច់សរីរាង្គ ឬផ្នែកណាមួយដើម្បីរកកោសិកាមហារីក
- MATERIEL OSTEOSYNTHESEៈ ជាលោហៈដែលប្រើប្រាស់សម្រាប់តភ្ជាប់ឆ្អឹងដែលបាក់
- បន្ទប់ម៉ាស៊ីនត្រជាក់ៈ ផ្អែកតាមស្ថានភាពជាក់ស្តែង ឬ កិច្ចព្រមព្រៀង
- សេវាបញ្ជូនជនរងគ្រោះ ឬអ្នកជម្ងឺ និងសេវាបញ្ជូនសព
- សេវាស្តារបុននីតិសម្បទាៈ ការផ្តល់សេវាស្តារនីតិសម្បទា ឬសម្ភារៈបរិក្ខារ និងឧបករណ៍សិប្បនិម្មិត ឬត្រូវផ្តល់ទាំងអស់ហើយត្រូវជ្រើសរើស និងវាយតម្លៃដោយ**ប.ស.ស** ដោយផ្អែកលើស្ថានភាព និងតារាងតម្លៃសេវារបស់អង្គភាព ឬស្ថាប័នរដ្ឋ ឬឯកជនដែលផ្តល់សេវានោះ។

**គ.២. ករណីពិសេសផ្សេងទៀតដែលគ្មាននៅក្នុងឧបសម្ព័ន្ធ ៦**

- ការចោះ ឬដាប់ឆ្អឹងលលាដ៏ក្បាល (Trepanation) គឺជាអន្តរាគមន៍វះកាត់ដោយដោះ ឬដាប់ឆ្អឹងលលាដ៏ក្បាល ដើម្បីពិនិត្យស្រទាប់ក្រៅ នៃស្រោមខួរក្បាល និងព្យាបាលបញ្ហាសុខភាពទាក់ទងនឹងជម្ងឺក្នុងស្រទាប់ក្រៅនៃស្រោមខួរ និងក្នុងខួរក្បាល ដែលផ្តល់ដោយមូលដ្ឋានសុខាភិបាល។
- ការវះកាត់បេះដូង និងសរសៃឈាម គឺជាការវះកាត់បេះដូង និងសរសៃឈាមធំៗដោយគ្រូពេទ្យឯកទេសបេះដូង ក្នុងករណីសង្គ្រោះបន្ទាន់សម្រាប់ផ្នែកថែទាំសុខភាព។ ចំពោះការវះកាត់បេះដូង និងសរសៃឈាមតាមការគ្រោងទុកមិនត្រូវបានរាប់បញ្ចូលឡើយ។
- ការព្យាបាលសង្គ្រោះបន្ទាន់ជម្ងឺបេះដូង គឺជាអន្តរាគមន៍ព្យាបាល និងថែទាំ

វេជ្ជសាស្ត្រឯកទេសបេះដូងក្នុងគោលបំណងសង្គ្រោះអាយុជីវិតរបស់អ្នកជម្ងឺ ឬជនងរងគ្រោះសម្រាប់របបថៃទាំសុខភាព។ អន្តរាគមន៍នេះសម្រាប់តែមជ្ឈមណ្ឌលព្យាបាលជម្ងឺបេះដូងភ្នំពេញ ឬមូលដ្ឋានសុខាភិបាលដែលដែលបានចុះកិច្ចព្រមព្រៀងជាមួយ**ប.ស.ស** តែប៉ុណ្ណោះ។

សម្រាប់ករណីដូចមានបានរៀបរាប់ក្នុងចំណុច "**គ.១**" មូលដ្ឋានសុខាភិបាលនឹងទទួលបានការទូទាត់តាមប្រភេទសេវាសម្រាប់ថ្លៃសេវាបន្ថែម ឬសេវាព្យាបាល និងថៃទាំបន្តទៅតាមតម្លៃហិរញ្ញប្បទានផ្លូវការរបស់មូលដ្ឋានសុខាភិបាល ឬ ទៅតាមកិច្ចព្រមព្រៀង។ ការទូទាត់នេះ មិនរាប់បញ្ចូលការទូទាត់តាមករណីដែលបានកំណត់ក្នុង "ឧបសម្ព័ន្ធ ១ នៃប្រកាសអន្តរក្រសួងលេខ: ១៧៣ កប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែថៃទាំសុខភាព" ។

សម្រាប់ករណីដូចបានរៀបរាប់ក្នុងចំណុច "**គ.២**" មូលដ្ឋានសុខាភិបាលនឹងទទួលបានការទូទាត់ថ្លៃតាប្រភេទសេវាហិរញ្ញប្បទានផ្លូវការរបស់មូលដ្ឋានសុខាភិបាល ឬទៅតាមកិច្ចព្រមព្រៀង[72]។

យន្តការនៃការទូទាត់ថ្លៃសេវាសម្រាប់របបថៃទាំសុខភាពត្រូវបានប្រើប្រាស់ដូចគ្នារវាងរបបថៃទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងរបបថៃទាំសុខភាពសម្រាប់មន្ត្រីសាធារណ: អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

សម្រាប់ចំពោះមន្ត្រីសាធារណ: អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ទោះបីជាយន្តការអនុវត្តដូចគ្នាទៅនឹងជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារក៏ដោយ ប៉ុន្តែការព្យាបាលជម្ងឺមហារីកដោយសារធាតុគីមី និងឱសថព្យាបាលជម្ងឺទឹកនោមផ្អែម និងជម្ងឺលើសឈាមក្រៅពីឱសថក្នុងសារវន្តដែលត្រូវទូទាត់ថ្លៃតាមសេវាព្យាបាលនីមួយៗ[73]។

[72] ប្រកាសអន្តរក្រសួងលេខ២៩១ ក.ប/ប្រ.ក ស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថៃទាំសុខភាព ឧបសម្ព័ន្ធ ២

[73] អនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណ: និងផ្នែកថៃទាំសុ ខភាពសម្រាប់មន្ត្រីសាធារណ: អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ប្រការ ២១

# ជំពូកទី ៤
# បញ្ហាប្រឈម ដំណោះស្រាយ និងទិសដៅអនុវត្តបន្ត

# ជំពូកទី ៤

# បញ្ហាប្រឈម ដំណោះស្រាយ និងទិសដៅអនុវត្តបន្ត

## ផ្នែកទី ១ បញ្ហាប្រឈម

### កថាខណ្ឌទី ១ ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងសមាជិក ប.ស.ស

#### ក. ការចុះបញ្ជិកាសហគ្រាស

និយោជកមួយចំនួននៅតែមិនទាន់ស្គាល់ច្បាស់ពីបេឡាជាតិរបបសន្តិសុខសង្គម និងនីតិវិធីនៃការចុះបញ្ជិកាសហគ្រាសចូលមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម។ ចំណែកឯប្រភេទសិប្បកម្មមិនរៀបរយគ្មានឯកសារគតិយុត្តត្រឹមត្រូវដើម្បីជាមូលដ្ឋានក្នុងការចុះបញ្ជិកានៅឡើយ និងមួយចំនួនទៀតមិនចាប់អារម្មណ៍ក្នុងការមកចុះបញ្ជិកាព្រោះតែគេគិតថាវាជារឿងគ្មានប្រយោជន៍។

ការបិទទ្វារ ផ្អាកសកម្មភាព ប្តូរអាសយដ្ឋាន ប្តូររដ្ឋបាលថ្មី ប្តូរម្ចាស់ ប្តូរឃីហោថ្មី ដោយមិនបានជូនដំណឹងមក**ប.ស.ស**។ លើសពីនេះ ការជួបដើម្បីផ្សព្វផ្សាយច្បាប់ បទដ្ឋានគតិយុត្តមួយចំនួនដែលពាក់ព័ន្ធដល់ម្ចាស់សហគ្រាសមួយចំនួនដូចជា ភោជនីយដ្ឋាន ក្លឹបកំសាន្ត ខារ៉ាអូខេ...ជាដើម មានការលំបាកខ្លាំង។

#### ខ. ការចុះបញ្ជិកាសមាជិក ប.ស.ស

ការចុះកំណត់អត្តសញ្ញាណត្រូវបានលើកពេលជារឿយៗដោយសារការសុំពន្យារពេល។ លើសពីនេះ នៅពេលដែលចុះកំណត់នៅតាមមូលដ្ឋានសហគ្រាស គ្រឹះស្ថានការបញ្ជូនកម្មករនិយោជិតមកតិចៗដែលធ្វើឱ្យចំណាយពេលយូរ ឬចុះមកម្តងទៀត។

កម្មករនិយោជិតមួយចំនួនមិនមានឯកសារគ្រប់គ្រាន់ក្នុងការមកចុះបញ្ជិកា។ មួយវិញទៀតកម្មករនិយោជិតមួយចំនួនបានខ្ចីឯកសាររបស់អ្នកដទៃមកធ្វើការចុះបញ្ជិកា ការច្រឡំឯកសារ និងការស្ទួនឈ្មោះ។

### កថាខណ្ឌទី ២ ការបង់ភាគទាន

និយោជកសហគ្រាសមួយចំនួនមិនទាន់យល់ច្បាស់ពាក់ព័ន្ធនឹងនីតិវិធីនៃការបង់ភាគទាន ការផ្តល់ទិន្នន័យកម្មករនិយោជិតមក**ប.ស.ស** មិនមានភាពច្បាស់លាស់តាមខែនីមួយ ការយឺតយ៉ាវ និងគេចវេសក្នុងការបង់ភាគទាន។

### កថាខណ្ឌទី ៣ ការផ្តល់តាវកាលិក

សមាជិក**ប.ស.ស** មួយចំនួននៅតែមិនមានឯកសារច្បាស់លាស់ក្នុងការទាមទារតាវកាលិក និងទាមទារតាវកាលិកហានិភ័យការងារទាំងខ្លួនមិនមែនទទួលរងនូវគ្រោះថ្នាក់ការងារ។

នៅពេលដែលមានបញ្ហាផ្នែកសុខភាព សមាជិក**ប.ស.ស** មួយចំនួនទៅព្យាបាលនៅមន្ទីរពេទ្យដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយ**ប.ស.ស** និងទៅមន្ទីរពេទ្យដែលចុះកិច្ចព្រមព្រៀងជាមួយ**ប.ស.ស** ប៉ុន្តែមិនបានបង្ហាញកាតសមាជិកដល់មន្ទីរពេទ្យ។ ហើយមន្ទីរពេទ្យដែលចុះកិច្ចព្រមព្រៀងជាមួយ**ប.ស.ស** មួយចំនួនការផ្តល់សេវានៅមានកម្រិតនៅឡើយ។

## ផ្នែកទី ២ ដំណោះស្រាយ

### កថាខណ្ឌទី ១ ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងសមាជិកប.ស.ស

**ប.ស.ស**បានចាត់មន្ត្រី និងបុគ្គលិករបស់ខ្លួនឱ្យចុះធ្វើការផ្សព្វផ្សាយពន្យល់ណែនាំពាក់ព័ន្ធទៅនឹងការជម្រុញឱ្យនិយោជក ឬម្ចាស់សហគ្រាសមកធ្វើការចុះបញ្ជិកាសហគ្រាសរបស់ពួកគេស្របទៅតាមបទប្បញ្ញត្តិជាធរមាន។ លើសពីនេះ **ប.ស.ស**បានបន្តព្យាយាមសម្របសម្រួលណាត់ជួបនិយោជក ឬម្ចាស់សហគ្រាសនៅពេលរសៀល និងបន្តពន្យល់ឱ្យអស់លទ្ធភាពនូវនីតិវិធីដែលពាក់ព័ន្ធនឹងការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន សហការក្នុងការចុះបញ្ជិកាកម្មករនិយោជិត។

ចំពោះកម្មករនិយោជិត **ប.ស.ស**ក៏បានជម្រុញឱ្យមានការប្រើប្រាស់តែអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (សម្រាប់ជនជាតិខ្មែរ) និងលិខិតឆ្លងដែន (សម្រាប់ជនបរទេសដែលបម្រើការងារនៅព្រះរាជាណាចក្រកម្ពុជា)សម្រាប់ធ្វើធ្វើជាឯកសារយោងក្នុងការចុះបញ្ជិកា។ ហើយថែមទាំងបានសហការជាមួយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃដើម្បីសម្រួលដល់ការធ្វើ កែ និងបោះពុម្ពម្តងទៀតនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដល់កម្មករនិយោជិតផងដែរ។

### កថាខណ្ឌទី ២ ការបង់ភាគទាន

បាន និងកំពុងព្យាយាមទំនាក់ទំនងផ្ទាល់ដើម្បីជួយបង្រៀនឱ្យចេះរៀបចំឯកសារបង់ភាគទាន និងដាក់លិខិតកំហិតក្នុងករណីដែលសហគ្រាសណាយឺតយ៉ាវ និងគេចវេសក្នុងការបង់ភាគទាន។

### កថាខណ្ឌទី ៣ ការផ្តល់តាវកាលិក

បាន និងកំពុងព្យាយាមទំនាក់ទំនងផ្ទាល់ដើម្បីជួយបង្រៀនឱ្យចេះរៀបចំឯកសារក្នុងការទាមទារតាវកាលិក និងបានជម្រុញឱ្យសមាជិក**ប.ស.ស** ទៅចុះសំបុត្រអាពាហ៍ពិពាហ៍ និងទៅប្រើប្រាស់សេវាសុខាភិបាលនៅតាមមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយ**ប.ស.ស**។

បន្តចុះកិច្ចព្រមព្រៀង និងដាក់ភ្នាក់ងារ**ប.ស.ស** នៅតាមមូលដ្ឋានសុខាភិបាល និងបន្តកែសម្រួលកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលដើម្បីឱ្យការផ្តល់សេវាកាន់តែល្អប្រសើរបន្ថែមទៀត។

## ផ្នែកទី ៣ ទិសដៅអនុវត្តបន្ត

បន្ទាប់ពីការអនុវត្តប្រកបដោយជោគជ័យនូវរបបសន្តិសុខសង្គមផ្នែកធានារ៉ាប់រងហានិភ័យការងារ (ចាប់តាំងពីឆ្នាំ២០០៨) និងផ្នែកថែទាំសុខភាពថែទាំសុខភាព (ចាប់តាំងពីឆ្នាំ២០១៦)

សម្រាប់កម្មករនិយោជិត និងទើបតែបន្តអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជននៅដើមឆ្នាំ២០១៨នេះ។ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា **ប.ស.ស**បាននឹងកំពុងត្រៀមខ្លួន និងរៀបចំតាក់តែងនូវលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការអនុវត្តរបបថ្មីបន្ថែមទៀត ដែលក្នុងនោះរួមមានរបបធានារ៉ាប់រងហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងរបបសោធននិវត្តន៍។

**កថាខណ្ឌទី ១ របបធានារ៉ាប់រងហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ**

យោងតាមព្រះរាជក្រឹត្យ នស/រកត/០២១៧/០៧៨ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មាត្រា៥ បានកំណត់ឱ្យ**ប.ស.ស** ជាអ្នកចាត់ចែង និងគ្រប់គ្រងរបបសន្តិសុខសង្គមទាំងពីរផ្នែកនេះផ្ទាល់មុខ។ ចំណែកឯលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកសម្រាប់របបសន្តិសុខសង្គមទាំងពីនេះក៏បានរៀបចំរួចជាស្រេចដោយស្របទៅតាមព្រះរាជក្រឹត្យខាងលើនេះ។

**កថាខណ្ឌទី ២ របបសោធន**

របបសោធននិវត្តន៍ត្រូវបានចែងក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារត្រង់ជំពូកទី២ មាត្រា៧ ដល់មាត្រា១១ប៉ុន្តែមិនទាន់បានអនុវត្តឡើយរហូតដល់ពេលនេះ។ រហូតដល់ដើមឆ្នាំ២០១៨នេះ តាមរបាយការណ៍ស្តីពីសមិទ្ធផល រយៈពេល១០ឆ្នាំ (២០០៨-២០១៧) និងទិសដៅការងារឆ្នាំ២០១៨របស់បេឡាជាតិរបបសន្តិសុខសង្គម និងការអង្កេតរបស់រូបខ្ញុំបាទដែលបម្រើការងារនៅស្ថាប័ននេះជាង២ឆ្នាំនោះ គឺបានបង្ហាញថា បេឡាជាតិរបបសន្តិសុខសង្គមបាននឹងកំពុងធ្វើការជ្រើសរើស និងផ្ទេរបុគ្គលិកដើម្បីឱ្យទៅបម្រើការងារនៅការិយាល័យសោធន នៃបេឡាជាតិរបបសន្តិសុខសង្គមទោះបីជាមិនទាន់មានសម្រេចណាមួយពាក់ព័ន្ធនឹងការកំណត់តួនាទី និងភារកិច្ចរបស់ការិយាល័យជំនាញដែលទើបតែបង្កើតថ្មីនេះនៅឡើយ។ លើសពីនេះ បេឡាជាតិរបបសន្តិសុខសង្គមបានស្នើសុំសហការជាមួយដៃគូអភិវឌ្ឍមួយចំនួនក្នុងការរៀបចំយន្តការអនុវត្ត បណ្តុះបណ្តាលធនធានមនុស្ស និងស្នើសុំឱ្យមានអ្នកជំនាញការផ្នែកគណិតវិទ្យាក្នុងការស្រាវជ្រាវ និងប្រមូលទិន្នន័យសម្រាប់ធ្វើការងារវិភាគលើការបង់ភាគទាន និងសេវាដែលត្រូវផ្តល់ថែមទៀតផង។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើរួចមក ខ្ញុំសង្កេតឃើញថា ក្នុងនាមជាប្រតិបត្តិករក្នុងការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណ: និងថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានធ្វើដំណើរដ៏រប៉ាក់រប៉ើកនៃការអនុវត្តរបបសន្តិសុខសង្គមទាំងឡាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។

អស់រយៈពេល១០ឆ្នាំនៃការឈានជើងមកបំពេញភារកិច្ចរបស់ខ្លួនមកនេះ **ប.ស.ស**ទើបតែអនុវត្តបានតែរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងទើបតែចាប់ផ្តើមអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជននៅខែមករា ឆ្នាំ២០១៨ នេះតែប៉ុណ្ណោះ។

រយៈពេល១០ឆ្នាំ (២០០៨-២០១៧) និយោជក ឬម្ចាស់សហគ្រាសទាំងអស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិស្តីពីច្បាប់ស្តីពីការងារត្រូវមានកាតព្វកិច្ចចុះបញ្ជិកាសហគ្រាស ដោយក្នុងដំណាក់កាលនៃការចាប់ផ្តើមដំបូងនេះ ការចុះបញ្ជិកាត្រូវបានអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថានណាដែលមានកម្មករនិយោជិតចំនួន០៨ (ប្រាំបី)នាក់ឡើងទៅតែប៉ុណ្ណោះ។ របបធានារ៉ាប់រងហានិភ័យការងារបានពង្រីកវិសាលភាព គ្របដណ្តប់ទូទាំងប្រទេស និងបានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានបានចំនួន ១០ ៨៤៩ សហគ្រាស និងមានកម្មករនិយោជិតចំនួន ១ ៩៣៥ ៣១៦ នាក់ ស្រីចំនួន ៨៦៨ ១៨៦នាក់ ត្រូវជា ៦០, ៤៨% ថែមទាំងបានផ្តល់តាវកាលិកហានិភ័យការងារដល់កម្មករនិយោជិតដែលរងគ្រោះចំនួន ២០១ ៧៩៧ (ដងនាក់)។ ដើម្បីផ្តល់តាវកាលិកឱ្យកាន់តែមានប្រសិទ្ធភាព និងទាន់ពេលវេលា។ តាមរយៈនេះ **ប.ស.ស**បានដាក់ឱ្យដំណើរការនូវប្រព័ន្ធទូរស័ព្ទ **(Hot-line) 1286** និងប្រព័ន្ធគ្រប់គ្រងទិន្នន័យតាកាលិកហានិភ័យការងារដែលអាចគ្រប់គ្រងរបាយការណ៍អំពីហានិភ័យការងារ អង្កេត និងការគណនាតាវកាលិកដែលពន្លឿនក្នុងការផ្តល់នូវតាវកាលិក និងមានភាពត្រឹមត្រូវ។លើសពីនេះ**ប.ស.ស** បានធ្វើការចុះកិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យសាធារណៈ និងឯកជនបានចំនួន ១២២មូលដ្ឋាន និងបានដាក់ភ្នាក់ងារចាំសម្របសម្រួលការប្រើប្រាស់សេវារបស់សមាជិក**ប.ស.ស** នៅតាមមូលដ្ឋានសុខាភិបាលនោះ។ តាវកាលិកផ្នែកធានារ៉ាប់រងហានិភ័យការងារទាំងអស់ដោយសរុបជាទឹកប្រាក់ក្នុងការទូទាត់ថ្លៃជាមួយមន្ទីរពេទ្យដៃគូ និងមន្ទីរពេទ្យក្រៅផ្លូវការ និងសេវាស្តារនីតិសម្បទាសរុបអស់ចំនួន ៧៦, ៦៤ ប៊ីលានរៀល។

ចាប់តាំងពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦នៃការចាប់ផ្តើមអនុវត្តជំហានទី២ គឺ ( របបថែទាំ

